ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០២៣

លេខៈ ១៨

ឆ្នាំ២០២៤

# អារម្ភកថា

សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៣ សម្រេចបានក្នុងរង្វង់៥,០%។ កំណើនទាបជាងការរំពឹងទុកធៀបនឹងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ ដោយសារ ទី១-ភាពមិនប្រាកដប្រជានៃបរិការណ៍សកលនិងតំបន់៖ ស្ថានភាពសេដ្ឋកិច្ចសកល និងតំបន់បន្តគ្របដណ្ដប់ដោយភាពមិនប្រាកដប្រជា រួមមាន ស្លាកស្នាមដែលជាវិបាកនៃវិបត្តិជំងឺកូវីដ-១៩ ដែលនៅសេសសល់ សង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែន សង្គ្រាមរវាងក្រុមអ៊ីស្រាអែលនិងក្រុមហាម៉ាស់ វិបត្តិនៅតំបន់សមុទ្រក្រហម ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុក្នុងកម្រិតសកល និងការរួមតូចនៃលំហរថវិការបស់ប្រទេសជាច្រើន។ ស្ថានភាពបែបនេះបានធ្វើឱ្យសមិទ្ធកម្មសេដ្ឋកិច្ចសម្រេចបានទាបជាងអ្វីដែលបានគ្រោងទុក និងក្នុងកម្រិតផ្សេងៗគ្នាទៅតាមវិស័យនិងតំបន់នីមួយៗ ទី២-ស្ថានភាពសង្គម សេដ្ឋកិច្ចក្នុងស្រុក រួមមាន៖ (១)-ការផ្ទេរការដឹកនាំរាជរដ្ឋាភិបាលអាណត្តិថ្មីដោយរលូន និងប្រកបដោយស្ថិរភាពនយោបាយ និងសន្តិសុខសង្គម និង(២)-ការពង្រឹងការងារកែទម្រង់ និងការដាក់ចេញនូវគោលនយោបាយឆ្លើយតបប្រកបដោយបុរេសកម្ម និងទន់ភ្លន់ បានជួយកាត់បន្ថយកម្មវិបាកទាំងឡាយពីកត្តាខាងក្រៅលេចឡើង។ ក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា បានអនុវត្ត និងសម្រេចបាននូវសមិទ្ធផលដែលនៅសេសសល់ក្នុង "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤" "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣" និងគោលនយោបាយ និងការកែទម្រង់អាទិភាពនានា។ ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាពទាំងនេះ បានក្លាយជាមូលដ្ឋានដ៏សំខាន់ ដែលបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភាដាក់ចេញ និងអនុវត្តនូវ "**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១**" "**កម្មវិធីគោលនយោបាយអាទិភាពទាំង៦**" "**វិធានការគន្លឹះទាំង៥**" រួមជាមួយនឹងការរៀបចំ "វេទិការាជរដ្ឋាភិបាល វិស័យឯកជនលើកទី១៩" ដើម្បីដោះស្រាយកង្វល់ និងលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ និងវិស័យឯកជន។ សមិទ្ធផលទាំងអស់នេះបានកសាងជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់របៀបវារៈអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០២៤ និងទៅខាងមុខ និងទី៣-កត្តាបច្ចេកទេស៖ ការប្ដូរឆ្នាំគោលទិន្នន័យគណនេយ្យជាតិពីឆ្នាំ២០០០ មកឆ្នាំ២០១៤ បានធ្វើឱ្យមានការរីកទំហំសេដ្ឋកិច្ច (ប្រមាណ៣២%ជាមធ្យម) និងការផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលធ្វើឱ្យតួលេខកំណើនសេដ្ឋកិច្ចរួមតូចជាងមុន និងមានបច្ច័យលើការគិតគូរផ្នែកគោលនយោបាយ។ សេដ្ឋកិច្ចកម្ពុជាបានថមថយជាងការរំពឹងទុកនៃវិស័យជំរុញកំណើនមួយចំនួន ជាពិសេសវិស័យកាត់ដេរ សំណង់ និងអចលនទ្រព្យ (កត្តាសេដ្ឋកិច្ចជាក់ស្តែង)។ បើទោះបីសង្គម សេដ្ឋកិច្ចកម្ពុជាវិលត្រលប់ទៅរកប្រក្រតីភាពវិញបន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ក៏ពិតមែន ប៉ុន្តែស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៣ នៅតែស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ ពោលគឺវិបត្តិមួយមិនទាន់បានបញ្ចប់ទាំងស្រុងផង ក៏លេចចេញនូវវិបត្តិមួយផ្សេងទៀត ដូចជាការបន្តអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន និងការផ្ទុះឡើងនូវភាពចម្រូងចម្រាសនៅតំបន់សមុទ្រក្រហមជាដើម ស្របពេលដែលស្ថានភាពរូបិយវត្ថុសកលនៅបន្តរឹតបន្តឹង។ ការណ៍នេះ បានបន្តដាក់សម្ពាធដល់ស្ថានភាពវិនិយោគ និងតម្រូវការសកលជារួម ហើយបានសាយភាយដល់កម្ពុជា ជាពិសេស វិស័យដែលពឹងផ្អែកលើការនាំចេញ ជាក់ស្តែងវិស័យកាត់ដេរ

ដែលជាលទ្ធផលធ្វើឱ្យកំណើនវិស័យនេះមិនអាចសម្រេចបានតាមការគ្រោងទុក ដូចក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ វិស័យសំណង់ អចលនទ្រព្យ ក៏បន្តថមថយជាងការរំពឹងទុកដោយសារការមិនទាន់ងើបឡើងវិញនៃលំហូរវិនិយោគពីបរទេសដែលបម្រើឱ្យសំណង់ថ្លៃខ្ពស់ ដូចជាអគារពាណិជ្ជកម្ម និងខុនដូ ស្របពេលដែលសកម្មភាពសំណង់ និងចរន្តទិញ-លក់លំនៅឋានក៏បន្តមានភាពទ្រឹង។ យ៉ាងណាមិញ កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៣ ជារួម គឺត្រូវបានទ្រទ្រង់យ៉ាងសំខាន់ដោយការបន្តរក្សាចលនការនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ ទាំងផ្នែកផលិតកម្មបម្រើការនាំចេញ និងផ្នែកផលិតកម្មបម្រើទីផ្សារក្នុងស្រុក ។ វិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) និងសេវាគាំទ្រផ្សេងទៀត ក៏បន្តរក្សានិន្នាការកើនឡើង ហើយចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចឆ្នាំ២០២៣ផងដែរ។ វិស័យកសិកម្ម បន្តរក្សាបាននូវស្ថិរភាពកំណើនក្នុងអត្រា០,៩%ក្នុងឆ្នាំ២០២៣ គាំទ្រដោយកំណើនល្អនៃអនុវិស័យដំណាំ ខណៈដែលអនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទបន្តមានកំណើនទាប។ វិស័យឧស្សាហកម្ម មានកំណើនថមថយក្នុងរង្វង់៤,៣%ក្នុងឆ្នាំ២០២៣ ដោយសារការធ្លាក់ចុះនៃវិស័យកាត់ដេរ និងការបន្តកំណើនទាបនៃវិស័យសំណង់ ប៉ុន្តែត្រូវបានប៉ះប៉ូវមកវិញដោយកំណើនល្អប្រសើរនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ។ វិស័យសេវាកម្ម បន្តនិន្នាការកើនឡើងក្នុងអត្រា៧,២%គាំទ្រដោយការបន្តរក្សាបានចលនការនៃវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) និងសេវាកម្មគាំទ្រ និងកំណើនល្អនៃវិស័យលក់ដុំ-រាយ និងដឹកជញ្ជូននិងស្តុក ខណៈដែលវិស័យអចលនទ្រព្យបន្តមានកំណើនទាប។ ផ.ស.ស សម្រាប់មនុស្សម្នាក់បានកើនឡើងពី **២ ៣៨៣** ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២២ ដល់ប្រមាណ**២ ៥២០**ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣។ អត្រាអតិផរណា បានថមថយមកត្រឹមប្រមាណ**២,១%**ក្នុងឆ្នាំ២០២៣ ពីអត្រាប្រមាណ**៥,៣%**ក្នុងឆ្នាំ២០២២ ដោយសារការវិលត្រលប់ទៅរកប្រក្រតីភាពវិញនៃថ្លៃទំនិញអន្តរជាតិ ជាពិសេសថ្លៃប្រេង។

ដោយឡែក អត្រាប្តូរប្រាក់ត្រូវបានបន្តកើនឡើងដល់ប្រមាណ**៤ ១១០**រៀលក្នុងមួយដុល្លារអាម៉េរិកក្នុងឆ្នាំ២០២៣ ដោយសារការបន្តកើនឡើងថ្លៃរូបិយប័ណ្ណដុល្លារអាម៉េរិក ដែលជាបច្ច័យនៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវគោលនយោបាយសំខាន់ៗ រួមមាន៖ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាបន្ន ៣-បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រលប់ទៅរកកំណើនសក្តានុពលតាមរយៈការជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្រ្តនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ៤-ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជាសម្រាប់ត្រៀមឆ្លើយតបទៅនឹងគ្រោះអាសន្នដែលអាចកើតមានជាយថាហេតុ ៥-ដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រាក់ឧបត្ថម្ភមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមក្នុងកម្រិតសមស្របដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ ៦-ដំឡើងប្រាក់សោធន និងកាត់បន្ថយគម្លាតនៃប្រាក់សោធនរវាងអ្នកចូល

និវត្តន៍ចាស់ និងថ្មីជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងអតីតកងកម្លាំងប្រដាប់អាវុធ ៧-បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៨-ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅលើកកម្ពស់ការតភ្ជាប់ក្នុងសេដ្ឋកិច្ច គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព ៩-បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូចនិងមធ្យមតាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច និង១០-ធានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ព្រមទាំងការត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី៥។

នៅក្នុងឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បានខិតខំប្រឹងប្រែងអនុវត្តវិធានការប្រមូលចំណូលដែលនាំឱ្យចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ប្រមូលបាន **២៤ ៦៤១ ៤១៥,0**លានរៀល គឺមានការថយចុះ**0,៩%** ធៀបនឹងការអនុវត្តឆ្នាំ២០២២ ប៉ុន្តែបើគិតទាំងថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំណូលចរន្តឆ្នាំ២០២៣ អនុវត្តបានចំនួន**២៦ ៩១៥ ៦៦៥,៨** លានរៀល ត្រូវជា**១៥,២0%**នៃ ផ.ស.ស ហើយស្មើនឹង**៩៥,១%**នៃច្បាប់ហិរញ្ញវត្ថុ។

ការអនុវត្តនូវវិធានការលើកទឹកចិត្តដែលមានស្រាប់ និងការពង្រីកនូវវិសាលភាពក្នុងការលើកលែងឬបន្ធូរបន្ថយការបង់ពន្ធ ដើម្បីសម្រួលដល់បរិយាកាសធុរកិច្ច ជំរុញការវិនិយោគក្នុងស្រុក និងទ្រទ្រង់ចលនការនៃការងើបឡើងវិញនៃសេដ្ឋកិច្ច បានប៉ះទង្គិចមូលដ្ឋានប្រមូលចំណូលលើវិស័យមួយចំនួន។ ការប្រមូលចំណូលពន្ធដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាចំពោះពន្ធប្រយោលលើការនាំចូល និងពន្ធលើពាណិជ្ជកម្មអន្តរជាតិមានការធ្លាក់ចុះ ដោយសារស្ថានភាពនៃការនាំចូលទំនិញដែលមានលក្ខណៈប្រណីត និងមានអាករពិសេសខ្ពស់មានការថមថយ។ ជាក់ស្តែង ចំណូលពីការនាំចូលយានយន្ត ដែលជាប្រភពចំណូលដ៏សំខាន់នៃការប្រមូលពន្ធនេះ ត្រូវរងផលប៉ះទង្គិច ជាមួយនឹងការកើនឡើងនៃក្រុមហ៊ុនដំឡើងយានយន្តក្នុងស្រុក ការវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលទាំងនេះសុទ្ធសឹងផ្តល់នូវលក្ខខណ្ឌអនុគ្រោះពន្ធខ្ពស់។ បើទោះជាយ៉ាងនេះក្តី ចំណូលពីការនាំចូលតេលសិលា និងទំនិញចម្រុះបន្តមាននិន្នាការល្អស្របនឹងការរីកធំនៃផលិតកម្មក្នុងស្រុក និងភាពមមាញឹកនៃតម្រូវការប្រើប្រាស់របស់ប្រជាជន ព្រមទាំងការពង្រឹងការអនុវត្តវិធានការរដ្ឋបាល សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលចំណូល។ រីឯអគ្គនាយកដ្ឋានពន្ធដារ បានអនុវត្តយន្តការបុរេសកម្មក្នុងការកែទម្រង់រដ្ឋបាលសារពើពន្ធលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ ហើយបាននិងកំពុងអនុវត្តបច្ចេកវិទ្យាឌីជីថល ដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចពន្ធ ធ្វើឱ្យការប្រមូលចំណូលសារពើពន្ធបានល្អប្រសើរលើសច្បាប់ហិរញ្ញវត្ថុ។

ចំណាយសរុបថវិកាថ្នាក់ជាតិក្នុងឆ្នាំ២០២៣ អនុវត្តបាន៣៤ ៨៧៦ ៨៣៦,៥លានរៀល ស្មើនឹង៩២,០%នៃច្បាប់ហិរញ្ញវត្ថុ គឺមានការកើនឡើង១៦,៨% ធៀបនឹងការអនុវត្តឆ្នាំ២០២២។ ជាមួយនឹងភាពស្រាកស្រាន្តនៃស្ថានភាពពីវិបត្តិនៃជំងឺកូវីដ-១៩ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពកាត់សន្សំថវិកាពីកញ្ចប់អន្តរាគមន៍សង្គមសេដ្ឋកិច្ចដែលបានត្រៀមទុក។ ការខិតខំទាំងអស់នេះអាចសម្រេច

ទៅបាន ដោយសារការគ្រប់គ្រងថវិកាជាតិកាន់តែមានភាពរឹងមាំប្រកបដោយប្រសិទ្ធភាព ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានឆ្លងកាត់ជាដំណាក់កាលជាបន្តបន្ទាប់ ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និងជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងរក្សាលំនឹងសេដ្ឋកិច្ច ជួយសម្រួលបន្ទុកជីវភាពប្រជាជន ទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិផ្សេងៗ ដូចជា ការបន្តអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន និងការផ្ទុះឡើងនូវភាពចម្រូងចម្រាសនៅតំបន់សមុទ្រក្រហមជាដើម ព្រមទាំងបានរួមចំណែកបម្រើដល់ការស្តារសេដ្ឋកិច្ច និងជំរុញកំណើនជាបណ្តើរៗឡើងវិញផងដែរ។

លទ្ធផលទាំងនេះ បានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយភាពជាម្ចាស់ព្រមជាមួយនឹងឆន្ទៈនយោបាយមោះមុតអង់អាច ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ជារដ្ឋបុរស ជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម**នៃព្រះរាជាណាចក្រកម្ពុជា និងដោយសារតែរាជរដ្ឋាភិបាលមានច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដែលត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមអាទិភាពគោលនយោបាយសំខាន់ៗ។ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៧នៃរដ្ឋសភា** ប្រកបដោយគតិបណ្ឌិតឈ្លាសវៃ ថាមពលនិងស្វាហាប់ បានបន្តពូនជ្រុំសមិទ្ធផលដែលសម្រេចបានកន្លងមកកាន់តែមានភាពរឹងមាំល្អប្រសើរថែមទៀត។

ការគ្រប់គ្រងថវិកាឆ្នាំ២០២៣ គោរពបានទាំងកាលវសាន ទាំងខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលបានគិតគូរ និងរៀបចំឡើង ដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ និងប្រាក់ចំណូលរបស់ប្រជាជន ព្រមទាំងទ្រទ្រង់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច ពិសេសការបន្តអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ និងធានាដល់ជោគជ័យនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ និងការធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេមឆ្នាំ២០២៣ ក៏ដូចជាការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការសម្រេចឱ្យបាននូវគោលដៅសំខាន់ៗនៃ**កម្មវិធីនយោបាយ**របស់រាជរដ្ឋាភិបាលដែលត្រូវបានកំណត់នៅក្នុង**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤** និង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣**។ ថវិកាឆ្នាំ២០២៣ ក៏ត្រូវបានរៀបចំតម្រង់ទៅអនុវត្តបញ្ចប់សកម្មភាពអាទិភាពនៅសេសសល់របស់ក្រសួង ស្ថាប័ន ក៏ដូចជារបស់រាជរដ្ឋាភិបាលនៅក្នុងឆ្នាំចុងក្រោយនៃអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៦ ជាពិសេសកិច្ចការកែទម្រង់លើគ្រប់វិស័យ សំដៅកសាងមូលដ្ឋានគ្រឹះបន្ថែមក្នុងដំណើរការឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជាដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿង ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងជារដ្ឋអធិបតេយ្យមួយដ៏រឹងមាំដែលគោរពបានយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ។

រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានដាក់ចេញ ព្រមជាមួយនឹងការបន្តប្រកាន់ខ្ជាប់នូវអភិក្រមការងារ៥យ៉ាង គឺ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** ដើម្បីធានាឱ្យបាននូវសន្តិភាព ស្ថិរភាព ឯកភាពជាតិ ឯករាជ្យ និងអធិបតេយ្យជាតិ ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ក៏ដូចជាដើម្បីទ្រទ្រង់នូវដំណើរស្តារ និងជំរុញកិច្ចអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចកម្ពុជាឡើងវិញលើគ្រប់វិស័យនៅលើមាគ៌ាឈានឆ្ពោះទៅការកសាងសង្គមកម្ពុជាមួយដ៏រុងរឿងល្បាញល្បី។

សរុបមក ថវិកាឆ្នាំ២០២៣ អាចត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុងនិងក្រៅប្រទេស សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជាតាមគន្លងប្រក្រតីភាពថ្មី ហើយអាចប្រសិទ្ធនាមបានថាជា **ថវិកាវិស្តារកម្មចំគោលដៅដោយផ្តល់អាទិភាពទី១ដល់មនុស្ស ពិសេសលើសុខភាព ជីវភាព និងសមធម៌ ព្រមជាមួយនឹងអាទិភាពនៃការបន្តជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ក៏ដូចជាកិច្ចប្រឹងប្រែងសម្រេចឱ្យបានជាអតិបរមានូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។**

តាមការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងបទប្បញ្ញត្តិគតិយុត្តនានា។

អាជ្ញាធរសវនកម្មជាតិសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងស្ថាប័ននានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តវិធានការប្រមូលចំណូល និងគ្រប់គ្រងការចំណាយប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពឈ្លាសវៃ។ សមិទ្ធផលទាំងនេះ សរបញ្ជាក់ពីភាពត្រឹមត្រូវ ពីប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងផ្លែផ្កានៃកំណែទម្រង់មុតស្រួច និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ពិសេសកំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០២៣ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មទូទៅ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ដែលជានិច្ចកាលគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយ ដែលបានសហការគាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា តាមការធ្វើសវនកម្មនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រលាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ ចន្ទ ៨រោច ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០២៤

**អគ្គសវនករ**



**សោម គីមសួគ៌**

# មាតិកា

**ទំព័រ**


សេចក្តីសង្ខេប ........ ១

១.សេចក្តីផ្តើម ........ ៣

១.១.លក្ខណៈទូទៅ ........ ៣

១.២.ការអនុវត្ត និងដែនកំណត់ ........ ៤

១.៣.គោលបំណងនៃការផ្សព្វផ្សាយ ........ ៤

២.ការគ្រប់គ្រងថវិកា ........ ៥

២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ........ ៥

២.២.កិច្ចប្រតិបត្តិការថវិកា ........ ៥

៣.លទ្ធផលសវនកម្ម ........ ១០

៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ ........ ១០

៣.១.១.ការអនុវត្តការងាររបស់សាខាពន្ធដារខេត្ត ខណ្ឌមួយចំនួន ........ ១០

៣.១.២.ការអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈមួយចំនួន ........ ១១

៣.១.៣.ការប្រមូលចំណូលពីថ្លៃឈ្នួលអចលនទ្រព្យ ........ ១២

៣.១.៤.ការប្រមូលចំណូលពីការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលជលផល ........ ១៣

៣.១.៥.ការពុំទាន់កែសម្រួលការិយបរិច្ឆេទនៃការប្រមូលចំណូលសម្បទានដីសេដ្ឋកិច្ច ........ ១៣

៣.១.៦.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ........ ១៤

៣.១.៧.កង្វះខាតក្នុងការអនុវត្តនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូល ........ ១៥

៣.១.៨.វិធានការចំពោះអ្នកកាន់អាជ្ញាបណ្ណ(ក្រុមហ៊ុន)បញ្ញើឆាប់រហ័សអន្តរជាតិ ........ ១៥

៣.១.៩.ការកត់ត្រាចំណូលពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ........ ១៦

៣.១.១០.ការចុះកិច្ចបញ្ជិកាគណនេយ្យរបស់រជ្ជទេយ្យករចំណូលរង ........ ១៧

៣.១.១១.ការពុំបានធ្វើបញ្ជីតាមដានបំណុលលើក្រុមហ៊ុនដែលពុំបានបង់ឈ្នួលដី ........ ១៨

៣.១.១២.ការទូទាត់ប្រាក់បេសកកម្មឆ្លងឆ្នាំ ........ ១៩

៣.១.១៣.ការវាយតម្លៃ និងការប្រគល់ទទួល (សេវា) មិនបានចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុន ........ ១៩

៣.១.១៤.ការប្រគល់ទទួលការងារជួសជុលនិងការថែទាំពុំស្របតាមពេលវេលានិងទំហំការងារ ........ ២០

៣.១.១៥.ការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ ........ ២២

៣.១.១៦.ការរៀបចំគម្រោងនៃកិច្ចលទ្ធកម្មសាធារណៈពុំសមស្រប ........ ២២

៣.១.១៧.ការរៀបចំរបាយការណ៍សមិទ្ធកម្ម ........ ២៤

៣.១.១៨.ការពុំបានរៀបចំរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍របស់មន្ត្រីរាជការ និង
មន្ត្រីជាប់កិច្ចសន្យា ........................................................................................................ ២៥
៣.១.១៩.ការចំណាយ និងកត់ត្រាចំណាយលើការសាងសង់មិនទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់
សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ............................................................................. ២៦
៣.១.២០.ការចំណាយតាមនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយមុនការឯកភាពផ្តល់ធានា
ចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........................................................................... ២៧
៣.១.២១.ការរៀបចំតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ................. ២៩
៣.១.២២.ការស្នើសុំទូទាត់ប្រាក់បុរេប្រទានពុំមានសក្ខីបត្រភ្ជាប់មកជាមួយ ................................ ៣០
៣.១.២៣.ការកក់ប្រាក់ធានាការអនុវត្តនៅថ្ងៃកិច្ចសន្យាចូលជាធរមាន ........................................ ៣០
៣.១.២៤.កង្វះខាតក្នុងការចុះហត្ថលេខាលើក្រមសីលធម៌មុននឹងធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា ៣១
៣.១.២៥.ការស្នេនឯកសារចូលប្រព័ន្ធក្នុងដំណាក់កាលអនុវត្តនីតិវិធីធានាចំណាយនៅមិនទាន់ស្រប
តាមសេចក្តីណែនាំ ........................................................................................................... ៣២
៣.១.២៦.ការប្រគល់ទទួលគម្រោងលទ្ធកម្មទំនិញ សំណង់ និងសេវាពុំមានការអញ្ជើញចូលរួមពីតំណាង
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.......................................................................................... ៣៣
៣.១.២៧.ការប្រគល់ទទួលក្រោយគណៈកម្មការចូលរួម ................................................................ ៣៤
៣.១.២៨.ការអនុវត្តប្រព័ន្ធFMIS.................................................................................................. ៣៥
៣.១.២៩.ការកត់ត្រាសម្ភារបរិក្ខារព័ត៌មានវិទ្យាចូលក្នុងបញ្ជីសារពើភណ្ឌមិនទាន់បានត្រឹមត្រូវតាម
តម្លៃជាក់ស្តែង.................................................................................................................. ៣៧
៣.១.៣០.ការរៀបចំរបាយការណ៍ផ្គូផ្គងចំណាយថវិកាឆ្នាំ២០២៣................................................... ៣៨
៣.១.៣១.ការផ្ញើរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋានមកអាជ្ញាធរសវនកម្មជាតិ.................. ៣៩
៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ............................................................................ ៤០
៣.២.១.ការប្រកាសពន្ធឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ........................................................... ៤០
៣.២.២.ការបង់ចំណូលភាស៊ីផ្សារ................................................................................................... ៤០
៣.២.៣.ការពុំបានប្រមូលចំណូលពីប្រភពបំពុលបរិស្ថាន................................................................. ៤១
៣.២.៤.ការជំរុញការស្នើសុំលិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់ស្ថានីយប្រេងឥន្ធនៈ ....................... ៤២
៣.២.៥.ការរៀបចំកិច្ចបញ្ជិកាគណនេយ្យរបស់រដ្ឋទេយ្យករចំណូល.................................................. ៤៣
៣.២.៦.ការតម្រូវមានភ្ជាប់អាជ្ញាបណ្ណផ្លូវថ្នល់ក្នុងកិច្ចលទ្ធកម្មសាធារណៈ ...................................... ៤៤
៣.២.៧.ការស្នើសុំលិខិតអនុញ្ញាតសាងសង់ និងជួសជុលសំណង់អគាររបស់រដ្ឋ .............................. ៤៥
៣.២.៨.ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍បូកសរុបចំណូល ចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ . ៤៦
៣.២.៩.ការគ្រប់គ្រងអនុវត្តវិធានការតឹងទារបំណុលពន្ធ ................................................................. ៤៨
៤.ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម..................................................... ៤៩
៤.១.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ......................... ៤៩

៤.២.ការកាន់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន ........................................ ៥០
៤.៣.ក្រុមហ៊ុនសហគ្រាសមួយចំនួនតូចពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ ........................ ៥១
៤.៤.ការប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយ ........................................................................ ៥១
៤.៥.ការកត់ត្រាប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ........................................ ៥២
៤.៦.ការចេញវិញ្ញាបនប័ត្របញ្ចប់ការងារជូនអ្នកទទួលការ ............................................ ៥៣
៤.៧.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់ ............................................................ ៥៣
៤.៨.ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២៣ ................................................ ៥៤
៤.៩.ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើ ដែលទទួល
បានការអនុគ្រោះព្យួរ ឬលើកលែងពន្ធអាករនៅមានកម្រិត ........................................ ៥៥
៤.១០.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ .................................. ៥៦
៤.១១.ការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានមិនអស់លទ្ធភាព ........................................ ៥៧
៤.១២.ការប្រមូលចំណូលអំពីសេវាសាធារណៈផ្នែកអធិការកិច្ចការងារ .................................. ៥៧
៤.១៣.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ................................................ ៥៨
៤.១៤.ភាពយឺតយ៉ាវក្នុងការចុះបញ្ជីម៉ាក ........................................................................ ៥៩
៤.១៥.ការទូទាត់និងការកត់ត្រាចំណាយមិនទាន់អនុលោមពេញលេញតាមគោលការណ៍ហិរញ្ញវត្ថុ ៥៩
៤.១៦.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ................................................ ៦១
៤.១៧.អង្គភាពថវិកាមួយចំនួនពុំបានធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ ........................ **៦២**
៤.១៨.ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម ................................................................ ៦៣
៤.១៩.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងការងារជួសជុល
និងថែទាំអគារ ........................................................................................ ៦៣
៤.២០.ការអនុវត្តតួនាទីអង្គភាពថវិកាមិនទាន់ពេញលេញ .................................................. ៦៤
៤.២១.ការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ .. ៦៤
៤.២២.បំណុលពីការជួលដីទំនេរ និងដីមានអគារ .............................................................. ៦៦
៤.២៣.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ .................................. ៦៧
៤.២៤.ភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ............................ ៦៨
៥. សេចក្តីសន្និដ្ឋាន .................................................................................................. ៦៩

# សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

## ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **៣២ ៦៥២ ៩៥៥,៧**លានរៀល ស្មើនឹង **១៨,៤៤%** នៃផ.ស.ស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **៤,៤%** ហើយកើនឡើង **១,១%** ធៀបនឹងការអនុវត្តឆ្នាំ២០២២។ ចំណូលថវិកានេះ គឺជាសមិទ្ធផលដ៏ត្រចះត្រចង់ជាច្រើនឆ្នាំជាប់ៗគ្នាក្នុងការប្រមូលចំណូលពន្ធអាករ អាចសម្រេចទៅបានដោយសារ៖ (១)-ឆន្ទៈយ៉ាងមុតមាំក្នុងការបំពេញការងារប្រកបដោយវិជ្ជាជីវៈ និងការយកចិត្តទុកដាក់ខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ (២)-ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវផែនការសកម្មភាពប្រចាំឆ្នាំនៃយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រធនធានមនុស្សឆ្នាំ២០១៩-២០២៣របស់អគ្គនាយកដ្ឋានពន្ធដារ និង(៣)-ការបន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីប្រកបដោយស្មារតីបុរេសកម្មតាមរយៈការអភិវឌ្ឍ និងការធ្វើបច្ចុប្បន្នភាព បន្តវិនិយោគ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញ និងបង្កើនអនុលោមភាពសារពើពន្ធ និងលើកកម្ពស់គុណភាពសេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែល្អប្រសើរ រហ័ស សាមញ្ញ និងងាយស្រួល។ ស្របគ្នានេះដែរ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានអនុវត្តនូវកំណែទម្រង់ទំនើបកម្មរដ្ឋបាលគយនិងរដ្ឋាករ ដោយយកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស កែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារគយនិងរដ្ឋាករ និងកសាងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ។ ទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាខិតខំយកចិត្តទុកដាក់អនុវត្តគោលនយោបាយ និងប្រសិទ្ធភាពនៃការអនុវត្តចំណូលគយនិងរដ្ឋាករតាមយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ យុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយនិងរដ្ឋាករ២០១៩-២០២៣ និងឯកសារគោលនយោបាយពាក់ព័ន្ធនានា ការទប់ស្កាត់និងបង្ការអំពើរត់ពន្ធ និងពង្រឹងប្រសិទ្ធភាពនៃការបង្ក្រាបបទល្មើស។ល។ ដោយឡែក ចំណូលមិនមែនសារពើពន្ធ ត្រូវបានទ្រទ្រង់ដោយការបន្តងើបឡើងវិញនៃចំណូលពីវិស័យទេសចរណ៍ រួមមានផលទុនពីសកម្មភាពទេស

ចរណ៍ អាកាសស្ថានទូត និងចំណូលពីផលទុនអាកាសចរស៊ីវិល ខណៈចំណូលពីវិស័យប្រៃសណីយ៍និងទូរគមនាគមន៍បន្តសម្រេចបានលទ្ធផលល្អ។ បន្ថែមលើនេះ មូលដ្ឋានប្រភពចំណូលផ្សេងៗ រួមមាន៖ ចំណូលពីវិស័យរ៉ែ និងចំណូលពីអាជ្ញាបណ្ណ ក៏ចាប់លេចចេញនូវសក្តានុពលដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ស្ថាប័ន និងការដាក់ចេញនូវវិធានការតឹងរឹងក្នុងការគ្រប់គ្រងលើអនុលោមភាពរបស់ប្រតិបត្តិករដែលទទួលបន្ទុកក្នុងការជំរុញ និងការតឹងទារបំណុល។ តាមលទ្ធផលនៃការធ្វើសវនកម្មលើចំណូលបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត ដូចមានបង្ហាញនៅក្នុងចំណុចទី៣.លទ្ធផលនៃការធ្វសើវនកម្ម។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **៣៤ ៨៧៦ ៨៣៦,៥** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៨,0%** ហើយស្មើនឹង**១៩,៧0%** នៃផ.ស.ស ហើយកើនឡើង**១៦,៨%** ធៀបនឹងការអនុវត្តឆ្នាំ ២០២២។ ចំណាយថវិកានេះ គឺដោយសារភាពស្រាកស្រាន្តនៃស្ថានភាពពីវិបត្តិនៃជំងឺកូវីដ-១៩ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពកាត់សន្សំថវិកាពីកញ្ចប់អន្តរាគមន៍សង្គមសេដ្ឋកិច្ចដែលបានត្រៀមទុក។ ការខិតខំទាំងអស់នេះអាចសម្រេចទៅបាន ដោយសារការគ្រប់គ្រងថវិកាជាតិកាន់តែមានភាពរឹងមាំប្រកបដោយប្រសិទ្ធភាព ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានឆ្លងកាត់ជាដំណាក់កាលជាបន្តបន្ទាប់ ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និងជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងរក្សាលំនឹងសេដ្ឋកិច្ច ជួយសម្រួលបន្ទុកជីវភាពប្រជាជន ទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិផ្សេងៗ ដូចជា ការបន្តអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន និងការផ្ទុះឡើងនូវភាពចម្រូងចម្រាសនៅតំបន់សមុទ្រក្រហមជាដើម ព្រមទាំងបានរួមចំណែកបម្រើដល់ការស្តារសេដ្ឋកិច្ចនិងជំរុញកំណើនជាបណ្តើរៗឡើងវិញផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវគោលនយោបាយសំខាន់ៗ រួមមាន៖ ១-បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២-បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាបន្ន ៣-បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រលប់ទៅរកកំណើនសក្តានុពលតាមរយៈការជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ៤-ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជាសម្រាប់ត្រៀមឆ្លើយតបទៅនឹងគ្រោះអាសន្នដែលអាចកើតមានជាយថាហេតុ ៥-ដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធព្រមទាំងប្រាក់ឧបត្ថម្ភមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមក្នុងកម្រិតសមស្របដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ ៦-ដំឡើងប្រាក់សោធន និងកាត់បន្ថយគម្លាតនៃប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មីជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងអតីតកងកម្លាំងប្រដាប់អាវុធ ៧-បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៨-ជំរុញ

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅលើកកម្ពស់ការតភ្ជាប់ក្នុងសេដ្ឋកិច្ច គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព ៩-បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូចនិងមធ្យមតាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច និង១០-ធានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ព្រមទាំងការត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី៥។ ជាមួយនឹងការអនុវត្តចំណាយថវិកានេះបានល្អប្រសើរនេះ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនតូចដូចមានបង្ហាញនៅក្នុងចំណុចទី៣.លទ្ធផលនៃការធ្វើសវនកម្ម។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន**៥ ៨៦៦ ០៦២,០** លានរៀល ស្មើនឹង **៩៥,០%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន**៦ ១៧៣ ៤១៥,០** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន **៣០៧ ៣៥៣,០** លានរៀល។

## ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន**៤ ១៨១ ៩២៦,១** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៥,៦%** និងចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្ត អនុវត្តបានចំនួន**៤ ១៧៣ ៣៥៩,២** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៥,៨%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តចំនួន**៦៥៩ ២៩៤,៨** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៣,៦%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានចំនួន**៦៥០ ១១១,០** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៥,០%**។ រីឯចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តចំនួន**១ ២៨៧ ២៣៤,៨** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៤,៩%** និងចំណាយថវិការបស់រដ្ឋបាលឃុំសង្កាត់ អនុវត្តបានចំនួន**១ ១០៧ ៨២៦,៥**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុ**៩,៧%**។ ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់មួយចំនួនដូចមានបង្ហាញនៅក្នុងចំណុចទី៣.លទ្ធផលនៃការធ្វើសវនកម្ម។

# ១. សេចក្តីផ្តើម

## ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ច អនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជិកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រងការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួងស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់

និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។ លើសពីនេះទៀត អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

## ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០២៤ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗប្រកបដោយគុណភាព ទាន់ពេលវេលា និងជឿទុកចិត្តបាន។ សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន១០៣ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣.លទ្ធផលនៃការធ្វើសវនកម្ម ដើម្បីផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

## ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាតាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែប្រសើរឡើងថែមទៀត។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០២៣ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- អនុក្រឹត្យលេខ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

### ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០២៣ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

## ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៣ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូល** | **៣៤ ១៦៥ ១៦៣,0** | **៣២ ៦៥២ ៩៥៥,៧** | **៩៥,៦%** |
| -ចំណូលចរន្ត | ២៥ ៥៦៤ ៤២៨,0 | ២៤ ៦៤១ ៤១៥,0 | ៩៦,៤% |
| -ចំណូលមូលធន | ២ ៤២៧ ៣២០,0 | ២ ១៤៥ ៤៧៨,៧ | ៨៨,៤% |
| +ចំណូលមូលធនក្នុងប្រទេស | ១ ១៤៤ ៨១២,0 | ២៨០ ៤១៤,៥ | ២៤,៥% |
| +ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | ១ ២៨២ ៥០៨,0 | ១ ៨៦៥ ០៦៤,២ | ១៤៥,៤% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយ ហិរញ្ញប្បទានក្រៅប្រទេស | ៦ ១៧៣ ៤១៥,0 | ៥ ៨៦៦ ០៦២,0 | ៩៥,0% |
| **II. សរុបចំណាយ** | **៣៧ ៩១២ ២៤៩,២** | **៣៤ ៨៧៦ ៨៣៦,៥** | **៩២,0%** |
| -ចំណាយចរន្ត | ២២ ១៤៧ ៩៧៦,២* | ២១ ៣៦៧ ២២៦,៣ | ៩៦,៥% |
| -ចំណាយមូលធន | ៩ ៥៩០ ៨៥៨,0 | ៧ ៦៤៣ ៥៤៨,៣ | ៧៩,៧% |
| +វិនិយោគសាធារណៈដោយហិរញ្ញប្បទាន ក្នុងប្រទេស | ៧ ៧៣០ ៩៧១,0 | ៥ ៩៨៥ ៩៩៣,១ | ៧៧,៤% |
| +ការទូទាត់ការខ្ចី | ១ ៨៥៩ ៨៨៧,0 | ១ ៦៥៧ ៥៥៥,២ | ៨៩,១% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយ ហិរញ្ញប្បទានក្រៅប្រទេស | ៦ ១៧៣ ៤១៥,0 | ៥ ៨៦៦ ០៦២,0 | ៩៥,0% |

**<u>កំណត់សម្គាល់:</u>** កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

(*)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន១ ៣០៨ ៥៥១,២លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

## ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

## ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៣ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៤ ៤៣០ ១៨៣,២** | **៤ ១៨១ ៩២៦,១** | **៩៤,៤%** |
| -ចំណូលចរន្ត | ៤ ៤៣០ ១៨៣,២ | ៤ ១៨១ ៩២៦,១ | ៩៤,៤% |
| • ចំណូលសារពើពន្ធ | ២ ១៧២ ៣៥០,០ | ១ ៩៣៨ ៦៨៤,៥ | ៨៩,២% |
| • ចំណូលពុំមែនសារពើពន្ធ | ២៨២ ៣១៤,០ | ៣២២ ៥៦៣,០ | ១១៤,៣% |
| • ចណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១ ៨៥៤ ១៨១,២* | ១ ៨០៦ ៥៤២,៩ | ៩៧,៤% |
| • ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១២១ ៣៣៨,០ | ១១៤ ១៣៥,៧ | ៩៤,១% |
| **II. សរុបចំណាយថវិកា** | **៤ ៤៣០ ១៨៣,២**** | **៤ ១៧៣ ៣៥៩,២** | **៩៤,២%** |
| -ចំណាយចរន្ត | ៣ ៤០៥ ៥៧១,៦ | ៣ ៣២៩ ១១៧,៦ | ៩៧,៨% |
| -ចំណាយមូលធន | ១ ០២៤ ៦១១,៦ | ៨៤៤ ២៤១,៦ | ៨២,៤% |

<u>**កំណត់សម្គាល់:**</u> កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

---

* តួលេខនេះបូកបញ្ចូលចំណូលរួមមាន៖ (១)-ការបន្ថែមឥណទានថវិកា ផ្តល់ជូនមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត ចំនួន ៨៤២,០លានរៀល សម្រាប់បើកប្រាក់បៀវត្សជូនមន្ត្រីរាជការដែលបានផ្ទេរចូលនៅក្នុងឆ្នាំ២០២២ និង២០២៣ (២)-ការបន្ថែមឥណទានថវិកាផ្តល់ជូនសាលាខេត្តសៀមរាបចំនួន៧២០,០លានរៀលពីមូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ និង(៣)-និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមចំនួន៩៩២ ៣៧១,២លានរៀល សម្រាប់ទូទាត់ជម្រះបុរេប្រទានចំណាយអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលរាជធានី ខេត្ត។

** តួលេខនេះបូកបញ្ចូលនូវការបន្ថែមឥណទានថវិកាផ្តល់ជូនរដ្ឋបាលរាជធានី ខេត្តចំនួន ៩៩៣ ៩៣៣,២លានរៀល ក្នុងនោះ៖ (១)-ការបន្ថែមឥណទានថវិកាផ្តល់ជូនមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពតចំនួន ៨៤២,០លានរៀលសម្រាប់ចំណាយបន្ទុកបុគ្គលិក (២)-និយ័តកម្មឥណទានថវិកាថ្នាក់ជាតិ សម្រាប់ការបន្ថែមឥណទានថវិកាផ្តល់ជូនសាលាខេត្តសៀមរាបចំនួន ៧២០លានរៀល ពីមូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ និង(៣)-និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមចំនួន៩៩២ ៣៧១,២ លានរៀល សម្រាប់ទូទាត់ជម្រះបុរេប្រទានចំណាយអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលរាជធានី ខេត្ត។

## ខ៧/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៣ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៦៨៤ ២៣២,៧** | **៦៥៩ ២៩៤,៨** | **៩៦,៤%** |
| -ចំណូលមិនមែនសារពើពន្ធ | ៣៩ ២៤៤,៩[*] | ៣២ ០៣៦,៥ | ៨១,៦% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ៦៣១ ៤៤៥,៨ | ៦២១ ៥៦៧,៨ | ៩៨,៤% |
| • ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក | ៤៧៧ ១៤១,០[**] | ៤៧១ ៩៦៥,២ | ៩៨,៩% |
| • ការប្រគល់មុខងារអប់រំ | ១៥៤ ៣០៣,៨[***] | ១៤៩ ៦០២,៦ | ៩៧,០% |
| -ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៣ ៥៤៣,០ | ៥ ៦៩០,៥ | ៤២,០% |
| **II. សរុបចំណាយថវិកា** | **៦៨៤ ២៣២,៧**[****] | **៦៥០ ១១១,០** | **៩៥,០%** |
| -ចំណាយចរន្ត | ៦៨៤ ២៣២,៧ | ៦៥០ ១១១,០ | ៩៥,០% |
| -ចំណាយមូលធន | - | - | - |

<u>**កំណត់សម្គាល់:**</u> កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុកឆ្នាំ២០២៣ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

(*) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន២៦ ២៨២,៩លានរៀល ក្នុងនោះ៖ (១)-ឥណទានថវិកាបន្ថែមចំនួន២០៨,៩លានរៀល ដោយចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ សម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត (២)-ឥណទានថវិកាចំនួន៨ ០០០,០លានរៀល ថវិកាសេវាអនាម័យបរិស្ថានសម្រាប់រដ្ឋបាលក្រុងគោលដៅចំនួន២៨ (៣)-ឥណទានថវិកាបន្ថែមចំនួន១៧ ៦៦២,០លានរៀល ចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្ត៤% ជូនរដ្ឋបាលក្រុង ស្រុក (៤)-ឥណទានថវិកាបន្ថែមចំនួន៤១០,០លានរៀល ចំណូលពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ។

(**) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន៧ ០០០,០លានរៀល ថវិកាពីមូលនិធិវិនិយោគរសម្រាប់ចំណាយអភិវឌ្ឍន៍។

(***) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន៣ ៨១០,៤លានរៀល សម្រាប់អនុវត្តមុខងារអប់រំនៅខេត្តបាត់ដំបង។

(****) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន២៧ ០៩៣,៣លានរៀល ក្នុងនោះ៖ (១)-ឥណទានថវិកាបន្ថែមចំនួន២០៨,៩លានរៀល ដោយចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយសម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត (២)-ឥណទានថវិកាបន្ថែមចំនួន៨ ០០០,០លានរៀល ថវិកាសេវាអនាម័យបរិស្ថានសម្រាប់រដ្ឋបាលក្រុងគោលដៅទាំង២៨ (៣)-ឥណទានថវិកាបន្ថែមចំនួន១៧ ៦៦៤,០លានរៀល ចំណូលសារពើពន្ធចែករំលែកពីរដ្ឋបាលខេត្ត៤% ជូនរដ្ឋបាលក្រុង ស្រុក (៤)-ឥណទានថវិកាបន្ថែមចំនួន៤១០,០លានរៀល ចំណូលពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ (៥)-ឥណទានថវិកាបន្ថែមចំនួន៧ ០០០,០លានរៀល ថវិកាពីមូលនិធិវិនិយោគសម្រាប់ចំណាយអភិវឌ្ឍន៍ និង(៦)-ឥណទានថវិកាបន្ថែមចំនួន៣ ៨១០,៤លានរៀល សម្រាប់អនុវត្តមុខងារអប់រំនៅខេត្តបាត់ដំបង។

### ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ឆ្នាំ២០២៣ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **១ ២២៦ ៨៣៣,១** | **១ ២៨៧ ២៣៤,៨** | **១០៤,៩%** |
| -ចំណូលមិនមែនសារពើពន្ធ | 0 | ៦០ ៤០១,៧ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប | ៩៧៤ ៩២៣,០ | ៩៧៤ ៩២៣,០ | ១០០,០% |
| -អតិរេកឆ្នាំ២០២២ | ២៥១ ៩១០,១* | ២៥១ ៩១០,១ | ១០០,០% |
| **II. សរុបចំណាយថវិកា** | **១ ២២៦ ៨៣៣,១** | **១ ១០៧ ៨២៦,៥** | **៩០,៣%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ៦៦ ០៦២,៥ | ៥៦ ៧០៣,១ | ៨៥,៨% |
| - ចំណាយសង្កាត់ចំណុះក្រុង | ១០៨ ៤៤៩,២ | ៩០ ១៣៥,៧ | ៨៣,១% |
| -ចំណាយឃុំ | ១ ០៥២ ៣២១,៤ | ៩៦០ ៩៨៧,៧ | ៩១,៣% |

**<u>កំណត់សម្គាល់:</u>** កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២៣ ដកស្រង់ចេញពីច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន២៥១ ៩១០,១លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

## ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១.ការអនុវត្តការងាររបស់សាខាពន្ធដារខេត្ត ខណ្ឌមួយចំនួន

ដើម្បីបង្កើនប្រសិទ្ធភាព និងការទទួលខុសត្រូវ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំនិយាមនីតិវិធីប្រតិបត្តិការងាររបស់សាខាពន្ធដារខេត្ត ខណ្ឌដែលបានអនុម័តដោយអគ្គនាយកដ្ឋានពន្ធដារ។ និយាមនីតិវិធីប្រតិបត្តិការងារបានកំណត់នូវការទទួលខុសត្រូវសំខាន់ៗដូចជាៈ ការិយាល័យរដ្ឋបាល ត្រូវប្រមូលទិន្នន័យ និងព័ត៌មានរបស់អ្នកជាប់ពន្ធពីអង្គភាពពន្ធដារនានា ដើម្បីកសាងកម្មវិធីសវនកម្ម រៀបចំកម្មវិធីសវនកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំដោយផ្អែកលើការកំណត់ហានិភ័យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសវនកម្ម គ្រប់គ្រងលិខិតស្នាម និងតាមដាន និងឆ្លើយតបលិខិត, ការិយាល័យសេវាអ្នកជាប់ពន្ធផ្តល់សេវាពាក់ព័ន្ធកាតព្វកិច្ចពន្ធដារជូនអ្នកជាប់ពន្ធលើការផ្តល់ប្រឹក្សា និងការផ្តល់ព័ត៌មាន និងទទួលបន្ទុកក្នុងការប្រមូលពន្ធ មានជាអាទិ៍ៈ ពន្ធប្រថាប់ត្រាលើកិច្ចសន្យា ពន្ធអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ និងចុះបញ្ជី, ការិយាល័យចាត់ចែងលិខិតប្រកាសទទួល និងពិនិត្យផ្ទៀងផ្ទាត់លិខិតប្រកាសសារពើពន្ធពីអ្នកជាប់ពន្ធ ដើម្បីធានាថា លិខិតប្រកាសសារពើពន្ធត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស និងគណនាបានត្រឹមត្រូវ និងធ្វើសវនកម្មលើលិខិតស្នាមជាដើម, ការិយាល័យបំណុលចុះជួប និងជូនដំណឹងដល់អ្នកជំពាក់បំណុលពន្ធ និងស្វែងរក និងទទួលព័ត៌មានហិរញ្ញវត្ថុថ្មីៗពីអង្គភាពពាក់ព័ន្ធនានា ដើម្បីវិភាគអំពីលទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទូទាត់បំណុលពន្ធ និងការិយាល័យសវនកម្មពន្ធធ្វើសវនកម្មលើឯកសារ និងសវនកម្មមានកម្រិតលើអ្នកជាប់ពន្ធឱ្យបានទាន់ពេលប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាពស្របតាមផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ និងដោយអនុលោមតាមនីតិវិធីសវនកម្មជាធរមាន។ល។

តាមការធ្វើសវនកម្មនៅសាខាពន្ធដារខេត្ត និងខណ្ឌមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការអនុវត្តការងាររបស់ការិយាល័យជំនាញរបស់សាខាពន្ធដារខេត្ត និងខណ្ឌមួយចំនួនពុំទាន់បានពេញលេញទាំងស្រុងតាមនិយាមនីតិវិធីប្រតិបត្តិការងារនៅឡើយ ដោយការិយាល័យរដ្ឋបាលមួយចំនួន ការិយាល័យសេវាមួយចំនួន ការិយាល័យចាត់ចែងលិខិតប្រកាសមួយចំនួន ការិយាល័យបំណុលមួយចំនួន និងការិយាល័យសវនកម្មពន្ធមួយចំនួន ពុំទាន់បានបំពេញមុខងារពេញលេញ និងមិនមានមន្ត្រីគ្រប់គ្រាន់ ដើម្បីឆ្លើយតបតាមតម្រូវការការងារដូចមានកំណត់ក្នុងនិយាមនីតិវិធីប្រតិបត្តិការងារនៅឡើយទេ។

កង្វះខាតនេះ អាចនាំឱ្យការអនុវត្តការងារតាមការិយាល័យជំនាញនីមួយៗនៅមានកម្រិត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំឱ្យអគ្គនាយកដ្ឋានពន្ធដារពិនិត្យការងារខាងលើបន្ថែមទៀត ដើម្បីឱ្យអង្គភាពពន្ធដារតាមបណ្តាខេត្ត និងខណ្ឌមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាកាន់តែល្អថែមទៀត។

តបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តតួនាទីភារកិច្ចរបស់អង្គភាពនីមួយៗស្របតាមនិយាមនីតិវិធីប្រតិបត្តិការងារ (SOP)

មិនអាចបានពេញលេញទាំងស្រុងនោះទេ តែងតែមានភាពចន្លោះប្រហោងតិចតួចខ្លះ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបន្តពង្រឹងការអនុវត្តការងាររបស់អគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធទាំងអស់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិសូមទទួលយកការឆ្លើយតបនេះ។ អាជ្ញាធរសវនកម្មជាតិជឿជាក់ថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តពង្រឹងការអនុវត្តការងាររបស់អគ្គនាយកដ្ឋានពន្ធដារ និងអង្គភាពពាក់ព័ន្ធទាំងអស់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នៅពេលខាងមុខ។

**៣.១.២.ការអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈមួយចំនួន**

ប្រកាសរួមលេខ៣៣៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រង់ប្រការ១បានចែងថា "អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ ដូចជា៖ សេវាសាធារណៈផ្នែកសុវត្ថិភាព និងសុខភាពការងារ(OSH) ផ្នែកអធិការកិច្ចការងារ ផ្នែកវិវាទការងារ ផ្នែកការងារកុមារ ផ្នែកហ្វឹកហ្វឺនកូនជាង ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្នែកមុខរបរ និងហត្ថពលកម្ម ផ្នែកកម្មករនិយោជិតជាជនបរទេស និងផ្នែកសេវារកការងារឱ្យធ្វើ។

តាមការពិនិត្យរបាយការណ៍អនុវត្តចំណូលប្រចាំឆ្នាំ២០២៣ របស់រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៣ ក្រសួងពុំបានប្រមូលចំណូលពីកម្រៃសេវាសាធារណៈចំនួន១០ ពាក់ព័ន្ធនឹងផ្នែកការងារកុមារ (លេខរៀង៦១ និង៦២), ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (លេខរៀង៦៩, ៧២, ៧៥-៧៩) និងផ្នែកកម្មករនិយោជិតជាជនជាតិបរទេស (លេខរៀង៩០)។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរអនុវត្តប្រមូលចំណូលទាំង១០ ខាងលើឱ្យស្របតាមប្រកាសរួមខាងលើឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់។

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបំភ្លឺដូចខាងក្រោម៖

១. **សេវាសាធារណៈផ្នែកការងារកុមារ៖** ជាសេវាតាមតម្រូវការ ដោយក្នុងឆ្នាំ២០២៣ពុំមានរោងចក្រ សហគ្រាសស្នើសុំចុះបញ្ជីកាសៀវភៅចុះបញ្ជីកានាមក្មេង និងការផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិត វ័យអាយុចាប់ពី១២ឆ្នាំ ដល់១៥ឆ្នាំទេ។

២. **សេវាសាធារណៈផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖** ក៏ជាសេវាតាមតម្រូវការ ហើយក្នុងឆ្នាំ២០២៣ពុំមានការស្នើសុំប្រើប្រាស់សេវានេះឡើយ។ សេវាខាងលើត្រៀមកែសម្រួលដើម្បីឱ្យសមស្របនឹងការអនុវត្តបច្ចុប្បន្ន។

៣. **សេវាសាធារណៈផ្នែកកម្មករនិយោជិតជនបរទេស៖** ជាក់ស្តែងសេវានេះពុំមានការស្នើសុំពីកម្មករ និយោជិតជាជនបរទេសនោះទេ។ ម្យ៉ាងវិញទៀត លើបណ្ណការងារជនបរទេសមានសុពលភាពប្រើប្រាស់១ឆ្នាំ ព្រមទាំងមាន QR កូដសម្គាល់អាចថតទុកដើម្បីប្រើប្រាស់បាន។

ទោះបីជាបែបនេះក្តី ក្រសួងសូមទទួលយកអនុសាសន៍ខាងលើ និងខិតខំពង្រឹងយន្តការពិនិត្យតាមដានការអនុវត្តកិច្ចការងារនេះ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៣.ការប្រមូលចំណូលពីថ្លៃឈ្នួលអចលនទ្រព្យ**

ឧបសម្ព័ន្ធបច្ចុប្បន្នភាពនៃកិច្ចសន្យាជួលអតីតទីតាំងសាលមហោស្រពទន្លេបាសាក់ បំពេញបន្ថែមលើខ្លឹមសារកិច្ចព្រមព្រៀងចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ រវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ត្រង់ប្រការ៦ ចំណុចទី៦.២ គ្រេទី២បានចែងថា "ពីឆ្នាំទី១៦ ដល់ឆ្នាំទី២០ គិតចាប់ពីខែមីនា ឆ្នាំ២០២១ ដល់ខែកុម្ភៈ ឆ្នាំ២០២៦ ត្រូវបង់ថ្លៃឈ្នួលចំនួន ២៨៩ ៣៥៥ (ពីររយប៉ែតសិបប្រាំបួន បីរយហាសិបប្រាំ) ដុល្លារអាម៉េរិក" និងចំណុចទី៦.៣បានចែងថា "ថ្លៃឈ្នួលដូចមានកំណត់ក្នុងចំណុចទី៦.២នៃប្រការ៦ ភាគី(ខ)ត្រូវបង់មួយឆ្នាំម្តងៗឱ្យបានទៀងទាត់យ៉ាងយូរត្រឹមសប្តាហ៍ទី២ (មិនគិតថ្ងៃឈប់សម្រាក) ក្នុងខែមីនានៃឆ្នាំនីមួយៗជាកំហិត"។

តាមការពិនិត្យលើឧបសម្ព័ន្ធបច្ចុប្បន្នភាពនៃកិច្ចសន្យាជួលអតីតទីតាំងសាលមហោស្រពទន្លេបាសាក់ តារាងចំណូលថ្លៃជួលរោងចក្រ សហគ្រាស អចលនវត្ថុ និងដោះដូរប្រចាំខែនីមួយៗ និងប្រចាំឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ភាគីក្រុមហ៊ុនបានបង់ថ្លៃឈ្នួលខាងលើនៅក្នុងខែតុលា ឆ្នាំ២០២៣ ដែលមានចំនួនទឹកប្រាក់ ២៨៩ ៣៥៥ ដុល្លារអាម៉េរិក។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរដាក់លិខិតទារថ្លៃឈ្នួលពីភាគីក្រុមហ៊ុនជាបន្តបន្ទាប់ទៀត និងផ្តល់ព័ត៌មានជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីបញ្ហានេះដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជួយសម្របសម្រួលក្នុងការទារថ្លៃឈ្នួលនោះឱ្យស្របតាមកិច្ចសន្យាជួលខាងលើ។

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានបំភ្លឺចំពោះអតីតសាលមហោស្រពទន្លេបាសាក់ ដូចខាងក្រោម៖

- ចំពោះជំពាក់បំណុលនៅឆ្នាំ២០២២ ក្រសួងបានធ្វើលិខិតទារបំណុលលេខ ៥៨៩ សណ. គហ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ សុំឱ្យក្រុមហ៊ុនទូទាត់បំណុលថ្លៃឈ្នួលចំនួន១៤៣ ០៨៤,១១ ដុល្លារអាម៉េរិក សម្រាប់ឆ្នាំ២០២២។
- ចំពោះជំពាក់បំណុលនៅឆ្នាំ២០២៣ ក្រសួងបានធ្វើលិខិតទារបំណុលលេខ១០៣ សណ. គហ ចុះថ្ងៃទី២១ខែមីនា ឆ្នាំ២០២៣ ស្នើឱ្យក្រុមហ៊ុនទូទាត់ថ្លៃឈ្នួលសរុបចំនួន ៤៣២ ៤៣៩,១១ ដុល្លារអាម៉េរិក ក្នុងនោះបំណុលឆ្នាំ ២០២២ ចំនួន ១៤៣ ០៨៤,១១ ដុល្លារអាម៉េរិក និងឆ្នាំ២០២៣ ចំនួន២៨៩ ៣៥៥ ដុល្លារអាម៉េរិក ក្រុមហ៊ុនបានបង់ឆ្នាំ២០២៣រួចហើយ ប៉ុន្តែពន្យារដល់ខែតុលា ឆ្នាំ២០២៣ ទើបបានទូទាត់ ចំណែកបំណុលឆ្នាំ២០២២ ចំនួន ១៤៣ ០៨៤,១១ ដុល្លារអាម៉េរិក ពុំទាន់បានបង់នៅឡើយ។
- ចំពោះឆ្នាំ២០២៤នេះ ក្រសួងបានធ្វើលិខិតទារបំណុលលេខ៣៩ សណ.គហចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ សម្រាប់ការជំពាក់ថ្លៃឈ្នួលឆ្នាំ២០២២ ចំនួន ១៤៣ ០៨៤,១១ ដុល្លារអាម៉េរិក និងបានធ្វើលិខិតជូនថ្នាក់ដឹកនាំរួចហើយ ដើម្បីចុះហត្ថលេខាក្នុងការទារ

បំណុលសម្រាប់ឆ្នាំ២០២២ និងឆ្នាំ២០២៤។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.៤.ការប្រមូលចំណូលពីការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលជលផល**

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ជំពូកទី៤ មាត្រា៣៣ បន្ទាត់ទី៦ បានចែងថា "ការគ្រោងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ ត្រូវមានមូលដ្ឋានគ្រោងគិតចំណូលទៅតាមមុខចំណូលនីមួយៗឱ្យបានច្បាស់លាស់ ដោយផ្អែកលើបញ្ជីស្ថិតិបច្ចុប្បន្នភាព បញ្ជីសម្រង់ទិន្នន័យ និងស្ថានភាពនៃការអនុវត្តចំណូល និងបំណុលនាឆ្នាំកន្លងមក ការរំពឹងលើប្រភពចំណូលថ្មី តម្លៃសេវាសាធារណៈ..." ។

តាមការពិនិត្យតារាងឈ្មោះក្រុមហ៊ុនដែលទទួលបានលិខិតអនុញ្ញាតនាំចូល និងក្រុមហ៊ុនទទួលបានលិខិតអនុញ្ញាតនាំចូលឆ្លងកាត់ផលិតផលជលផលរបស់រដ្ឋបាលជលផល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៣ រដ្ឋបាលជលផលបានចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនចំនួន២៩ ក្នុងនោះក្រុមហ៊ុនចំនួន២៦នាំចូលផលិតផលជលផលចំនួន៣១ ៨៦៥តោន និងក្រុមហ៊ុនចំនួន៣នាំចូលឆ្លងកាត់ផលិតផលជលផលចំនួន៣ ៣០០តោន ដោយពុំមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នៃប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនោះទេ។

កត្តានេះ នាំឱ្យរដ្ឋខាតបង់ចំណូលពីការផ្តល់សេវាសាធារណៈ ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរធ្វើបច្ចុប្បន្នភាពតារាងឧបសម្ព័ន្ធនៃប្រកាសរួមខាងលើ។

ចំពោះចំណុះនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាពតាមខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ និងខិតខំព្យាយាមកែលម្អនូវចំណុចខ្វះខាតទាំងឡាយដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.១.៥. ការពុំទាន់បានកែសម្រួលការិយបរិច្ឆេទនៃការប្រមូលចំណូលសម្បទានដីសេដ្ឋកិច្ច**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ត្រង់មាត្រា១១ បានចែងថា "ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពុំទាន់បានកែសម្រួលការិយបរិច្ឆេទនៃការប្រមូលចំណូលសម្បទានដីសេដ្ឋកិច្ចឱ្យស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចាប់ពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៅឡើយទេ។ ក្រសួងកសិកម្ម រុក្ខា

ប្រមាញ់ និងនេសាទ គួរកែសម្រួលការិយបរិច្ឆេទប្រមូលចំណូលសម្បទានដីសេដ្ឋកិច្ចឱ្យស្របតាមច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន ទទួលយកនូវខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ និងធ្វើការកែលម្អនូវចំណុចខ្វះខាតទាំងឡាយដែល បានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងអនុវត្តឱ្យបានត្រឹមត្រូវតាមព្រះរាជក្រមខាងលើ។

**៣.១.៦.ភាពយឺតយ៉ាវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ**

អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រង់មាត្រា៦ បានតម្រូវឲ្យម្ចាស់គម្រោងត្រូវធ្វើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងចំពោះគម្រោងដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះ ពាល់បរិស្ថាន និងមាត្រា៨ បានតម្រូវឲ្យម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថានចំពោះគម្រោង ដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាល ភាពសាធារណៈ។

អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីសម្បទានដីសេដ្ឋកិច្ច ត្រង់ មាត្រា៤ បានកំណត់ថា រាល់សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ ឲ្យចំពោះតែដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការ អភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន។

តាមរយៈការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេត ឃើញថា ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមួយចំនួន ពុំទាន់បានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៅឡើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរណែនាំក្រុមហ៊ុនឱ្យរូតរះ រៀបចំនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដើម្បីស្នើសុំឯកភាព ពីក្រសួងបរិស្ថានឱ្យបានឆាប់រហ័ស។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ ក្រុមហ៊ុនរង់ចាំការចុះបញ្ជីដីធ្លីជាឯកជនរបស់រដ្ឋជាមុន សិន ដើម្បីឱ្យបានដឹងទំហំដីច្បាស់លាស់ និងប្តូរកិច្ចសន្យាថ្មីរួចរាល់។ កត្តានេះហើយដែលនាំឱ្យមាន ភាពយឺតយ៉ាវក្នុងការរៀបចំនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ប៉ុន្តែក្រុមហ៊ុននឹងព្យាយាមពន្លឿនការរៀបចំរបាយការណ៍វាយតម្លៃនេះឱ្យបានឆាប់រហ័ស។ ក្រុមហ៊ុន បានទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងបន្តខិតខំអនុវត្តតាមអនុសាសន៍នេះនៅ ឆ្នាំបន្ទាប់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានការអនុវត្តតាមអនុសាសន៍សវនកម្ម ជាបន្តទៀត។

### ៣.១.៧.កង្វះខាតក្នុងការអនុវត្តនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូល

អនុក្រឹត្យលេខ ៧២ អនក្រ ២០១៨មិថុនា ឆ្នាំខែ ០៧បក ចុះថ្ងៃទី.របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់មាត្រា៤៥ ចែងថា "រជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ត្រូវទុកដាក់ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យដោយចុះបញ្ជិកាទ្វេភាគនូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ ទៅតាមនីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រមូលចំណូលមិនមែនសារពើពន្ធតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ ប្រកាសលេខ ១៨៩០ សហវ ប្រក.ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រង់ជំពូកទី៤ បានបញ្ជាក់ថា "គណនេយ្យរជ្ជទេយ្យចំណូលត្រូវកាន់បញ្ជីបេឡា ដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់ប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ បញ្ជីគណនេយ្យរបស់រជ្ជទេយ្យករចំណូល រួមមាន ទិន្នានុប្បវត្តិទូទៅ សៀវភៅធំ និងតារាងតុល្យាភាពគណនី"។

តាមការធ្វើសវនកម្មនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រជ្ជទេយ្យករចំណូលនៅពុំទាន់បានកាន់កាប់បញ្ជីគណនេយ្យ ដោយពុំបានចុះបញ្ជិកាទ្វេភាគ(ទិន្នានុប្បវត្តិទូទៅ សៀវភៅធំ និងតារាងតុល្យភាពគណនី)នូវរាល់កិច្ចប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃទៅតាមនីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូលនៃអនុក្រឹត្យខាងលើដូចជា ការតាមដានបេឡាសាច់ប្រាក់រជ្ជទេយ្យករចំណូលនៅធនាគារ (គណនីលេខ១៣០១.១) សាច់ប្រាក់ក្នុងដៃរជ្ជទេយ្យករចំណូល(គណនីលេខ១៣០១.២) មូលប្បទានប័ត្រធ្វើបេឡានិច្ច័យ(គណនីលេខ១១១៦) ចំណូលបណ្តោះអាសន្នរជ្ជទេយ្យករចំណូល(គណនីលេខ៤៧០៥៣) ប្រាក់បញ្ញើមូលនិធិរជ្ជទេយ្យករចំណូលរតនាគារជាតិ (គណនីលេខ១២០៧) និងចំណាយមុនការធ្វើអាណត្តិកិច្ច (គណនីលេខ ១៥០៥៤) ជាដើម។

ក្រសួងគួរជំរុញរជ្ជទេយ្យករចំណូលកត់ត្រាតាមដានឱ្យបានត្រឹមត្រូវ។

ជាការឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបំភ្លឺថា រជ្ជទេយ្យករចំណូលបានចុះបញ្ជិកាទ្វេភាគជាធម្មតាប្រើប្រាស់ប្រព័ន្ធគណនេយ្យអេឡិចត្រូនិក (Quick book) ប៉ុន្តែមន្ត្រីកាន់បញ្ជីមិនបានបោះពុម្ពរបាយការណ៍សុំហត្ថលេខាពីថ្នាក់ដឹកនាំ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព ។

### ៣.១.៨. វិធានការចំពោះអ្នកកាន់អាជ្ញាបណ្ណ(ក្រុមហ៊ុន)បញ្ញើឆាប់រហ័សអន្តរជាតិ

ប្រកាសអន្តរក្រសួងលេខ ១១២០ប្រក ១០ចមព ចុះថ្ងៃ/សហវ.បទ.ខែវិច្ឆិកា ឆ្នាំ២០០៦ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រង់ប្រការ១៥ បានបញ្ជាក់ថា "អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់របាយការណ៍បរិមាណផលិតផលដែលបានធ្វើអាជីវកម្មជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍រៀងរាល់ត្រីមាសឱ្យបានទៀងទាត់ហើយរបាយការណ៍នេះត្រូវបានរក្សាការសម្ងាត់"។

តាមការពិនិត្យស្ថិតិអាជ្ញាប័ណ្ណបញ្ញើឆាប់រហ័សអន្តរជាតិឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅពុំទាន់មានវិធានការចំពោះអ្នកកាន់អាជ្ញាប័ណ្ណ

មិនបានផ្តល់របាយការណ៍បរិមាណផលិតផលដែលបានធ្វើអាជីវកម្មជារៀងរាល់ត្រីមាសជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅឡើយ។ ជាក់ស្តែងក្នុងចំណោមក្រុមហ៊ុនមានអាជ្ញាប័ណ្ណបញ្ជើឆាប់រហ័សអន្តរជាតិចំនួន៦៧ ក្នុងនោះមាន២៤ក្រុមហ៊ុនបានធ្វើរបាយការណ៍បរិមាណផលិតផល៤ត្រីមាស មាន១០ក្រុមហ៊ុនបានធ្វើរបាយការណ៍បរិមាណផលិតផល៣ត្រីមាស មាន១០ក្រុមហ៊ុនបានធ្វើរបាយការណ៍បរិមាណផលិតផល២ត្រីមាស មាន០៧ក្រុមហ៊ុនបានធ្វើរបាយការណ៍បរិមាណផលិតផល១ត្រីមាស មាន០១ក្រុមហ៊ុនបានធ្វើរបាយការណ៍បរិមាណផលិតផល០១ខែ ចំណែកឯមាន១៥ក្រុមហ៊ុនទៀតមិនបានធ្វើរបាយការណ៍បរិមាណផលិតផលឡើយ។

ដូចនេះក្រសួងគួរជំរុញការអនុវត្តប្រកាសអន្តរក្រសួងខាងលើឱ្យមានប្រសិទ្ធភាព។

ជាការឆ្លើយបំភ្លឺរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកឡើងថា ចំពោះក្រុមហ៊ុនមិនបានធ្វើរបាយការណ៍បរិមាណផលិតផលធ្វើអាជីវកម្មទៀងទាត់រៀងរាល់ត្រីមាស បច្ចុប្បន្នក្រសួងបានតម្រូវឱ្យក្រុមហ៊ុនទាំងនោះធ្វើកិច្ចសន្យាផ្តល់របាយការណ៍បរិមាណផលិតផលរៀងរាល់ត្រីមាស ដោយភ្ជាប់នឹងលក្ខខណ្ឌព្យួរអាជ្ញាបណ្ណប្រសិនបើមិនអនុវត្ត។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តតាមអនុសាសន៍ជាបន្តទៀត។

### ៣.១.៩.ការកត់ត្រាចំណូលពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា

ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ១ ត្រូវដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានចែកជាចំណាត់ថ្នាក់ចំណូល ចំណាយ និងត្រូវបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ភ្ជាប់ជាមួយប្រកាសនេះ។

- គណនី ៧៣០២ អនុគណនី ៧៣០២៨ ចំណូលទទួលបានពីការបញ្ជាក់លើហត្ថលេខា លិខិតចម្លងច្បាប់ដើម វិញ្ញាបនប័ត្រ លិខិតបញ្ជាក់ការសិក្សា ព្រឹត្តិបត្រពិន្ទុ លិខិតផ្សេងៗ...
- គណនី៧៥០៨ អនុគណនី៧៥០៨១ ចំណូលដែលបានពីការរួមចំណែករបស់រោងចក្រសហគ្រាស អាជីវកម្ម សម្រាប់ទ្រទ្រង់ ឬថែរក្សាបរិស្ថាន។

តាមការពិនិត្យលើកិច្ចសន្យាតម្លើងអង់តែនទូរស័ព្ទក្នុងតំបន់ការពារធម្មជាតិ និងរបាយការណ៍ចំណូលរបស់អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថាន សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋទេយ្យករចំណូលរងនៃអង្គភាពថវិកាអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ បានធ្វើការកត់ត្រាចំណូលពីការជួលទីតាំងតម្លើងអង់តែនទូរស័ព្ទតាមតំបន់ការពារធម្មជាតិ ដែលមានទឹកប្រាក់សរុបចំនួន ១៧៤ ១៧៣ ៣០០រៀល នៅមិនទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៅឡើយទេ ដូចមានបង្ហាញជូនក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | កត់ត្រាជាក់ស្តែង | ចំណាត់សេដ្ឋកិច្ចនៃមាតិកាថវិកា |
|---|---|---|---|
| ១ | ការតម្លើងអង់តែនទូរស័ព្ទក្នុងតំបន់ការពារធម្មជាតិ | គណនី៧៣០២<br>អនុគណនី៧៣០២៨ | គណនី៧៥០៨<br>អនុគណនី៧៥០៨១ |

ក្រសួងបរិស្ថាន គួរណែនាំដល់អង្គភាពថវិកាអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ឱ្យធ្វើការកត់ត្រាចំណូលឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ឆ្លើយតបទៅនឹងការលើកឡើងខាងលើ ក្រសួងបានបំភ្លឺថា ការកត់ត្រាចូលក្នុងអនុគណនី៧៣០២៨ គឺបានស្របតាមប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ដែលចំណូលនេះជាចំណូលសេវាសាធារណៈពីការផ្តល់ទីតាំងដំឡើងបង្គោលអង់តែនទូរស័ព្ទស្ថិតក្នុងតំបន់ការពារធម្មជាតិ។ ម្យ៉ាងទៀត ការធ្វើកិច្ចសន្យាផ្តល់ទីតាំងដំឡើងបង្គោលអង់តែនទូរស័ព្ទក្នុងតំបន់ការពារធម្មជាតិនេះ មិនមែនជាការជួលដីរដ្ឋដែលត្រូវបង់ចូលថវិការដ្ឋ១០០នោះទេ។ ហើយមួយវិញទៀត ការផ្តល់%ទីតាំងដំឡើងបង្គោលអង់តែនទូរស័ព្ទក្នុងតំបន់ការពារធម្មជាតិ ស្ថិតក្នុងឧបសម្ព័ន្ធទី១នៃកម្រងសេវាសាធារណៈនៃប្រកាសអន្តរក្រសួង លេខ១០០៧ សហវ.ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងបរិស្ថាន។ តាមរយៈលទ្ធផលដែលបានសង្កេតឃើញ និងតាមការពិនិត្យឯកសារពាក់ព័ន្ធ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិនឹងធ្វើការសិក្សាបន្ថែមពីអនុគណនីថ្មី ដើម្បីកែលម្អតាមអនុសាសន៍នៅពេលក្រោយទៀត។

ផ្អែកតាមការបំភ្លឺរបស់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.១០.ការចុះកិច្ចបញ្ជិកាគណនេយ្យរបស់រជ្ជទេយ្យករចំណូលរង

សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ចំណុចទី៦ បានចែងថា "ក្នុងករណីដែលរដ្ឋបាលថ្នាក់ជាតិមានរជ្ជទេយ្យករចំណូលរងជាជំនួយការដល់រជ្ជទេយ្យករចំណូលក្នុងការប្រមូលចំណូល រជ្ជទេយ្យករចំណូលរងមិនតម្រូវឱ្យបើកគណនីរជ្ជទេយ្យករចំណូលនៅរតនាគារ និងមិនចុះកិច្ចបញ្ជិកាគណនេយ្យ ចំណូលតាមគោលការណ៍ទ្វេភាគដូចរជ្ជទេយ្យករចំណូលទេ។ រជ្ជទេយ្យករចំណូលរងត្រូវកាន់បញ្ជីបេឡាសាច់ប្រាក់អមដោយសក្ខីបត្រតែប៉ុណ្ណោះ" និងត្រង់ចំណុចទី៩ ត្រទី៦ "រជ្ជទេយ្យករចំណូលត្រូវបង្កើតបញ្ជីបេឡាសាច់ប្រាក់នៅក្នុងដៃ និងបញ្ជីសាច់ប្រាក់នៅធនាគារដាច់ដោយឡែកពីគ្នា" ។

តាមការពិនិត្យសុំណុំឯកសាររបស់រជ្ជទេយ្យករចំណូលរង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រជ្ជទេយ្យករចំណូលរងប្រចាំរដ្ឋបាលជលផលពុំបានរៀបចំបញ្ជីបេឡាតាមដានសាច់ប្រាក់ដើម្បីកត់ត្រានូវចំណូលដែលទទួលបាន និងចំណាយដែលបានដកប្រចាំថ្ងៃនោះទេ ដោយរជ្ជទេយ្យករចំណូលរងបានរៀបចំរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូលប្រចាំខែ តារាងគណនាប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែលើការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលជលផលតាមរយៈប្រព័ន្ធe-Payment និងភ្ជាប់ជាមួយវិក្កយបត្របង់ចំណូលតែប៉ុណ្ណោះ។

រដ្ឋទេយ្យករចំណូលរងប្រចាំអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានកត់ត្រាចំណូលពីសេវាសាធារណៈដែលទទួលបានជាសាច់ប្រាក់ផង និងតាមរយៈធនាគារដៃគូផងទៅក្នុងបញ្ជីបេឡាសាច់ប្រាក់ក្នុងដៃរួមបញ្ចូលគ្នាតែមួយ ដោយពុំបានរៀបចំបញ្ជីបេឡាសាច់ប្រាក់ក្នុងដៃ និងបញ្ជីបេឡាសាច់ប្រាក់នៅធនាគារដាច់ដោយឡែកពីគ្នានោះទេ។ លើសពីនេះទៀត បញ្ជីបេឡាដែលបានកត់ត្រានោះ ពុំបានឆ្លុះបញ្ចាំងនូវចំណូលចំណាយដែលទទួលបានពីអតិថិជន និងការបែកចែកប្រាក់រង្វាន់លើកទឹកចិត្ត ព្រមទាំងសមតុល្យសាច់ប្រាក់ទៅតាមកាលបរិច្ឆេទដែលកើតឡើងជាក់ស្តែងប្រចាំថ្ងៃនោះទេ ដោយរដ្ឋទេយ្យករចំណូលរងបានធ្វើការបូកសរុបចំណូលពីសេវាសាធារណៈប្រចាំថ្ងៃ ហើយរៀបចំប័ណ្ណចំណូល ប័ណ្ណចំណាយ រួចកត់ត្រាសរុបទៅក្នុងបញ្ជីបេឡានៅពេលវេលាសមស្របណាមួយនៅពេលក្រោយ។ រដ្ឋទេយ្យករចំណូលរងប្រចាំអគ្គនាយកដ្ឋាន កៅស៊ូ បានប្រមូលចំណូលពីការជួលដីទំនេរ និងដីមានអគារដោយចំណូលទាំងនោះត្រូវបង្វែរចូលទៅក្នុងគណនីរបស់ក្រសួងនៅធនាគារកាណាឌីយ៉ា នៅពេលអតិថិជនបានបង់ប្រាក់ចូលគណនីធនាគាររួច អតិថិជនបានប្រគល់បណ្ណដាក់ប្រាក់ចូលគណនីជូនរដ្ឋទេយ្យករចំណូលរង ប៉ុន្តែរដ្ឋទេយ្យករចំណូលរងពុំបានធ្វើបញ្ជីបេឡាសាច់ប្រាក់នៅធនាគារនោះទេ ដោយបានរៀបចំតែរបាយការណ៍ស្តីពីការប្រមូលចំណូលថវិការដ្ឋ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំតែប៉ុណ្ណោះ។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរណែនាំរដ្ឋទេយ្យករចំណូលរងរបស់អង្គភាពក្រោមឱវាទខាងលើឱ្យកាន់កាប់កិច្ចបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ ។

ចំពោះចំណុះនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាពតាមខ្លឹមសារនៃរបាយការណ៍សវនកម្មនេះ និងខិតខំព្យាយាមកែលម្អនូវចំណុចខ្វះខាតទាំងឡាយដែលបានលើកឡើងដោយអាជ្ញាធរសវនកម្មជាតិ។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.១១.ការពុំបានធ្វើបញ្ជីតាមដានបំណុលលើក្រុមហ៊ុនដែលពុំបានបង់ឈ្នួលដី

ប្រកាសលេខ១១៩៥ សហវ.ប្រក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីវិធានការនិងនីតិវិធីនៃការគ្រប់គ្រង ការតឹងទារ និងការជម្រះបញ្ជីនៃបំណុលមិនមែនសារពើពន្ធ ត្រង់ប្រការ៦ចែងថា "ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំបញ្ជីតាមដានបំណុលប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងត្រូវត្រួតពិនិត្យតាមដានជាប្រចាំនូវស្ថានភាពបំណុលមិនមែនសារពើពន្ធឱ្យបានម៉ត់ចត់ដើម្បីក្រើនរំលឹក ឬឈានដល់ការចាត់វិធានការតឹងទារ"។

តាមការចុះធ្វើសវនកម្មនៅអគ្គនាយកដ្ឋានសហគមន៍នៃក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋាននេះបានប្រមូលចំណូលពីការជួលដីទំនេរបានចំនួន២កន្លែង ប៉ុន្តែអគ្គនាយកដ្ឋាននេះនៅពុំទាន់បានប្រមូលចំណូលពីការជួលដីទំនេរចំនួន២កន្លែងទៀត ហើយគិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៤ ក្រសួងក៏នៅពុំទាន់ធ្វើបញ្ជីតាមដានបំណុលនិងពិន័យលើក្រុមហ៊ុនដែលពុំទាន់បង់ថ្លៃឈ្នួលទាំង២នេះនៅឡើយទេ ដែលមានទឹកប្រាក់ចំនួន ៣៤០ ៨០០ ០០០ រៀល។

ដើម្បីឱ្យការប្រមូលចំណូលនិងការធ្វើបញ្ជីតាមដានបំណុលឱ្យបានត្រឹមត្រូវ ក្រសួងបរិស្ថានគួរតែណែនាំឱ្យអគ្គនាយកដ្ឋានសហគមន៍ឱ្យអនុវត្តត្រឹមត្រូវតាមប្រកាសខាងលើ។

ឆ្លើយតបនឹងករណីនេះ ក្រសួងបរិស្ថានបានទទួលយក និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់ទៀត។

ផ្អែកតាមការបំភ្លឺរបស់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

**៣.១.១២.ការទូទាត់ប្រាក់បេសកកម្មឆ្លងឆ្នាំ**

អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រង់ជំពូកទី៤ មាត្រា២១ កថាខណ្ឌទី១ បានចែងថា "រាល់បេសកកម្មក្នុង និងក្រៅប្រទេសដែលបានអនុវត្តនៅក្នុងត្រីមាសទី៤នៃឆ្នាំមុនមិនទាន់ទូទាត់ ត្រូវអនុញ្ញាតឱ្យទូទាត់ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទី១នៃឆ្នាំបន្ទាប់ដោយអនុវត្តនីតិវិធីទូទាត់ត្រង់ និងប្រើឥណទានថវិកានៅឆ្នាំបន្ទាប់" និងកថាខណ្ឌទី២ បានចែងថា "រាល់បេសកកម្មនៅក្នុង និងក្រៅប្រទេសដែលបានអនុវត្តនៅក្នុងបីត្រីមាសដំបូងនៃឆ្នាំមុន និងបណ្តាឆ្នាំកន្លងទៅមិនត្រូវបានអនុញ្ញាតឱ្យទូទាត់នៅឆ្នាំបន្ទាប់ឡើយ"។

តាមការពិនិត្យអាណត្តិបើកប្រាក់ បណ្ណចំណាយ និងរបាយការណ៍ចំណាយបេសកកម្មក្នុងប្រទេសប្រចាំឆ្នាំ២០២៣ ព្រមទាំងសក្ខីបត្រគាំទ្រប្រតិបត្តិការចំណាយបេសកកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសឆ្លងឆ្នាំ ដែលមានទឹកប្រាក់ចំនួន ៣៣២ ៥០៦ ៦០០រៀល ដោយក្រសួងបានយកប្រតិបត្តិការចំណាយបេសកកម្មក្នុងប្រទេសដែលបានកើតឡើងក្នុងត្រីមាសទី២ និងទី៣ នៃឆ្នាំ២០២២ មកទូទាត់ថវិកានៅត្រីមាសទី១ ក្នុងឆ្នាំ២០២៣។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួររួសរាន់ក្នុងការទូទាត់ប្រាក់បេសកកម្មក្នុងប្រទេសឱ្យបានទាន់ពេលវេលាស្របតាមអនុក្រឹត្យខាងលើ។

ឆ្លើយតបចំពោះចំណុចខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបំភ្លឺថា ក្នុងឆ្នាំ២០២២ ក្រសួងមានតម្រូវការចុះបេសកកម្មថ្នាក់ជាតិជាច្រើនលើសពីផែនការដែលបានគ្រោងទុកទើបធ្វើឱ្យមានការទូទាត់ឆ្លងឆ្នាំ។ ក្រសួងសូមទទួលយកអនុសាសន៍ខាងលើ និងខិតខំពង្រឹងយន្តការពិនិត្យតាមដានការអនុវត្តកិច្ចការងារនេះ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

**៣.១.១៣.ការវាយតម្លៃ និងការប្រគល់ទទួល(សេវា)មិនបានចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុន**

ដើម្បីគ្រប់គ្រងកិច្ចលទ្ធកម្មសាធារណៈអនុវត្តឱ្យមានប្រសិទ្ធភាព លក្ខខណ្ឌនៃកិច្ចសន្យាបានចែងអំពីកាតព្វកិច្ចរបស់អ្នកម្ចាស់ការត្រូវចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុន រួចធ្វើរបាយការណ៍ជូនគណៈកម្មការវាយតម្លៃ និងប្រគល់ទទួល។

តាមការពិនិត្យសំណុំឯកសារលទ្ធកម្មស្តីពីការផ្គត់ផ្គង់ និងដំឡើងឧបករណ៍បច្ចេកទេសដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវូបករណ៍ និងទំហំផ្ទុកទិន្នន័យនៅមជ្ឈមណ្ឌលទិន្នន័យ ការបំពាក់ឧបករណ៍ទប់ភ្លើង (UPS) ការដំឡើងឧបករណ៍បច្ចេកទេសប្រព័ន្ធវីដេអូនៃសន្និសីទដែលមានទឹកប្រាក់ចំនួន ៧៩៨ ៥០០ ០០០រៀល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មិនបានចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសលើការផ្គត់ផ្គង់ និងដំឡើងឧបករណ៍បច្ចេកទេស ដើម្បីធ្វើរបាយការណ៍ជូនគណៈកម្មការវាយតម្លៃ និងប្រគល់ទទួលជាមុនឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឡើយ។ កត្តានេះអាចនាំឱ្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈមិនស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា។ ក្រសួងគួរជំរុញអង្គភាពលទ្ធកម្មអនុវត្តកិច្ចសន្យាលទ្ធកម្មឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឱ្យមានប្រសិទ្ធភាព។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបំភ្លឺថា ក្រុមការងារបច្ចេកទេសនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានបានចូលរួមពិនិត្យលក្ខណៈបច្ចេកទេសក្នុងពេលដែលគណៈកម្មាធិការលទ្ធកម្ម និងតំណាងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក.ស.ហ.វ. ចុះត្រួតពិនិត្យបរិមាណ លក្ខណៈបច្ចេកទេស និងតេស្តគុណភាពស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា ហេតុដូច្នេះទើបមិនតម្រូវឱ្យចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសដោយឡែកផ្សេងទៀត។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

### ៣.១.១៤.ការប្រគល់ទទួលការងារជួសជុល និងការថែទាំពុំស្របតាមពេលវេលា និងទំហំការងារ

ប្រកាសលេខ១៦១៣សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ផ្នែក៣ ប្រការ៧ ចំណុចត្រេទី២ បានបញ្ជាក់ថា "អ្នកផ្គត់ផ្គង់ និងអ្នកទទួលការមានភារកិច្ចអនុវត្តកិច្ចសន្យាលទ្ធកម្មសំខាន់ៗជាអាទិ៍អនុវត្តឱ្យបានត្រឹមត្រូវតាមបរិមាណ គុណភាព លក្ខណៈបច្ចេកទេស គំនូសប្លង់ និងប្រតិទិនការងារ" និងសារាចរណែនាំលេខ០០២សហវ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុច១៩ បានបញ្ជាក់ថា "ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណ ទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានកំណត់ក្នុងកិច្ចសន្យា"។

តាមការពិនិត្យសំណុំឯកសារលទ្ធកម្មសាធារណៈស្តីពីការងារជួសជុល ថែទាំ និងកែលម្អអគាររបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងបរិស្ថានក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការងារជួសជុល ថែទាំ និងកែលម្អអគារមួយចំនួនត្រូវបានអនុវត្ត និងបានប្រគល់-ទទួលពុំស្របតាមប្រតិទិនការងារដែលបានចែងក្នុងកិច្ចសន្យា។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងបរិស្ថានគួរណែនាំដល់អ្នកទទួលការទាំងអស់ឱ្យអនុវត្តការងារជួសជុល និងថែទាំអគារ ព្រមទាំងការតបណ្តាញផ្សេងៗឱ្យស្របកិច្ចសន្យា។

ចំពោះចំណុចនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានបំភ្លឺដូចខាងក្រោម៖

១. ការងារជួសជុលអគារអន្តេវាសិកដ្ឋានចំនួន ០២អគារ ជួសជុលប្រព័ន្ធលូរំដោះទឹក ភ្លៀង និងដាក់ចម្រឹងបង្អួច មូលហេតុដែលធ្វើការជួសជុលមុនប្រតិទិនការងារនោះ ដោយសារបន្ទាប់ពីធ្វើការដេញថ្លៃ និងធ្វើការវាយតម្លៃយ៉ាងល្អិតល្អន់លើបុរេលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុន និងប្រគល់កិច្ចសន្យារួចមក ខាងសាលាមធ្យមវិចិត្រសិល្បៈដែលជាម្ចាស់ការបានសំណូមពរដល់ភាគីក្រុមហ៊ុនធ្វើយ៉ាងណាជួយជួសជុលអន្តេវាសិកដ្ឋានដែលមាន០២(ពីរ)អគារនេះឱ្យបានឆាប់ ដើម្បីកុំឱ្យប៉ះពាល់ដល់ការស្នាក់នៅរបស់សិស្សានុសិស្សដែលភាគច្រើនពុំមានកន្លែងស្នាក់នៅ និងធ្វើការជួសជុលប្រព័ន្ធលូរំដោះទឹកភ្លៀងឱ្យមុនរដូវភ្លៀងមកដល់ ព្រោះថា បើមានភ្លៀងខ្លាំងសាលាអាចនឹងជន់លេចដែលធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្ស។ ដោយបានទទួលសំណូមពរពីភាគីខាងម្ចាស់ការ ភាគីក្រុមហ៊ុនបានធ្វើការជួសជុលទាំងអគារអន្តេវាសិកដ្ឋាន និងជួលជុលប្រព័ន្ធលូរំដោះទឹកភ្លៀងនេះដំណាលគ្នា ដោយពុំរង់ចាំជួសជុលគម្រោងណាមុនគម្រោងណាក្រោយនោះទេ។

២. ការងារថែទាំ តបណ្តាញទូរស័ព្ទ អគ្គិសនី ខ្សែអ៊ីនធ័រណេត តម្លើងឧបករណ៍ និងជួសជុលស្តារប្រព័ន្ធលូទឹកកខ្វក់ ដែលការងារនេះគឺមានម្ចាស់គម្រោងចំនួន០២ គឺនាយកដ្ឋានសម្ភារនិងបរិក្ខារ និងនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុដែលជាម្ចាស់ការ ដោយតម្រូវឱ្យក្រុមហ៊ុនត្រូវធ្វើការបែងចែកជាក្រុមការងារអនុវត្តគម្រោងត្រូវសហការជាមួយអង្គភាពនៃម្ចាស់គម្រោងទាំងពីរជាពីរផ្នែកទៅតាមគម្រោងរបស់អង្គភាពទាំងពីរនេះ ដែលជាហេតុធ្វើឱ្យការអនុវត្តការងាររួចរាល់មុនកាលបរិច្ឆេទបញ្ចប់ការងារដែលមានចែងក្នុងកិច្ចសន្យា។

៣. ការងារជួសជុលដំបូលអគារសារមន្ទីរជាតិស្លាបខាងលិចZOON-III គឺក្រសួងបានធ្វើការចុះកិច្ចសន្យាផ្ទាល់ជាមួយអង្គភាពជំនាញគឺនាយកដ្ឋានសារមន្ទីរជាតិ មូលហេតុដែលអនុវត្តរួចរាល់មុនប្រតិទិនការងារនោះ ដោយសារនៅពេលធ្វើការប្រជុំចរចាថ្លៃរួចមក ក្រសួងបានអនុញ្ញាតឱ្យនាយកដ្ឋានសារមន្ទីរជាតិធ្វើការងារជួសជុលភ្លាមៗផងដែរដើម្បីជៀសវាងប៉ះពាល់ភ្ញៀវទេសចរណ៍ដែលមកទស្សនាសារមន្ទីរ និងធ្វើយ៉ាងណាឱ្យបានរួចរាល់មុនរដូវភ្លៀងមកដល់ ជៀសវាងភ្លៀងលិចនៅពេលដែលបើកដំបូលធ្វើការជួសជុលដែលជាហេតុនាំឱ្យ ប៉ះពាល់ដល់រូបចម្លាក់ដែលរក្សាទុកនៅទីនោះ ។

ក្រសួងបានជម្រាបផងដែរថា រាល់ការប្រគល់ទទួលសំណង់ទាំងនេះគឺមានការចូលរួមវាយតម្លៃពីតំណាងអ្នកម្ចាស់ការ គណៈកម្មាធិការលទ្ធកម្ម តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីអនុវត្តការងារ (តំណាងក្រុមហ៊ុន) ដើម្បីធ្វើការវាយតម្លៃទៅលើគុណភាពសំណង់។

ចំពោះចំណុចនេះក្រសួងបរិស្ថាន បំភ្លឺថា៖

១. ក្រសួងបានទទួលយកនូវអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងកែលម្អនៅឆ្នាំបន្ទាប់។ ហើយចំពោះករណីនេះ សូមបញ្ជាក់ជូនបន្ថែមថា ដោយសារក្រុមការងារលទ្ធកម្មបានស្នើសុំឱ្យក្រុមហ៊ុនទទួលការពន្លឿនលើការងារនេះតាមដែលអាចធ្វើទៅបាន។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៥.ការអនុវត្តកិច្ចលទ្ធកម្មពុំស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ

សារាចរណែនាំលេខ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់និងទៀងទាត់តាមវិធីសាស្ត្រ និងពេលវេលានៃដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មដូចមានចែងក្នុងផែនការលទ្ធកម្មដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី-ខេត្ត (ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ) ដោយត្រូវជៀសវាងដាច់ខាតរាល់ការអូសបន្លាយពេលវេលា ក្នុងគោលបំណងគេចវេសពីការអនុវត្តវិធីសាស្ត្រលទ្ធកម្មដេញថ្លៃសាធារណៈពេញលេញដោយស្នើសុំកាត់បន្ថយរយៈពេលផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ ឬស្នើសុំការអនុវត្តវិធីសាស្ត្រលទ្ធកម្មដោយឡែក ដោយចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុន ឬជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋណាមួយ។

តាមការពិនិត្យលើផែនការលទ្ធកម្ម និងរបាយការណ៍អនុវត្តលទ្ធកម្មនៃអង្គភាពលទកម្មរបស់ក្រសួងធនធានទឹក និងឧតុនិយមសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃក្រសួងបានអនុវត្តកិច្ចលទ្ធកម្មស្តីពីការជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេសពុំបានស្របតាមផែនការលទ្ធកម្មប្រចាំឆ្នាំ។ កត្តានេះ នាំឱ្យការអនុវត្តតាមសារាចរណែនាំខាងលើពុំមានប្រសិទ្ធភាព និងធ្វើឱ្យការអនុវត្តកិច្ចលទ្ធកម្មប្រកួតប្រជែងក្នុងស្រុកពុំបានត្រឹមត្រូវតាមនីតិវិធី។

ក្រសួងធនធានទឹក និងឧតុនិយម គួរណែនាំអង្គភាពលទ្ធកម្មរបស់ខ្លួនឱ្យអនុវត្តឱ្យបានសមស្របតាមផែនការលទ្ធកម្មដែលបានលើក។

នៅចំណុចនេះ ក្រសួងធនធានទឹក និងឧតុនិយម សូមឯកភាពតាមរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិ។ ករណីនេះ ក្រសួងនឹងធ្វើការកែលម្អដោយត្រូវអនុវត្តតាមផែនការលទ្ធកម្មសាធារណៈឱ្យបានសមស្រប។

អាជ្ញាធរសវនកម្មជាតិបានឃើញការបំភ្លឺរបស់ក្រសួងធនធានទឹក និងឧតុនិយម។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.១៦.ការរៀបចំគម្រោងនៃកិច្ចលទ្ធកម្មសាធារណៈពុំសមស្រប

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវចងជាកញ្ចប់លទ្ធកម្មចំពោះមុខសញ្ញាលទ្ធកម្ម ដែលស្ថិតក្នុងប្រភេទដូចគ្នា មានលក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែងសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង ការសន្សំសំចៃសោហ៊ុយចំណាយ និងចំណេញពេលវេលា។

ប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ៥ បានចែងថា ចំណាយរជ្ជទេយ្យបុរេប្រទានគឺជាចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់ និងមានចំនួនទឹកប្រាក់តិចតួចដែលពុំអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីទូទាត់ត្រង់បានជាអាទិ៍រួមមាន ចំណាយលើការទិញសម្ភារតិចតួច និងសេវាកម្មតូចតាចជាដើម និងត្រង់ប្រការ

១៨ បានចែងថា ចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយត្រូវបានកំណត់ ៣ ០០០ ០០០រៀលជាអតិបរមា។ មួយគោលការណ៍ចំណាយសំដៅដល់មួយ (បីលាន) កម្មវត្ថុចំណាយ ឬមួយគម្រោងចំណាយដែលរដ្ឋទេយ្យករបុរេប្រទានស្នើសុំគោលការណ៍ចំណាយពីអាណាប័កមួយលើកៗ ដើម្បីចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន។ រដ្ឋទេយ្យករបុរេប្រទាន ឬរដ្ឋទេយ្យករបុរេប្រទានរងត្រូវជៀសវាងដាច់ខាតនូវការបំបែកគោលការណ៍ចំណាយ ឬប័ណ្ណចំណាយទៅតាមទីកន្លែងគោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេះការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

ប្រកាសលេខ០១០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការផ្ដល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រង់ប្រការ១ បានចែងថា "ប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈជូនក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាក្នុងកម្រិតទឹកប្រាក់ធានាចំណាយដូចមានបញ្ជាក់ក្នុងត្រែទី៤ បញ្ជាក់ថា " ក្រោមទឹកប្រាក់៨០០លានរៀល សម្រាប់ថវិកាក្រសួង ស្ថាប័ន និងអង្គភាពថវិកាថ្នាក់កណ្តាលក្រោមឱវាទ" និងប្រការ៣ បានចែងថា " ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងដាក់ពិន័យដោយផ្អាកការផ្ដល់ធានាចំណាយសម្រាប់គម្រោងលទ្ធកម្មបន្ទាប់ ឬដកយកមកវិញនូវសិទ្ធិសម្រេចលទ្ធកម្មតាមកម្រិតមួយផ្នែក ឬទាំងស្រុង ចំពោះក្រសួង ស្ថាប័ន រាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពថវិកាដែលអនុវត្តមិនបានម៉ឺងម៉ាត់តាមវិធាន បទប្បញ្ញត្តិ នីតិវិធី លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ពិសេសអនុវត្តមិនបានត្រឹមត្រូវតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងផែនការលទ្ធកម្ម ការបំបែកគម្រោងទៅជាគម្រោងតូចៗ ដើម្បីតម្រូវតាមសិទ្ធិសម្រេចរបស់ខ្លួន..."។

ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៩ បានកំណត់ថា "អង្គភាពលទ្ធកម្ម ឬក្រុមលទ្ធកម្មត្រូវប្រមូលផ្ដុំបញ្ចូលក្នុងក្រុមលទ្ធកម្មតែមួយហៅថា (ឡូត៏លទ្ធកម្ម) នូវតម្រូវការទំនិញ សំណង់ និងសេវាកម្មដែលស្ថិតនៅប្រភេទដូចគ្នា ហើយមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ឬបម្រើឱ្យការងារតែមួយដូចគ្នា គ្រឿងសង្ហារឹម សម្ភារការិយាល័យ ឬប្រេងឥន្ធនៈ សម្រាប់ទំនិញ ឬការងារសាងសង់តូចតាមមួយចំនួន ដែលស្ថិតនៅជិតគ្នាៗជាដើម សម្រាប់សំណង់" និងប្រការ២០ បានកំណត់ថា "ឡូត៏លទ្ធកម្មដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នាត្រូវបញ្ចូលជាក្រុមធំមួយហៅថា (កញ្ចប់លទ្ធកម្ម) សម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក ដើម្បីបង្កើនកម្រិតគុណភាពប្រកួតប្រជែង និងចំណេញពេលវេលា ព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយ"។

ប្រកាសលេខ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម។

តាមការពិនិត្យសំណុំឯកសារកិច្ចលទ្ធកម្មក្នុងការិយបរិច្ឆេទ២០២៣ របស់ក្រសួងសុខាភិបាល (សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង) ក្រសួងព័ត៌មាន ក្រសួងផែនការ និងក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅមិនទាន់អនុលោមទៅតាមខ្លឹមសារនៃប្រកាសខាងលើនៅឡើយ ដូចជា ការពុំបានដាក់បញ្ចូលគម្រោងដេញថ្លៃមានលក្ខណៈដូចគ្នាឬស្រដៀងគ្នាក្នុងកិច្ចលទ្ធកម្មតែមួយ ការបំបែកគម្រោងលទ្ធកម្មមួយចំនួនដែលមានលក្ខណៈបច្ចេកទេសដូចគ្នាឬប្រហាក់ប្រហែលគ្នាទៅជាគម្រោងតូចៗ និងការបំបែកប័ណ្ណចំណាយថវិកាកម្មវិធីរដ្ឋទេយ្យបុរេប្រទានដោយមិនអនុវត្តកិច្ចលទ្ធកម្ម។

កត្តានេះនាំឱ្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ពុំទាន់បានសមស្របតាមខ្លឹមសារនៃប្រកាសខាងលើ។ ក្រសួងសុខាភិបាល (សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង) ក្រសួងព័ត៌មាន ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) គួរខិតខំយកចិត្តទុកដាក់ និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិខាងលើឱ្យបានត្រឹមត្រូវ។

ក្រសួងសុខាភិបាល (សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង) ក្រសួងព័ត៌មាន ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម) បានទទួលយកនូវអនុសាសន៍ និងកែលម្អនូវចំណុចខ្វះខាតទាំងឡាយ ឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើនៅឆ្នាំបន្ទាប់។

អាជ្ញាធរសវនកម្មជាតិបានឃើញការឆ្លើយបំភ្លឺរបស់ក្រសួងសុខាភិបាល (សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង) ក្រសួងព័ត៌មាន ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកសិកម្ម)។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.១៧.ការរៀបចំរបាយការណ៍សមិទ្ធកម្ម

ប្រកាសលេខ១១៣ សហវ.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំអំពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មក្នុងសៀវភៅ(សេចក្ដីព្រាង)គោលការណ៍ណែនាំស្ដីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ទំព័រ១២ ត្រង់ចំណុចទី៣.៣. របបរៀបចំរបាយការណ៍ និងរាយការណ៍សមិទ្ធកម្ម កថាខ័ណ្ឌទី២ បានចែងថា "ក្រសួងស្ថាប័នត្រូវរៀបចំរបាយការណ៍ ទាំងរបាយការណ៍ចំណូល-ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្ម រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ...។ ទម្រង់របាយការណ៍សមិទ្ធកម្មមាននៅក្នុងតារាង ៤ តារាង៥ និងតារាង៦នៃសៀវភៅណែនាំ"។

តាមការពិនិត្យលើរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំរបាយការណ៍សមិទ្ធកម្ម ដែលមានទម្រង់នៅពុំទាន់បានស្របតាមទម្រង់ដែលត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងសៀវភៅណែនាំស្ដីពីការតាមដាន និង វាយតម្លៃថវិកាសមិទ្ធកម្មនៅឡើយ។

ដូចនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួររៀបចំរបាយការណ៍សមិទ្ធកម្មឱ្យស្របតាមគោលការណ៍ណែនាំខាងលើ។

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការបំភ្លឺដូចខាងក្រោម៖

- ក្នុងឆ្នាំ២០២៣ ក្រសួងបានរៀបចំរបាយការណ៍សមិទ្ធកម្មតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមានសេចក្តីផ្តើម វឌ្ឍនភាពប្រចាំឆមាស ប្រចាំឆ្នាំ តាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពសម្រាប់រដ្ឋបាលកណ្តាល-មន្ទីរជំនាញ និងទម្រង់តារាងរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាព (ប្រចាំឆមាស ប្រចាំឆ្នាំ)
- នៅឆ្នាំបន្ត ក្រសួងនឹងធ្វើការកែសម្រួល អនុវត្តតាមប្រកាសលេខ១១៣ សហវ.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំអំពីការតាមដាន និងវាយតម្លៃចរិកាសមិទ្ធកម្មក្នុងសៀវភៅ (សេចក្តីព្រាង) គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃចរិកាសមិទ្ធកម្ម ទំព័រ១២ ត្រង់ចំណុច ទី៣.៣. របបរៀបចំរបាយការណ៍ និងរាយការណ៍សមិទ្ធកម្ម និង

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថា៖
  - កន្លងមកក្រសួងបានអនុវត្តតាមសៀវភៅគោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃចរិកាសមិទ្ធកម្ម(២០២០) ត្រង់ទំទី១៣៥(តារាងឧបសម្ព័ន្ធ៦.១៣) ចាប់តាំងពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ ភាពខុសគ្នារវាងគំរូទម្រង់តារាងនៃរបាយការណ៍សមិទ្ធកម្ម(សេចក្តីព្រាង) ដែលបានភ្ជាប់ជាមួយនឹងប្រកាសលេខ១១៣ សហវ.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ និងសៀវភៅណែនាំស្តីពីការតាមដាន និងវាយតម្លៃចរិកាសមិទ្ធកម្មឆ្នាំ២០២០ ដែលក្រសួងបានអនុវត្តគឺត្រង់ចំណុច "**រៀបរាប់អំពីសូចនាករលទ្ធផលក្នុងឆ្នាំ**"។ ប៉ុន្តែក្រសួងសូមទទួលយកអនុសាសន៍ខាងលើ និងកែសម្រួលពេលក្រោយ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៨.ការពុំបានរៀបចំរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍របស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា

អនុក្រឹត្យលេខ៥៦.អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ត្រង់មាត្រា១២ បានចែងថា "បញ្ជីសម្រង់វត្តមានប្រចាំថ្ងៃ ឬប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវត្តមានត្រូវរៀបចំឱ្យមានគ្រប់អង្គភាពធ្វើយ៉ាងណាបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាក្នុងការចុះវត្តមានមុននិងក្រោយពេលបំពេញការងារប្រចាំថ្ងៃឱ្យបានទាន់ពេលវេលា និងងាយស្រួលដល់ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ក្នុងការប្រមូលទិន្នន័យរៀបចំរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍ និងប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដូចមានគំរូជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ និងទី៣នៃអនុក្រឹត្យនេះ" និងមាត្រា១៣ បានចែងថា "ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ដូចមានចែងក្នុងមាត្រា១២ខាងលើនេះ ត្រូវបូកសរុប និងចុះហត្ថលេខាលើរបាយការណ៍ស្តីពីវត្តមានប្រចាំសប្តាហ៍ និងប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យារបស់អង្គភាពខ្លួនឱ្យបានត្រឹមត្រូវ និងតម្លាភាព..."។

តាមការពិនិត្យបញ្ជីសម្រង់វត្តមានរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពមួយចំនួនរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដូចជាៈ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលពុំបានរៀបចំរបាយការណ៍ស្ដីពីវត្តមានប្រចាំសប្ដាហ៍របស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានោះទេ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរណែនាំដល់អង្គភាព ឬនាយកដ្ឋានដែលស្ថិតក្រោមឱវាទរៀបចំរបាយការណ៍ស្ដីពីវត្តមានប្រចាំសប្ដាហ៍ឱ្យស្របតាមអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងចំណុចនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានស្រាយបំភ្លឺដូចតទៅៈ ករណីរបស់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល នាយកដ្ឋានបុគ្គលិកបានទទួលបញ្ជីវត្តមានប្រចាំខែរបស់អង្គភាពទាំងពីរជាទៀងទាត់នៅក្នុងឆ្នាំ២០២៣ ដោយមិនតម្រូវឱ្យផ្ញើបញ្ជីវត្តមានប្រចាំថ្ងៃ និងសប្ដាហ៍មកនោះទេ។ ជាមួយគ្នានេះ តាមការផ្ដល់ព័ត៌មានត្រឡប់មកវិញរបស់អង្គភាពទាំងពីរពាក់ព័ន្ធនឹងករណីនេះគឺៈ

- ទី១. សម្រាប់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុគឺមានការបូកសរុបបញ្ជីវត្តមានប្រចាំសប្ដាហ៍ជាទៀងទាត់
- ទី២. សម្រាប់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គឺដោយសារមានការផ្លាស់ប្ដូរមន្ត្រីទទួលការងារបូកសរុបបញ្ជីវត្តមានហើយមានការខ្វះចន្លោះក្នុងការបូកសរុបបញ្ជីវត្តមានប្រចាំសប្ដាហ៍ ។

ក្នុងន័យនេះ ដើម្បីឱ្យការអនុវត្តនូវការបំពេញនូវតារាងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាឱ្យបានត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត នាយកដ្ឋានបុគ្គលិកនឹងរៀបចំធ្វើការផ្សព្វផ្សាយបន្តអំពីការបំពេញឱ្យបានគ្រប់ជ្រុងជ្រោយនូវរបាយការណ៍វត្តមានរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.១៩.ការចំណាយ និងកត់ត្រាចំណាយលើការសាងសង់មិនទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ

ឧបសម្ព័ន្ធទី២នៃមាតិកាចំណាយថវិកាភ្ជាប់ជាមួយប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់ពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោមៈ

- អនុគណនី៦១០៥២(ការថែទាំ ជួសជុលអគារ និងប្រាសាទ) ចំណាយជួសជុលអគារ របងអគារ ចំណតរថយន្ត បន្ទប់ទឹក ឃ្លាំង ប្រាសាទ អាកាសយានដ្ឋាន កំពង់ផែ ទីផ្សារ សត្តឃាតដ្ឋាន។ល។
- អនុគណនី២១០៣១(សំណង់ អគារ) ចំណាយលើការទិញ ឬការសាងសង់អគារសាធារណៈ។

តាមរយៈការពិនិត្យ និងធ្វើតេស្តប្រតិបត្តិការចំណាយបុរេប្រទានអភិវឌ្ឍស្ថាប័នរបស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០២៣ លើការសាងសង់អគារសិក្សាថ្មី១ខ្នង មានកម្ពស់៣ជាន់ ចំនួន១៨បន្ទប់ និងបង្គន់អនាម័យចំនួន៥បន្ទប់នៅវិទ្យាល័យព្រែកលៀបស្ថិតនៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញដែលមានទឹកប្រាក់ចំនួន១ ៣៧៨ ៥០០ ០០០រៀលនៃថវិកាបុរេប្រទានអភិវឌ្ឍស្ថាប័នសរុបចំនួន១០ ៩១៨ ៦០០ ០០០រៀល អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការយកថវិកាបុរេប្រទានទៅធ្វើការចំណាយក្នុងការសាងសង់អគារសិក្សាថ្មី១ខ្នង មានកម្ពស់៣ជាន់ចំនួន១៨បន្ទប់ និងបង្គន់អនាម័យចំនួន០៥បន្ទប់នៅវិទ្យាល័យព្រែកលៀបខាងលើមិនទាន់បានត្រឹមត្រូវ និងសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ដែលតម្រូវឱ្យធ្វើការចំណាយ និងកត់ត្រាចំណាយទៅក្នុងអនុគណនី២១០៣១សម្រាប់ការសាងសង់អគារថ្មី។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការពិនិត្យ និងណែនាំដល់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុឱ្យធ្វើការចំណាយ និងកត់ត្រាចំណាយលើការសាងសង់អគារថ្មីឱ្យបានសមស្របតាម ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិថវិកាទូទៅរបស់រដ្ឋ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ នាយកដ្ឋានហិរញ្ញវត្ថុបានបញ្ជាក់ថាករណីនេះគឺជាការងារចាំបាច់ និងបន្ទាន់ដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវសាងសង់អគារសិក្សាថ្មី១ខ្នងដែលមានកម្ពស់៣ជាន់ ១៨បន្ទប់ និងបង្គន់អនាម័យចំនួន៥បន្ទប់នៅវិទ្យាល័យព្រែកលៀប ស្ថិតនៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីប្រែក្លាយវិទ្យាល័យព្រែកលៀបទៅជាសាលារៀនជំនាន់ថ្មី ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃកម្មវិធីកំណែទម្រង់អាទិភាពរបស់ក្រសួង ក៏ដូចជារបស់រាជរដ្ឋាភិបាល។ នាយកដ្ឋានហិរញ្ញវត្ថុទទួលយក និងបន្តពង្រឹងបន្ថែមឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

អាជ្ញាធរសវនកម្មជាតិ បានឃើញការបំភ្លឺរបស់ក្រសួងអប់រំ យុវជន និងកីឡា។ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការបន្តពិនិត្យនូវវឌ្ឍនភាព។

### ៣.១.២០.ការចំណាយតាមនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយមុនការឯកភាពផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច២.១.២.២បានកំណត់ថា " ប្រភេទចំណាយពាក់ព័ន្ធជាមួយសេវាកម្ម(ជំពូក៦១) ចំណាយសម្រាប់អត្ថប្រយោជន៍សង្គម (ជំពូក៦២) និងចំណាយឧបត្ថម្ភធន (ជំពូក៦៥) ដែលមិនតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ប៉ុន្តែមិនមានគោលការណ៍កំណត់ច្បាស់លាស់គឺតម្រូវឱ្យស្នើសុំគោលការណ៍ធានាចំណាយជាមុន ទើបអនុញ្ញាតទូទាត់បាន..." និងសារាចរណែនាំលេខ០១៣ សហវ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ត្រង់ចំណុច២.៤.១ ចុចទី៣ បានបញ្ជាក់ថា "ចំណាយផ្សេងៗដែលត្រូវចាត់ទុកថា មិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធ

កម្ម ហើយដែលមិនស្ថិតនៅក្នុងប្រភេទចំណាយដែលត្រូវបានគូសរំលេចខាងលើ ក្រសួង-ស្ថាប័នត្រូវស្នើសុំធានាចំណាយជាមុន ដោយត្រូវមានការពន្យល់ច្បាស់លាស់អំពីភាពចាំបាច់អំពីគោលការណ៍អនុញ្ញាត ឬ/និងអំពីឯកសារគាំទ្រផ្សេងៗ"។

តាមរយៈការពិនិត្យ និងធ្វើតេស្តលើប្រតិបត្តិការចំណាយតាមនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយ និងចំណាយតាមនីតិវិធីបុរេប្រទានរបស់អង្គភាពថវិការដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិការដ្ឋបាលកណ្តាលមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡាបានចំណាយកិច្ចប្រតិបត្តិការតាមនីតិវិធីស្នើសុំគោលការណ៍ធានាចំណាយ និងចំណាយថវិកាបុរេប្រទានមុនគោលការណ៍ឯកភាពផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការណែនាំដល់អង្គភាពថវិការដ្ឋបាលកណ្តាលមួយចំនួនឱ្យធ្វើការចំណាយថវិកាតាមនីតិវិធីស្នើសុំគោលការណ៍ចំណាយ និងចំណាយថវិកាបុរេប្រទានឱ្យបានសមស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការបញ្ជាក់ថាៈ

❖ នាយកដ្ឋានហិរញ្ញវត្ថុបានបញ្ជាក់ថា ករណីនេះ គឺដោយសារកត្តាពេលវេលា ដែលជាតម្រូវការចាំបាច់ក្នុងការចំណាយ។ ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវការរយៈពេល រីឯការចំណាយគឺជាការងារបន្ទាន់ និងចាំបាច់។ នាយកដ្ឋានហិរញ្ញវត្ថុនឹងពង្រឹងបន្ថែមលើការចំណាយថវិកាតាមនីតិវិធីស្នើសុំគោលការណ៍ចំណាយ និងចំណាយថវិកាបុរេប្រទានឱ្យបានសមស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

❖ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បានទទួលយកនូវអនុសាសន៍ និងសន្យាពង្រឹងការអនុវត្ត និងកែលម្អនូវចំណុចខ្វះខាតនេះ។

❖ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្រ្ត បានធ្វើការបកស្រាយដូចខាងក្រោម៖

១. សោហ៊ុយនៃការប្រើប្រាស់សិទ្ធិចំនួន៣ ០០០ ០០០រៀល (បីលានរៀលគត់) គឺនាយកដ្ឋានត្រូវទិញសិទ្ធិក្នុងការប្រើប្រាស់ ZOOM សម្រាប់ប្រជុំ សិក្ខាសាលាផ្សេងៗ និងទិញសិទ្ធិក្នុងការប្រើប្រាស់ WEBSITE សម្រាប់ដំណើរការទស្សនាវដ្តី CJESER របស់នាយកដ្ឋាន ដើម្បីចូលរួមចំណែកអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា និងចូលរួមអភិវឌ្ឍកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូចនេះរាល់ការទិញសិទ្ធិនៃការប្រើប្រាស់ទាំងនេះ គឺក្រុមហ៊ុនតម្រូវឱ្យអ្នកទិញត្រូវតែបង់ថវិកាជាមុន ទើបក្រុមហ៊ុនផ្តល់សិទ្ធិឱ្យប្រើប្រាស់។

២. សោហ៊ុយនៃការប្រើប្រាស់សេវាទូរគមនាគមន៍ គឺនាយកដ្ឋានបានប្រើប្រាស់ សេវាទូរគមនាគមន៍(អ៊ីនធឺណិត) ពីអ្នកផ្គត់ផ្គង់ឯកជនក្រុមហ៊ុន (NEOCOM) ដោយមាន

កិច្ចព្រមព្រៀងរយៈពេលជាឆ្នាំ និងលក្ខខណ្ឌតម្រូវឱ្យភាគីអ្នកប្រើប្រាស់ត្រូវតែបង់ថវិកាជាមុនចំនួន១ឆ្នាំ(១២ខែ) ទើបក្រុមហ៊ុនផ្តល់សេវាឱ្យប្រើប្រាស់បាន។

❖ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ បានបញ្ជាក់ថា ករណីនេះ កើតឡើងដោយសារកំហុសបច្ចេកទេសក្នុងការចុះកាលបរិច្ឆេទនៃការចំណាយ ដោយវិទ្យាស្ថានបានដាក់លិខិតស្នើសុំគោលការណ៍អនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុហើយ។ ប៉ុន្តែដោយនីតិវិធីត្រូវការពេលវេលាយូរ ហើយវិទ្យាស្ថានត្រូវការអនុវត្តសកម្មភាពអំឡុងពេលសិស្សកំពុងសិក្សាតាមផែនការប្រតិបត្តិរបស់វិទ្យាស្ថាន និងរៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរតាមប្រតិទិន ទើបវិទ្យាស្ថានសម្រេចដំណើរការសកម្មភាពមុនពេលទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជារួម វិទ្យាស្ថានសូមទទួលយកនូវអនុសាសន៍ និងសន្យាពង្រឹងការអនុវត្ត និងកែលម្អនូវចំណុចខ្វះខាតនេះ។

❖ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល បានឯកភាពតាមការរកឃើញ និងទទួលយកដើម្បីធ្វើការកែលម្អតាមអនុសាសន៍។

❖ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានបញ្ជាក់ថា តម្រូវការចាំបាច់សម្ភារសម្រាប់ថែរក្សា និងសម្អាតបរិស្ថានសាលា។ រដ្ឋទេយ្យករ និងអ្នកស្នើសុំចំណាយ មិនទាន់យល់ច្បាស់អំពីនីតិវិធីនៃការចំណាយតាមការស្នើសុំគោលការណ៍ធានាចំណាយ ដោយនេះជាលើកដំបូងដែលអង្គភាពវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានប្រើប្រាស់ថវិកាតាមសំណើសុំគោលការណ៍ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

❖ អគ្គនាយកដ្ឋានយុវជន បានបញ្ជាក់ថា បានស្នើសុំគោលការណ៍ធានាចំណាយ និងចំណាយថវិកាបុរេប្រទាន និងឯកភាពពីថ្នាក់ដឹកនាំផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា មុនពេលរៀបចំកម្មវិធី និងបានរៀបចំស្នើសុំគោលការណ៍ធានាចំណាយ និងចំណាយថវិកាបុរេប្រទាន ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុនកម្មវិធីចាប់ផ្តើម។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២១.ការរៀបចំតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ

សារាចរណែនាំលេខ០០២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មត្រូវចាត់ចែងរៀបចំតារាងទិន្នន័យតម្លៃទីផ្សារនៃសមាសធាតុលទ្ធកម្មសម្រាប់ទុកជាព័ត៌មានបន្ថែមក្នុងការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់ក្រសួងសុខាភិបាល ពុំបានរៀបចំធ្វើនូវតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់ទុកជាព័ត៌មានបន្ថែមក្នុងការវាយតម្លៃជ្រើសរើសក្រុមហ៊ុនចូលរួមដេញថ្លៃនោះឡើយ។

ក្រសួងសុខាភិបាលគួរធ្វើការណែនាំដល់អង្គភាពលទ្ធកម្មរបស់ក្រសួងយកចិត្តទុកដាក់រៀបចំតារាងទិន្នន័យតម្លៃទីផ្សារឱ្យស្របតាមសារាចរណែនាំខាងលើ។

ក្រសួងសុខាភិបាលបានធ្វើការបំភ្លឺជូនថា ក្រសួងសូមទទួលយកនូវអនុសាសន៍ដែលបានលើកឡើង និងជំរុញឱ្យអង្គភាពលទ្ធកម្មរបស់ក្រសួងយកចិត្តទុកដាក់រៀបចំនូវតារាងទិន្នន័យតម្លៃទីផ្សារ ឱ្យស្របតាមសារាចរណែនាំខាងលើ។

អាជ្ញាធរសវនកម្មជាតិបានឃើញនូវការឆ្លើយបំភ្លឺរបស់ក្រសួងសុខាភិបាល។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

**៣.១.២២.ការស្នើសុំទូទាត់ប្រាក់បុរេប្រទានពុំមានសក្ខីបត្រភ្ជាប់មកជាមួយ**

អនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ ត្រង់ជំពូកទី៤ កិច្ចនិយ័តកម្មនៃប្រាក់បុរេប្រទាន មាត្រា១២ កំណត់ថា អាណាប័កគ្រប់ក្រសួង ស្ថាប័ន ត្រូវចាត់តាំងរដ្ឋទេយ្យករដែលមានស្រាប់ដើម្បីទទួលបន្ទុកបន្ថែមក្នុងការតាមដានចំណាយថវិកា និងទទួលខុសត្រូវក្នុងការប្រមូលលិខិតយុត្តិការចំណាយថវិកា (សក្ខីបត្រចំណាយ) សម្រាប់រៀបចំធ្វើអាណត្តិនិយ័តកម្ម និងអាណត្តិបើកប្រាក់បង្គ្រប់ទៅតាមចំនួនទឹកប្រាក់ដែលបានកំណត់ទៅក្នុងលិខិតបុរេប្រទានថវិកា និងមាត្រា១៣ កំណត់ថា រាល់លិខិតយុត្តិការចំណាយ ត្រូវមានចុះហត្ថលេខាបញ្ជាក់ទទួលស្គាល់ពីភាពត្រឹមត្រូវរបស់អាណាប័ក ឬមន្ត្រីដែលមានការប្រគល់សិទ្ធិជំនួស។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងធនធានទឹក និងឧតុនិយមសម្រាប់ការិយបរិច្ឆេទ ២០២៣ បានស្នើសុំទូទាត់ទឹកប្រាក់ក្នុងអាណត្តិនិយ័តកម្ម និងអាណត្តិបើកប្រាក់បង្គ្រប់នៃការចំណាយលើការងារគាំទ្រ ពង្រឹង និងបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ដែលមានទឹកប្រាក់សរុបចំនួន ៨ ០០០ លានរៀល ក្នុងនោះមានតែទឹកប្រាក់ចំនួន ៩៥៥ លានរៀល ដែលមានសក្ខីបត្រចំណាយ រីឯទឹកប្រាក់នៅសល់ចំនួន ៧ ០៤៥ លានរៀលនៃថវិការបស់មន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្តទាំង ២៥ ពុំមានសក្ខីបត្រចំណាយនោះទេ។

ដូចនេះ ក្រសួងធនធានទឹក និងឧតុនិយម គួរអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបនៅការលើកឡើងខាងលើ ក្រសួងធនធានទឹក និងឧតុនិយមសូមទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

ផ្អែកតាមការការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

**៣.១.២៣.ការកក់ប្រាក់ធានាការអនុវត្តនៅថ្ងៃកិច្ចសន្យាចូលជាធរមាន**

ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ត្រង់មាត្រា៦៣ ចែងថា រាល់កិច្ចសន្យាត្រូវមានប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លើកលែងតែកិច្ចសន្យាដែលទទួលបានតាមរយៈវិធីសាស្ត្រលទ្ធកម្មស្ទង់តម្លៃ កិច្ចសន្យាជាមួយនឹងក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជន កិច្ចសន្យាជាមួយនឹងអង្គភាពជំនាញនៃស្ថាប័នរដ្ឋ និងកិច្ចសន្យាជាមួយសហគមន៍។ អ្នកដេញថ្លៃឈ្នះ ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ចសន្យាចូលជាធរមាន។

តាមការចុះធ្វើសវនកម្មនៅក្រុមការងារលទ្ធកម្មនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកដេញថ្លៃឈ្នះបានកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុងថ្ងៃដែលកិច្ចសន្យានេះចូលជាធរមាន។

| ល.រ | បរិយាយ | អ្នកដេញថ្លៃឈ្នះ | ថ្ងៃចុះកិច្ចសន្យា | ផ្សេងៗ |
|---|---|---|---|---|
| ១ | សម្ភារប្រើប្រាស់សម្រាប់មន្ទីរពិសោធន៍ | ០១.សីហា.២០២៣ | ០១.សីហា.២០២៣ | |
| ២ | សម្ភារការិយាល័យ | ២២.ឧសភា.២០២៣ | ២២.ឧសភា.២០២៣ | |

ដូចនេះ ក្រសួងបរិស្ថាន គួរណែនាំអគ្គនាយកដ្ឋានគាំពារបរិស្ថាន ឱ្យអនុវត្តឱ្យបានត្រឹមត្រូវបានត្រឹមត្រូវតាមច្បាប់។

ឆ្លើយតបលើករណីនេះ ក្រសួងបានឆ្លើយបំភ្លឺ និងបញ្ជាក់ជូនថា ដោយសារមានតម្រូវការប្រើប្រាស់សម្ភារបន្ទាន់ទើបក្រុមការងារចង់សម្រួលពេលវេលាឱ្យបានឆាប់រហ័ស។ ម្យ៉ាងវិញទៀត ដោយសារក្រុមការងារលទ្ធកម្មសង្កេតឃើញថា ក្នុងច្បាប់មិនបានបញ្ជាក់ច្បាស់លាស់ពីការកំណត់ចំនួនថ្ងៃក្រោយពេលអ្នកដេញថ្លៃឈ្នះកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ចសន្យាជាធរមាន។ តែទោះជាយ៉ាងណា ក្រសួងសូមទទួលយកនូវកំហុសឆ្គងខាងលើនេះ និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ដើម្បីកែសម្រួលទៅឆ្នាំបន្តបន្ទាប់ទៀត។

ផ្អែកតាមការបំភ្លឺរបស់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.២៤.កង្វះខាតក្នុងការចុះហត្ថលេខាលើក្រមសីលធម៌មុននឹងធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា

សារាចរណែនាំលេខ ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១២ កំណត់ថា ការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃនិងប្រគល់កិច្ចសន្យា ត្រូវធ្វើឡើងជាសម្ងាត់ដោយម៉ឺងម៉ាត់នឹងហ្មត់ចត់ជាទីបំផុតស្របតាមលក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងឯកសារដេញថ្លៃ និងត្រូវផ្អែកលើព័ត៌មានសំខាន់ៗក្នុងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃនិងព័ត៌មានប្តឹងជំទាស់ (ប្រសិនបើមាន)។ គ្រប់សមាជិកគណៈកម្មាធិការលទ្ធកម្មត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌លទ្ធកម្មជាកំហិតមុនការអនុវត្តការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃនិងប្រគល់កិច្ចសន្យាលើគម្រោងលទ្ធកម្មនីមួយៗ។

តាមការចុះធ្វើសវនកម្មនៅអង្គភាពលទ្ធកម្មរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានៃក្រសួងធនធានទឹក និងឧតុនិយមសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានអនុវត្តកិច្ចលទ្ធកម្មស្តីពីគម្រោងផ្គត់ផ្គង់សម្ភារការិយាល័យដែលមានទឹកប្រាក់ក្នុងកិច្ចសន្យាចំនួន ១៤៩ ១៨៥ ០០០រៀល និងសម្ភារបច្ចេកទេសដែលមានទឹកប្រាក់ក្នុងកិច្ចសន្យាចំនួន ១៤៨ ៩៩០ ០០០រៀល ដោយពុំបានធ្វើការចុះហត្ថលេខាលើក្រមសីលធម៌មុនធ្វើការវាយតម្លៃជ្រើសរើសអ្នកដេញ និងប្រគល់កិច្ចសន្យាឡើយ។

ដូចនេះ ក្រសួងធនធានទឹក និងឧតុនិយម គួរណែនាំដល់អង្គភាពលទ្ធកម្មនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបការលើកឡើងខាងលើ ក្រុមការងារលទ្ធកម្មរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជានៃក្រសួងធនធានទឹក និងឧតុនិយមសូមទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

ផ្អែកតាមការការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.២៥.ការស្កេនឯកសារចូលប្រព័ន្ធក្នុងដំណាក់កាលអនុវត្តនីតិវិធីធានាចំណាយ នៅមិនទាន់ស្រប តាមសេចក្ដីណែនាំ

សេចក្តីណែនាំលេខ ០១២ សហវ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយថវិកាចរន្តក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថានតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ត្រង់នីតិវិធីធានាចំណាយកិច្ចលទ្ធកម្ម ការស្កេនចូលក្នុងប្រព័ន្ធ៖

១.លិខិតស្នើសុំថវិការបស់អង្គភាពថវិកា

២.តារាងគម្រោងចំណាយលម្អិតតាមមាតិកាថវិកា និងមុខទំនិញ

៣.ផែនការលទ្ធកម្ម/ផែនការលទ្ធកម្មកែតម្រូវ

៤.គំរូកាតាឡុកទំនិញ

៥.វិក្កយបត្រស្នង់តម្លៃ

តាមការពិនិត្យលើអាណត្តិទូទាត់បរិក្ខារមិនមែនព័ត៌មានវិទ្យា ដែលមានទឹកប្រាក់ចំនួន ៣៥ ៣០០ ០០០ រៀល និងតាមការសាកសួរអ្នកកាន់ប្រព័ន្ធលើដំណាក់កាលស្នើសុំធានាចំណាយកិច្ចលទ្ធកម្មនិងការពិនិត្យមើលប្រព័ន្ធ នៃអង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងបរិស្ថានសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មសង្កេតឃើញថា ក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋាននេះបានធ្វើការស្នើសុំធានាចំណាយលើការទិញបរិក្ខារមិនមែនព័តមានវិទ្យា ដូចជាម៉ាស៊ីនសម្ងួតដៃ ម៉ាស៊ីនកិនកំទេចក្រដាស ទូដែកក្នុងប្រព័ន្ធ ..FMISដោយបានស្កេនឯកសារចូលក្នុងប្រព័ន្ធទាំងអស់ ក្រុមលទ្ធកម្មនេះពុំបានស្កេនគំរូកាតាឡុកទំនិញចូលទៅក្នុងប្រព័ន្ធនៅឡើយទេ។

កត្តានេះ នាំឱ្យការអនុវត្តតាមសេចក្តីណែនាំខាងលើនៅពុំទាន់មានប្រសិទ្ធភាព។

ក្រសួងគួរណែនាំដល់អង្គភាពថវិកានៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមសេចក្តីណែនាំខាងលើ។

ចំពោះករណីនេះ ក្រសួងបរិស្ថានសូមទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងកែប្រែនៅឆ្នាំបន្ទាប់សម្រាប់កង្វះខាតគំរូកាតាឡុកលើការផ្គត់ផ្គង់សម្ភារមិនមែនព័ត៌មានវិទ្យាៈ ម៉ាស៊ីនសំងួតដៃ ម៉ាស៊ីនកិនកំទេចក្រដាស។

អាជ្ញាធរសវនកម្មជាតិបានឃើញការបំភ្លឺរបស់ក្រសួងបរិស្ថាន។ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.២៦.ការប្រគល់ទទួលគម្រោងលទ្ធកម្មទំនិញ សំណង់ និងសេវាពុំមានការអញ្ជើញចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសលេខ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើសៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈត្រង់ចំណុចទី**១៦.២** លក្ខខណ្ឌនៃការប្រគល់ទទួលបានកំណត់ថា "ការប្រគល់ទទួលធ្វើឡើងជាជំហានៗតាមតម្រូវការចាំបាច់ និងក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃប្រគល់កិច្ចសន្យា និងមានការចូលរួមពីតំណាងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ" និងលិខិតលេខ ៤៧៥ សជណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំគោលការណ៍អនុវត្តបន្តលើការបញ្ជាទិញ និងកំណត់ដោយផ្ទាល់លើការបញ្ជាទិញឧបករណ៍សម្ភារបរិក្ខាការផលិតឯកសារ(បោះពុម្ព) និងសេវាផ្សេងៗ ដោយអនុវត្តកិច្ចលទ្ធកម្មសម្របសម្រួលការបើកផ្តល់ថវិកាបុរេប្រទាន១០០%សម្រាប់មុខសញ្ញាចំណាយចាំបាច់មួយចំនួន និងបើកផ្តល់សាច់ប្រាក់បេសកកម្មដោយផ្ទាល់ជូនមន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ ពេលប្រតិបត្តិការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតត្រង់ចំណុច**១** បានកំណត់ថា " អនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអនុវត្តបន្តកិច្ចលទ្ធកម្មសម្របសម្រួលលើការបញ្ជាទិញដោយផ្ទាល់នូវឧបករណ៍សម្ភារបរិក្ខារផលិតឯកសារ(បោះពុម្ព) និងសេវាផ្សេងៗ និងបើកផ្តល់ថវិកាបុរេប្រទាន ១០០%លើមុខសញ្ញាចំណាយចាំបាច់មួយចំនួនសម្រាប់ចំណាយពេលប្រតិបត្តិការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត" ។

តាមរយៈការពិនិត្យ និងផ្ទៀងផ្ទាត់កំណត់ហេតុប្រគល់ទទួល និងបញ្ជីវត្តមានអ្នកចូលរួមប្រគល់ទទួលគម្រោងលទ្ធកម្មផ្គត់ផ្គង់ទំនិញ សំណង់ និងសេវាឆ្នាំ២០២៣ចំនួន៥១គម្រោង ដែលមានទឹកប្រាក់ចំនួន៧៧ ៥៧៥ ៤០០ ០០០រៀលរបស់គណៈកម្មាធិការលទ្ធកម្មនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការប្រគល់ទទួលគម្រោងលទ្ធកម្មខាងលើរបស់គណៈកម្មាធិការលទ្ធកម្មនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំមានការអញ្ជើញចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទេ។

កត្តានេះ នាំឱ្យការប្រគល់ទទួលទំនិញ សំណង់ និងសេវាពុំទាន់បានត្រឹមត្រូវតាមខ្លឹមសារកំណត់នៃប្រកាសខាងលើ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរណែនាំដល់គណៈកម្មាធិការលទ្ធកម្មឱ្យធ្វើការអញ្ជើញតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចូលរួមប្រគល់ទទួលគម្រោងលទ្ធកម្មទំនិញ សំណង់ និងសេវា ដើម្បីធានាបាននៅភាពត្រឹមត្រូវ និងស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ដោយផ្អែកតាមលក្ខណៈដោយឡែកនៃការងាររៀបចំការបោះឆ្នោត ដែលក្នុងនោះមានទាំងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត គឺជាសកម្មភាពបែបប្រជាធិបតេយ្យដ៏ធំមួយក្នុងសង្គម និងជាភារកិច្ចបច្ចេកទេស និងរដ្ឋបាលស្មុគស្មាញដែលត្រូវអនុវត្តក្នុងបរិយាកាសនយោបាយរបស់ប្រទេសជាតិ និងតម្រូវឱ្យ គ.ជ.ប អនុវត្តយ៉ាងម៉ឺងម៉ាត់តាមប្រតិទិន និងច្បាប់កំណត់

ដែលទាមទារត្រូវតែមានតាមផែនការនូវឧបករណ៍ សម្ភារបរិក្ខារ ឯកសារ នឹងត្រូវដឹកជញ្ជូនទៅតាមបណ្តារាជធានី-ខេត្ត រួចបន្តទៅតាមបណ្តាឃុំ-សង្កាត់ និងចុងក្រោយទៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅទូទាំងប្រទេសឱ្យបានទាន់ពេលវេលាស្របតាមប្រតិទិន និងច្បាប់កំណត់ ។

ដោយមូលហេតុនេះទើប គ.ជ.ប បានស្នើសុំគោលការណ៍អនុវត្តលទ្ធកម្មដោយឡែកទៅរាជរដ្ឋាភិបាល ដោយសុំការអនុញ្ញាតអនុវត្តកិច្ចលទ្ធកម្មសម្របសម្រួលលើការបញ្ជាទិញដោយផ្ទាល់នូវឧបករណ៍ សម្ភារបរិក្ខារ ការផលិតឯកសារ (បោះពុម្ព) និងសេវាផ្សេងៗ សម្រាប់ពេលប្រតិបត្តិការ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។ ហើយត្រូវបានរាជរដ្ឋាភិបាលឯកភាពជាគោលការណ៍តាមរយៈលិខិតលេខ ៤៧៥ សជណ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអនុវត្តកិច្ចលទ្ធកម្មសម្របសម្រួលលើការបញ្ជាទិញដោយផ្ទាល់នូវឧបករណ៍ សម្ភារបរិក្ខារ ការផលិតឯកសារ (បោះពុម្ព) និងសេវាផ្សេងៗ ដើម្បីសម្រួលក្នុងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈនៅ គ.ជ.ប សម្រាប់ពេលប្រតិបត្តិការ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ទើបការប្រគល់ទទួលពុំមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូចនេះទាក់ទងនឹងអនុសាសន៍ដែលបានលើកឡើងខាងលើដោយ អាជ្ញាធរសវនកម្មជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំអាចអនុវត្តតាមទាំងស្រុងបានទេ ។ អាជ្ញាធរសវនកម្មជាតិ បានឃើញការបំភ្លឺរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការបន្តពិនិត្យនូវវឌ្ឍនភាព។ ប៉ុន្តែអាជ្ញាធរសវនកម្មជាតិស្នើសុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យធ្វើការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើលិខិតលេខ៤៧៥ សជណ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីករណីសំណើសុំគោលការណ៍អនុវត្តបន្តលើការបញ្ជាទិញ និងកំណត់ដោយផ្ទាល់លើការបញ្ជាទិញឧបករណ៍សម្ភារបរិក្ខា ការផលិតឯកសារ(បោះពុម្ព) និងសេវាផ្សេងៗដើម្បីសម្រួលក្នុងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈឱ្យបានសមស្រប ដើម្បីធានាការអនុវត្តលទ្ធកម្មស្របតាមគោលការណ៍ និងបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ។

**៣.១.២៧.ការប្រគល់ទទួលក្រោយគណៈកម្មការចូលរួម**

សារាចរណែនាំលេខ ០០២ សហវ.អលស ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី១៩ បានបញ្ជាក់ថា "ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារត្រូវប្រព្រឹត្តទៅតាមទីកន្លែង ពេលវេលា បរិមាណ ទំហំ គុណភាព និងលក្ខណៈបច្ចេកទេស ដូចមានកំណត់ក្នុងកិច្ចសន្យា។ លទ្ធផលនៃការប្រគល់ទទួលឬការវាយតម្លៃលទ្ធផលការងារ ត្រូវកត់ត្រាឱ្យបានត្រឹមត្រូវនៅក្នុងកំណត់ហេតុប្រគល់ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងារ ហើយត្រូវមានការចុះហត្ថលេខាទទួលខុសត្រូវពីគ្រប់សមាជិកគណៈកម្មការប្រគល់ទទួល និងអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ។ ការប្រគល់ទទួល ឬការវាយតម្លៃលទ្ធផលការងារ "ខ្យល់" (គ្មានទំនិញ សំណង់ ឬសេវា) ឬមានបរិមាណទំនិញ ទំហំការងារ ឬសេវាមិនគ្រប់ចំនួន និង/ឬមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គឺជាអំពើយុបយិតដែលត្រូវចៀសវាងឱ្យបានដាច់ខាត"។

តាមការចុះធ្វើសវនកម្មនៅក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្រ្ត នៃក្រសួងបរិស្ថាន និងអង្គភាពលទកម្មរបស់អាជ្ញាធរទន្លេសាបនៃក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា៖

- ក្រុមលទ្ធកម្មនៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្រ្ត នៃក្រសួងបរិស្ថានបាន ធ្វើការប្រគល់ទទួលសៀវភៅ និងក្បាលលិខិតមុនពេលមានសម្ភារជាក់ស្តែងដូចខាងក្រោម៖

| ល.រ | បរិយាយ | ថ្ងៃខែប្រគល់ទទួល | ថ្ងៃខែឆ្នាំឃ្លាំងទទួលបានពីក្រុមហ៊ុន |
|---|---|---|---|
| ១ | ការបោះពុម្ពសៀវភៅនិងក្បាលលិខិត | ២៧.មិថុនា.២០២៣ | ២៨.មិថុនា.២០២៣ |

- អង្គភាពលទ្ធកម្មរបស់អាជ្ញាធរទន្លេសាបនៃក្រសួងធនធានទឹក និងឧតុនិយម ព្រមទាំង គណៈកម្មាធិការអន្តរក្រសួងបានធ្វើការប្រគល់ទទួលមុនពេលមានសម្ភារជាក់ស្តែង ដូចមានក្នុងតារាង ខាងក្រោម៖

| ល.រ | បរិយាយ | ថ្ងៃខែឆ្នាំប្រគល់ទទួល | ថ្ងៃខែឆ្នាំចូលឃ្លាំង |
|---|---|---|---|
| ១ | ការបោះពុម្ពសៀវភៅផែនការសកម្មភាពការងារ ទស្សនាវដ្តីស្រោមសំបុត្រ សៀវភៅកត់ត្រា | ២៦.មេសា.២០២៣ | ០៥.ឧសភា.២០២៣ |

ដូចនេះ ក្រសួងបរិស្ថាន និងក្រសួងធនធានទឹក និងឧតុនិយម គួរណែនាំដល់អង្គភាព ក្រោម ឱវាទអនុវត្តឱ្យបានត្រឹមត្រូវបានត្រឹមត្រូវតាមច្បាប់។

ឆ្លើយតបនៅការលើកឡើងខាងលើ ក្រសួងទាំងពីរបានទទួលយកនូវលទ្ធផលដែលបានរក ឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

ផ្អែកតាមការបំភ្លឺរបស់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

### ៣.១.២៨.ការអនុវត្តប្រព័ន្ធFMIS

ក្នុងឆ្នាំ២០២៤នេះ ក្រសួងផែនការបានអនុវត្តប្រព័ន្ធ FMIS ទៅលើមុខងារចំនួន៣ មុខងារ មានដូចជា៖

- មុខងារគណនីត្រូវសងក្នុងប្រព័ន្ធ FMIS (AP Account Payable) ផ្អែកតាមសៀវភៅ សិក្សាអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រង់មុខងារ គណនីត្រូវសង គឺត្រូវបានប្រើប្រាស់សម្រាប់កត់ត្រានូវគ្រប់ប្រតិបត្តិការចំណាយរបស់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកា និងមានលំហូរការងាររហូតដល់ការទូទាត់ ដោយមានការបោះផ្សាយចេញជាមូលប្ប ទានប័ត្រ ដោយអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រាល់ព័ត៌មានស្នើសុំ ចំណាយដែលមាននៅលើសន្លឹកអាណត្តិ គឺត្រូវបានកត់ត្រាចូលក្នុងមុខងារគណនីត្រូវសង ដែលរួមមាន៖

ចំណាយទូទាត់ត្រង់ ទូទាត់កិច្ចលទ្ធកម្ម និងអាណត្តិជម្រះបុរេប្រទាន/វជ្ជទេយ្យបុរេប្រទាន។ល។ ដំណើរការកត់ត្រាអាណត្តិបើកប្រាក់បុរេប្រទាន/វជ្ជទេយ្យបុរេប្រទាន ដោយត្រូវកត់ត្រាព័ត៌មានអាណត្តិត្រួតពិនិត្យថវិកា របាយការណ៍សរុបអាណត្តិ (Q03-AP) គឺជាទម្រង់របាយការណ៍ទាញយកមកភ្លាមៗ បន្ទាប់ពីអ្នកប្រើប្រាស់បានបញ្ចូលប្រតិបត្តិការចូលទៅក្នុងប្រព័ន្ធរួចរាល់។

- មុខងារបញ្ជាទិញក្នុងប្រព័ន្ធFMIS (PO Purchase Order) ផ្អែកតាមសៀវភៅសិក្សាអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រង់មុខងារការទិញក្នុងប្រព័ន្ធ FMIS គឺជាមុខងារប្រើប្រាស់សម្រាប់កត់ត្រាការបញ្ជាទិញផ្សេងៗ ដូចជា៖ ការបង្កើតសំណើធានាចំណាយ ការទិញដោយអនុវត្តកិច្ចលទ្ធកម្ម និងការទិញដោយមិនអនុវត្តកិច្ចលទ្ធកម្មសម្រាប់ក្រសួង ស្ថាប័ន។ ដំណើរការបង្កើតការបញ្ជាទិញ មានបង្ហាញការបង្កើតការបញ្ជាទិញ ការត្រួតពិនិត្យសុពលភាពថវិកា ការកែសម្រួល ការលុប ការបដិសេធ បញ្ជាទិញ និងការអនុម័តការបញ្ជាទិញ។ ដំណើរការបង្កើតបង្កាន់ដៃមានបង្ហាញការបង្កើតបង្កាន់ដៃ ដំណើរការត្រួតពិនិត្យតាមរយៈ Online។ ដំណើរការថែទាំចម្បងទៅលើការបញ្ជាទិញមានបង្ហាញពីការកត់ត្រាទំនិញចម្បង អ្នកសំណើ អ្នកទិញ។ ចំពោះរបាយការណ៍សំណើ (សំណើសុំធានាចំណាយ) (Q02-REQ) ជារបាយការណ៍មួយដែលអាចផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងការស្វែងរកព័ត៌មាន និងការធ្វើរបាយការណ៍នានាទៅតាមតម្រូវការ។ របាយការណ៍នេះ គឺជារបាយការណ៍ទៅតាមតម្រូវការ ដែលបានបង្ហាញនូវព័ត៌មានជាច្រើនសម្រាប់អ្នកប្រើប្រាស់ដូចជា៖ កាលបរិច្ឆេទនៃសំណើ ឈ្មោះអ្នកបង្កើតសំណើ ប្រភពនៃអ្នកបង្កើតសំណើ ស្ថានភាពសំណើ មុខទំនិញនៃសំណើ ទឹកប្រាក់មុខទំនិញនីមួយៗ មាតិកាថវិកានៃការស្នើសុំចំណាយជាដើម។ រីឯរបាយការណ៍ការបញ្ជាទិញ (Q01-PO) ជារបាយការណ៍ដែលបង្ហាញពីអង្គភាព ការងារ អង្គភាពប្រតិបត្តិប្រភពដើមស្ថានភាពការបញ្ជាទិញ និងជារបាយការណ៍បង្ហាញការបញ្ជាទិញគ្រប់ស្ថានភាពការបញ្ជាទិញទាំងអស់។ ក្នុងដំណើរការអនុវត្តតាមប្រព័ន្ធ FMIS មុខងារបញ្ជាទិញបានបង្ហាញពីការបង្កើតសំណើ ការបង្កើតការបញ្ជាទិញ ការអនុម័តក្នុងមុខងារការទិញ និងរបាយការណ៍ (របាយការណ៍សំណើ និងរបាយការណ៍ការបញ្ជាទិញ)។

- មុខងារវិភាជន៍ថវិកាក្នុងប្រព័ន្ធ FMIS (BA Budget Allocated) ផ្អែកតាមសៀវភៅសិក្សាអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ត្រង់មុខងារវិភាជន៍ថវិកា គឺជាមុខងារមួយដែលកត់ត្រាច្បាប់ថវិការបស់បណ្តាក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពថវិកាថ្នាក់ក្រោមជាតិដែលបានអនុម័តដោយរដ្ឋសភា។ នៅក្នុងកំឡុងឆ្នាំនីមួយៗ បណ្តាក្រសួង ស្ថាប័ន មន្ទីរជំនាញអាចធ្វើការស្នើសុំនិយ័ត/ផ្ទេរបន្ថែម ឬកែតម្រូវឥណទានបានចាប់ពីដើមត្រីមាសទី២ រហូតដល់បំណាច់ឆ្នាំ។ ម្យ៉ាងទៀតមុខងារនេះ ជាមុខងារស្នូលនៅក្នុងប្រព័ន្ធ ពីព្រោះថា ការធ្វើធានាចំណាយបឋម ការធ្វើធានាចំណាយ ការបញ្ជាទិញ និងការចំណាយត្រូវការត្រួតពិនិត្យថវិកាជាមុនសិន ដើម្បីធានាថារាល់ប្រតិបត្តិការចំណាយទាំងអស់ មានថវិកាគ្រប់គ្រាន់ក្នុងការចំណាយ។ ប្រព័ន្ធFMIS បានបង្ហាញពីដំណើរការទិន្នានុប្បវត្តិថវិកា ការថែទាំថវិកា ការថែទាំទិន្នានុប្បវត្តិថវិកា ដំណើរការចុងការិយបរិច្ឆេទ។ ចំពោះរបាយការណ៍វិភាជន៍ថវិកា (Q06-BA) គឺជារបាយការណ៍តាមដានប្រតិបត្តិការប្រចាំថ្ងៃ

ដើម្បីត្រួតពិនិត្យឡើងវិញ និងតាមដានចំពោះប្រតិបត្តិការទាំងឡាយណាដែលបានបង្កើត ហើយមិនទាន់បានអនុម័ត មិនទាន់ចុះចូលទៅក្នុងបញ្ជី និងប្រតិបត្តិការដែលចុះចូលក្នុងបញ្ជីរួច (Posted) ព្រមទាំងប្រតិបត្តិការដែលមានកំហុសឆ្គង ដើម្បីធ្វើការកែតម្រូវនៅក្នុងប្រព័ន្ធ។ ក្រោយពីច្បាប់ថវិកាត្រូវបានរដ្ឋសភាអនុម័តរួច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ចូលឥណទានថវិការបស់ក្រសួងផែនការចូលក្នុងប្រព័ន្ធFMIS។ បន្ទាប់មកមន្ត្រីទទួលបន្ទុកមុខងារវិភាជន៍ថវិកា បានត្រួតពិនិត្យ និងទាញយករបាយការណ៍ធ្វើការបែងចែកឥណទានជាប្រភេទទូទាត់ត្រង់ ឬរជ្ជទេយ្យបុរេប្រទាន។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងផែនការបានប្រើប្រាស់ប្រព័ន្ធFMIS បានតែនៅក្នុងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងនៅអង្គភាពលទ្ធកម្ម ហើយការប្រើប្រាស់ប្រព័ន្ធFMIS ក៏ជួបនៅបញ្ហាប្រឈមមួយចំនួន ដូចជា៖ មុខងារគណនីត្រូវសងក្នុងប្រព័ន្ធ FMIS (AP Account Payable) និងមុខងារបញ្ជាទិញក្នុងប្រព័ន្ធFMIS (PO Purchase Order) ការអនុវត្តប្រព័ន្ធ FMIS នៅពុំទាន់ទាញរបាយការណ៍មកប្រើប្រាស់បាន។ ដោយឡែកមុខងារវិភាជន៍ថវិកាក្នុងប្រព័ន្ធ FMIS (BA Budget Allocated) ត្រង់R20 របាយការណ៍ចំណូល ចំណាយថវិកា ការទាញរបាយការណ៍មិនអាច Zoom in-out បាន និងពិបាកក្នុងការព្រីនចេញ ដើម្បីផ្ទៀងផ្ទាត់ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ។

អាស្រ័យហេតុនេះ ក្រសួងផែនការ គួរសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុវត្តតាមខ្លឹមសារនៃសៀវភៅសិក្សាអំពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS ឱ្យមានប្រសិទ្ធភាព។

ចំពោះចំណុចនេះ ក្រសួងផែនការសូមឯកភាព ចំពោះការសង្កេតរបស់អាជ្ញាធរសវនកម្មជាតិ ចំពោះដំណើរការការងារតាមប្រព័ន្ធ FMIS នៅក្រសួងផែនការ គឺនៅមានកម្រិតចំពោះការងារមួយចំនួនដូចជា៖ ការទាញយករបាយការណ៍ចេញពីប្រព័ន្ធ FMIS ព្រមទាំងមានការលំបាកក្នុង Zoom In និង Zoom Out មូលហេតុដោយសារទម្រង់ប្រព័ន្ធនេះជាទម្រង់ស្តង់ដារជាប់ជាមួយប្រព័ន្ធ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចនេះ ក្រសួងផែនការមិនមានលទ្ធភាពក្នុងការកែប្រែទៅលើទម្រង់របាយការណ៍ក្នុងប្រព័ន្ធ FMIS នេះបានឡើយ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.២៩.ការកត់ត្រាសម្ភារបរិក្ខារព័ត៌មានវិទ្យាចូលក្នុងបញ្ជីសារពើភណ្ឌមិនទាន់បានត្រឹមត្រូវតាមតម្លៃជាក់ស្តែង

អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់មាត្រា១៩ ចែងថា "បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវឆ្លុះបញ្ចាំងជាប្រចាំនូវព័ត៌មានពិតប្រាកដនៃទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្រោមការកាន់កាប់របស់អាជ្ញាធរកាន់កាប់ និងត្រូវកត់ត្រាជាអាទិ៍ទៅតាមប្រភេទ លក្ខណៈ តម្លៃ និងស្ថានភាពនៃទ្រព្យសម្បត្តិនោះ។

តាមការចុះធ្វើសវនកម្មនៅអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាននៃក្រសួងបរិស្ថាន សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាននៅពុំទាន់បានកត់ត្រាតម្លៃទ្រព្យសម្បត្តិរដ្ឋមួយចំនួនតូចឱ្យបានត្រឹមត្រូវតាមតម្លៃជាក់ស្តែងដែលបានទិញនោះទេ។ ដូចនេះ ក្រសួងបរិស្ថានគួរណែនាំដល់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបករណីនេះ ក្រសួងសូមធ្វើការបំភ្លឺជូនអាជ្ញាធរសវនកម្មជាតិថា កន្លងមកក្រុមការងារលទ្ធកម្មបានអនុវត្តបញ្ចូលតម្លៃមុខទំនិញទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មានលក្ខណៈល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែករណីចំពោះមុខនេះគឺជាកំហុសឆ្គងបច្ចេកទេសដោយអចេតនាក្នុងការបញ្ចូលទិន្នន័យ។ ក្រសួងសូមទទួលយក និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ហើយសូមបញ្ជាក់ជូនថា ករណីនេះ ក្រុមការងារបានកែសម្រួលត្រឹមត្រូវតាមតម្លៃនៃកិច្ចសន្យាទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួចរាល់ហើយផងដែរ។

ផ្អែកតាមការបំភ្លឺរបស់របស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដាននូវវឌ្ឍនភាព។

**៣.១.៣០.ការរៀបចំរបាយការណ៍ផ្ទៀងផ្ទាត់ចំណាយថវិកាឆ្នាំ២០២៣**

សារាចរណែនាំបន្ថែមលេខ០០៣ សហវ.សរណ.អរតន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយ័តកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៣ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) សម្រាប់ថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ត្រង់ចំណុច**ខ លេខ២** បានបញ្ជាក់ថា " ក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវបូកសរុបផ្ទៀងផ្ទាត់តួលេខចំណាយថវិកាជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស) ហើយត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកា ដោយរួមបញ្ចូលតួលេខចំណាយថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត ដែលស្ថិតនៅក្រោមឱវាទរួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានរតនាគារជាតិ-នាយកដ្ឋានចំណាយថវិកា និងអគ្គនាយកដ្ឋានថវិកា-នាយកដ្ឋានថវិកានិយតកម្ម) ឱ្យបានមុនថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ជាកំហិត"។

តាមរយៈការពិនិត្យសេចក្តីព្រាងរបាយការណ៍សម្រេចទូទាត់ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣(បណ្តោះអាសន្ន)របស់ក្រសួងព័ត៌មាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតមកត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ ក្រសួងព័ត៌មាននៅមានភាពយឺតយ៉ាវក្នុងការផ្ទៀងផ្ទាត់របាយការណ៍សម្រេចទូទាត់ថវិកាជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលាស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មានគួរធ្វើការពន្លឿនការរៀបចំរបាយការណ៍ផ្ទូផ្ទងសម្រេចទូទាត់ថវិកាជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ឱ្យបានទាន់ពេលវេលាស្របតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងព័ត៌មានបានធ្វើការបញ្ជាក់ថា នាយកដ្ឋានផែនការ គណនេយ្យ និងហិរញ្ញកិច្ច ទទួលស្គាល់ថា មានភាពយឺតយ៉ាវក្នុងការផ្ទូផ្ទងរបាយការណ៍សម្រេចទូទាត់ថវិកាជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា ដោយសារនៅចុងឆ្នាំមានឯកសារមួយចំនួនជាប់នៅក្នុងប្រព័ន្ធ FMIS ដូចនេះត្រូវរង់ចាំទាល់តែចេញឯកសារពីប្រព័ន្ធFMISអស់ ទើបអាចផ្ទូផ្ទងរបាយការណ៍សម្រេចទូទាត់ថវិកាជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀត។

### ៣.១.៣១.ការផ្ញើរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋានមកអាជ្ញាធរសវនកម្មជាតិ

អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ត្រង់ជំពូកទី៣ មាត្រា៧ ចំណុច១៨ បានចែងថា "សនកម្មផ្ទៃក្នុងត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ" និងអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង ត្រង់ជំពូក២ មាត្រា៥ ចំណុចទី១៨ បានចែងថា "អង្គភាពសវនកម្មផ្ទៃក្នុងមានភារកិច្ចដូចខាងក្រោម៖ ផ្ញើរបាយការណ៍សវនកម្មជូនសវនដ្ឋាននីមួយៗដែលមានកាតព្វកិច្ចកែលម្អតាមអនុសាសន៍ ដោយចម្លងជូនរបាយការណ៍ប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ លើកលែងតែករណីមានបទប្បញ្ញត្តិដោយឡែកដែលចែងផ្សេងពីនេះ"។

តាមការពិនិត្យរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារបន្ត និងតារាងកម្មវិធីសវនកម្មបីឆ្នាំរំកិល២០២៣-២០២៥ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងព័ត៌មាន និងផែនការសវនកម្មប្រចាំឆ្នាំ២០២៣ និងរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋាន និងពិនិត្យលើរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ២០២៣ របស់អង្គភាពថវិកានាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងព័ត៌មាន និងក្រសួងអប់រំ យុវជន និងកីឡាពុំទាន់បានផ្ញើរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋានរបស់ខ្លួនជូនអាជ្ញាធរសវនកម្មជាតិនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងព័ត៌មាន និងក្រសួងអប់រំ យុវជន និងកីឡា គួរណែនាំដល់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរៀបចំបូកសរុបរបាយការណ៍សវនកម្ម និងសេចក្តីសន្និដ្ឋានរបស់សវនដ្ឋានប្រចាំឆ្នាំ ដើម្បីចម្លងជូនមកអាជ្ញាធរសវនកម្មជាតិឱ្យបានទាន់ពេលវេលា និងស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងព័ត៌មាន និងក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបញ្ជាក់ថា នាយកដ្ឋានសវនកម្មផ្ទៃក្នុងសូមទទួលយកចំណុចខ្វះខាតខាងលើ និងកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានវឌ្ឍនភាព។

## ៣.២. ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១.ការប្រកាសពន្ធឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ

ច្បាប់ស្តីពីសារពើពន្ធបានចែងថា ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានកំណត់តាមអត្រា ១០(ដប់)ភាគរយនៃថ្លៃឈ្នួលអចលនទ្រព្យ។ កម្មសិទ្ធិករត្រូវដាក់លិខិតបង់ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់។ អ្នកជាប់ពន្ធក៏ត្រូវបានចាត់ទុកថាមានការឆ្វេសប្រហែស ប្រសិនបើប្រាក់ពន្ធមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់។

តាមការធ្វើតេស្តលើសំណុំឯកសារប្រមូលពន្ធឈ្នួលអចលនទ្រព្យ និងចលនទ្រព្យចំនួន២២៦ និងសហគ្រាសដែលបានចុះបញ្ជីថ្មីក្នុងឆ្នាំ២០២៣ លើកិច្ចសន្យាជួលអចលនទ្រព្យចំនួន២២០ នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន ១៧ ក្នុងចំណោមអ្នកជាប់ពន្ធខាងលើ ពុំទាន់បានប្រកាសពន្ធឈ្នួលអចលនទ្រព្យ និងចលនទ្រព្យឱ្យបានត្រឹមត្រូវ។

អាស្រ័យហេតុនេះ អាចនាំឱ្យបាត់បង់ប្រាក់ពន្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការបន្ថែមទៀតលើអ្នកជាប់ពន្ធដែលពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាពតាមអនុសាសន៍ និងណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យកែលម្អ និងតាមដានការអនុវត្តការងារដែលមានភាពខ្វះចន្លោះតាមការលើកឡើង ព្រមទាំងយកលទ្ធផលនេះ ចូលរួមជាចំណែកមួយសម្រាប់ការវាយតម្លៃនូវគុណភាពមន្ត្រីពន្ធដារតាមរយៈប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធកំណត់ចំណាត់ថ្នាក់នៃកម្រិតប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ប្រធានអង្គភាព (Merit និង Demerit System-MDS) ចំពោះអង្គភាពពន្ធដារណាដែលអនុវត្តការងារនេះមិនទាន់បានល្អ និងលើកទឹកចិត្តបន្ថែមទៀតដល់អង្គភាពពន្ធដារទាំងឡាយណាដែលសម្រេចការងារបានល្អរួចហើយ។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.២.២.ការបង់ចំណូលភាស៊ីផ្សារ

ដើម្បីប្រមូលចំណូលពីអ្នកវិនិយោគសាងសង់ផ្សារនានា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសៀវភៅបន្ទុកស្តីពីការដាក់ទុនវិនិយោគសាងសង់ផ្សារជប់-ថ្មល់ទទឹង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣

ត្រង់ប្រការ៥ បានតម្រូវឱ្យអ្នកវិនិយោគបង់ចំណូលចូលថវិកាខេត្តជារៀងរាល់ឆ្នាំតាមប្រតិទិននៃខែនីមួយៗក្នុងមួយឆ្នាំ គឺយ៉ាងយូររៀងរាល់ថ្ងៃទី២០នៃខែ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមខែមីនា ឆ្នាំ២០២៤ អ្នកវិនិយោគ និងធ្វើអាជីវកម្មភាស៊ីផ្សារជប់ ថ្នល់ទទឹង នៅពុំទាន់បានបង់ចំណូលពីការធ្វើអាជីវកម្មភាស៊ីផ្សារជប់ ថ្នល់ទទឹង ចំនួន ១១ លានរៀល សម្រាប់ឆ្នាំ២០២៣ នៅឡើយ ទោះបីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តត្បូងឃ្មុំបានចេញលិខិតក្រើនរំលឹកលេខ ៨៧០ សហវ.ខតឃ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការពន្លឿនបង់ចំណូលពីការធ្វើអាជីវកម្មផ្សារជប់ ថ្នល់ទទឹងក៏ដោយ។

កត្តានេះ អាចនាំឲ្យបាត់បង់ចំណូលខេត្តជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តត្បូងឃ្មុំ គួរណែនាំឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តជំរុញ និងចាត់វិធានការតឹងរឹងដើម្បីឱ្យអ្នកវិនិយោគ និងធ្វើអាជីវកម្មភាស៊ីបង់ចំណូលចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា។

ឆ្លើយតបចំពោះការលើកឡើងខាងលើនេះ រដ្ឋបាលខេត្តត្បូងឃ្មុំបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តត្បូងឃ្មុំនឹងខិតខំពង្រឹង និងកែលម្អនូវចំណុចខ្វះខាតទាំងឡាយពាក់ព័ន្ធ ដែលមិនទាន់ស្របតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិ ដែលអាជ្ញាធរសវនកម្មជាតិបានធ្វើការកត់សម្គាល់ឃើញក្នុងអំឡុងពេលធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៣។ រដ្ឋបាលខេត្តនឹងអនុវត្តឆ្នាំបន្តបន្ទាប់ឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា រដ្ឋបាលខេត្តត្បូងឃ្មុំនឹងអនុវត្តឱ្យបានត្រឹមត្រូវតាមសៀវភៅបន្ទុកខាងលើ។

**៣.២.៣.ការពុំបានប្រមូលចំណូលពីប្រភពបំពុលបរិស្ថាន**

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ១០៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ស្តីពីការផ្តល់សេវាសាធារណៈ និងការផាកពិន័យជាប្រាក់ដោយក្រសួងបរិស្ថាន។

ប្រកាសលេខ ៤២៦ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងបរិស្ថាន ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ ត្រង់ប្រការ៧ បានចែងថា "ការិយាល័យគាំពារបរិស្ថាន មានតួនាទី និងភារកិច្ចក្នុងការចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើទីតាំង ឬមធ្យោបាយនៃផលិតកម្ម អាជីវកម្ម ឬសេវាកម្មដែលពាក់ព័ន្ធការដឹកជញ្ជូន ការផលិត ការបង្កើត ការប្រើប្រាស់ ការកែច្នៃ ការធ្វើព្រឹត្តកម្ម និងការបោះបង់ចោល ឬការបញ្ចេញចោល សំណល់ និងសារធាតុគ្រោះថ្នាក់ ដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា"។

សម្រាប់ការិយបរិច្ឆេទ ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តឧត្តរមានជ័យមានមូលដ្ឋានអាជីវកម្មសរុបចំនួន៣៤៧ទីតាំង ប៉ុន្តែមន្ទីរបរិស្ថានមិនបានប្រមូលចំណូលពីប្រភពបំពុលបរិស្ថាននៅឡើយ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត គួរជំរុញមន្ទីរបរិស្ថានខិតខំប្រមូលចំណូលពីប្រភពបំពុលបរិស្ថាន។

ឆ្លើយតបនឹងការលើកឡើង រដ្ឋបាលខេត្តឧត្តរមានជ័យ បានទទួលយកអនុសាសន៍ និងព្យាយាមកត់ត្រាតាមការិយបរិច្ឆេទឱ្យអស់លទ្ធភាព។

ផ្អែកតាមការបំភ្លឺនេះ រដ្ឋបាលខេត្តឧត្តរមានជ័យ បានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ។

**៣.២.៤.ការជំរុញការស្នើសុំលិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់ស្ថានីយប្រេងឥន្ធនៈ**

ប្រកាសលេខ ០២១៤ រថ.នក.ប្រក ចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងរ៉ែ និងថាមពលស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីមទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ត្រង់ប្រការ៤ បានបញ្ជាក់ថា "ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាល រាជធានី ខេត្ត នូវមុខងារក្នុងការទទួលពិនិត្យវាយតម្លៃការស្នើសុំ និងសម្រេចផ្តល់ និងដកហូតលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ដូចខាងក្រោម៖

១. លិខិតអនុញ្ញាតប្រព្រឹត្តកម្ម។
២. លិខិតអនុញ្ញាតសន្និធិ។
៣. លិខិតអនុញ្ញាតដឹកជញ្ជូនក្រៅបំពង់បង្ហូរ។
៤. លិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈនិងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ

ត្រង់ប្រការ៥ និងប្រការ៦នៃប្រកាសខាងលើបានបញ្ជាក់ថា "រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតសម្រាប់សកម្មភាពផ្នែកដោនស្ទ្រីម ត្រូវទៅដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលជាមូលដ្ឋានអាជីវកម្មរបស់អ្នកស្នើសុំ។ អភិបាលរាជធានី ខេត្ត ត្រូវចាត់ឱ្យមានការពិនិត្យផ្ទៀងផ្ទាត់លើសំណើសុំលិខិតបច្ចេកទេសសុវត្ថិភាពចេញដោយក្រសួងរ៉ែ និងថាមពល និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀតមុននឹងសម្រេច"។

តាមការធ្វើសវនកម្មនៅខេត្តចំនួន០៧ សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅមានស្ថានីយប្រេងឥន្ធនៈមួយចំនួនកំពុងដំណើរការអាជីវកម្មដោយពុំមានលិខិតអនុញ្ញាតពាណិជ្ជកម្មឡើយ ករណីនេះមាននៅក្នុងដែនដីនៃខេត្ត៖

១. ស្វាយរៀងមានចំនួន ២២ស្ថានីយ
២. កំពតមានចំនួន ១៦០ស្ថានីយ
៣. កំពង់ឆ្នាំងមានចំនួន៤០ស្ថានីយ
៤. ស្ទឹងត្រែងមានចំនួន១៤ស្ថានីយ
៥. សៀមរាបមានចំនួន៣២២ស្ថានីយ
៦. កំពង់ធំមានចំនួន៧៩ស្ថានីយ និង
៧. កំពង់ចាមមានចំនួន៤០ស្ថានីយ

ដោយសារកង្វះការជំរុញលើការស្នើសុំលិខិតអនុញ្ញាតពាណិជ្ជកម្មសម្រាប់ស្ថានីយប្រេងឥន្ធនៈ នាំឱ្យស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈមួយចំនួនដំណើរការអាជីវកម្មដោយពុំមានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ឡើយ ហើយនាំឱ្យការអនុវត្តប្រកាសខាងលើពុំមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំមន្ទីររ៉ែ និងថាមពលឱ្យចុះជំរុញដល់ម្ចាស់ស្ថានីយប្រេងឥន្ធនៈមកដាក់ពាក្យសុំនៅច្រកចេញចូលតែមួយនៅរដ្ឋបាលខេត្តឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តបានឯកភាព និងសន្យាថានឹងណែនាំមន្ទីររ៉ែ និងថាមពលឱ្យចុះជំរុញម្ចាស់ស្ថានីយប្រេងឱ្យមកដាក់ពាក្យនៅច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្ត។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ការអនុវត្តការងារនេះនឹងអនុវត្តបានល្អនាពេលខាងមុខ ហើយអាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៥.ការរៀបចំកិច្ចបញ្ជិកាគណនេយ្យរបស់រជ្ជទេយ្យករចំណូល

សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលក្រោមជាតិ ត្រង់ចំណុច៣ បានបញ្ជាក់ថា "បញ្ជីគណនេយ្យរបស់រជ្ជទេយ្យករចំណូល មាន ៖

- ចំណុច៣.១. បញ្ជីបេឡាសាច់ប្រាក់ប្រើសម្រាប់កត់ត្រានូវចំនួនទឹកប្រាក់រជ្ជទេយ្យចំណូលដែលបានទទួលពីអតិថិជន និងចំនួនទឹកប្រាក់ដែលបានចំណាយ និងចំនួនទឹកប្រាក់ដែលនៅសល់។

- ចំណុច ៣.១.១. បញ្ជីបេឡាសាច់ប្រាក់នៅធនាគារ៖ កត់ត្រាដោយយោងប្រកាសឥណពន្ធ ឬបណ្ណដកប្រាក់ប្រកាសឥណទាន ឬប័ណ្ណបង់ប្រាក់ និងចំនួនទឹកប្រាក់ដែលនៅសល់។

- ចំណុច ៣.១.២. បញ្ជីបេឡាសាច់ប្រាក់ក្នុងដៃ ៖ កត់ត្រាដោយយោងប័ណ្ណចំណូល និងប័ណ្ណចំណាយ។

- ចំណុច ៣.២.១. ផ្នែកទិន្នានុប្បវត្តិទូទៅ៖ សម្រាប់កត់ត្រាគ្រប់ប្រតិបត្តិការរជ្ជទេយ្យចំណូលប្រចាំថ្ងៃទៅតាមលំដាប់លំដោយមានរៀបរាប់ពីលេខរៀង កាលបរិច្ឆេទ ឯកសារយោង (សលាប័ត្រចុះលេខនា) លេខគណនី ឬអនុគណនី បរិយាយទឹកប្រាក់ខាងឥណពន្ធ និងទឹកប្រាក់ខាងឥណទាន។ ទិន្នានុប្បវត្តិទូទៅត្រូវបូកសរុបនៅដំណាច់ខែនីមួយៗ។ សរុបចលនាខាងឥណពន្ធ និងសរុបចលនាខាងឥណទាននៃទិន្នានុប្បវត្តិទូទៅត្រូវស្មើគ្នា។

- ចំណុច ៣.២.២. ផ្នែកសៀវភៅធំ៖ សម្រាប់កត់ត្រាប្រតិបត្តិការរជ្ជទេយ្យចំណូលប្រចាំថ្ងៃទៅតាមផ្នែកខាងឥណពន្ធ និងផ្នែកខាងឥណទាននៃគណនេយ្យរជ្ជទេយ្យចំណូលនីមួយៗដែលពាក់ព័ន្ធ។ សៀវភៅធំត្រូវបូកសរុបនៅដំណាច់ខែនីមួយៗ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំតារាងតុល្យភាពគណនីរជ្ជទេយ្យចំណូលប្រចាំខែ និងប្រចាំឆ្នាំ។

សារាចរលេខ០០៦ សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយ

រាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី.ខេត្ត ត្រង់ចំណុច "ឈ" និងចំណុច២.១ បានបញ្ជាក់ថា យោងបង្កាន់ដៃបង់ប្រាក់ទទួលចំណូលពីសេវានៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត រជ្ជទេយ្យករចំណូលរៀបចំបណ្ណចំណូល និងកត់ត្រាទៅក្នុងបញ្ជីបេឡាក្នុងដៃ។ បន្ទាប់មករជ្ជទេយ្យករចំណូលត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ រជ្ជទេយ្យចំណូល(ទិន្នានុប្បវត្តិ-សៀវភៅធំ)។

តាមរយៈការចុះធ្វើសវនកម្មនៅខេត្តចំនួន០៣សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការរៀបចំកិច្ចបញ្ជិកាគណនេយ្យរបស់រជ្ជទេយ្យករចំណូលនៅមន្ទីរជំនាញ និងរដ្ឋបាលខេត្តមួយចំនួននៅមានកង្វះខាតនៅឡើយ មានដូចខាងក្រោម៖

១. ខេត្តកែប៖ គណនេយ្យរជ្ជទេយ្យករចំណូលនៃមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ពុំបានរៀបចំកិច្ចបញ្ជីកាគណនេយ្យឡើយ។

២. ខេត្តព្រៃវែង៖ រជ្ជទេយ្យករចំណូលនៃរដ្ឋបាលខេត្ត ពុំបានរៀបចំសៀវភៅបញ្ជីបេឡាដើម្បីកត់ត្រាចំណូល ដែលទទួលបានពីមន្ទីរជំនាញនានាឡើយ។

៣. ខេត្តស្ទឹងត្រែង៖ រជ្ជទេយ្យករចំណូលនៃរដ្ឋបាលខេត្ត ពុំបានរៀបចំទិន្នានុប្បវត្តិទូទៅសៀវភៅធំ និងតារាងតុល្យភាពគណនីឡើយ។

ដោយសារកង្វះខាតកិច្ចបញ្ជិកាគណនេយ្យរបស់រជ្ជទេយ្យករចំណូល នាំឱ្យតួលេខចំណូលអាចបង្ហាញមិនច្បាស់លាស់។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំមន្ទីរ អង្គភាព ជំរុញដល់រជ្ជទេយ្យករចំណូលរបស់ខ្លួនអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តទាំងអស់បានឯកភាព និងបានសន្យាថាជំរុញការងារនេះបានល្អនាពេលខាងមុខ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដានលើការអនុវត្តការងារនេះបន្តទៀត។

**៣.២.៦.ការតម្រូវមានភ្ជាប់អាជ្ញាបណ្ណផ្លូវថ្នល់ក្នុងកិច្ចលទ្ធកម្មសាធារណៈ**

អនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃ ទី២២ ខែកក្កដា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់ ត្រង់មាត្រា៧ បានចែងថា " រាល់ការប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំផ្លូវថ្នល់ ការផ្តល់សេវាទីប្រឹក្សាបច្ចេកទេសសំណង់ផ្លូវថ្នល់ ការសិក្សា គម្រោងប្លង់ ការត្រួតពិនិត្យ សំណង់ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់ ត្រូវតែមានអាជ្ញាប័ណ្ណដែលផ្តល់ឱ្យដោយក្រសួងសាធារណការ និងដឹកជញ្ជូន"។

តាមរយៈការចុះធ្វើសវនកម្មនៅខេត្តចំនួន៣សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាអង្គភាពលទ្ធកម្ម និងគណៈកម្មាធិការលទ្ធកម្មនៃរដ្ឋបាលខេត្តស្វាយរៀង រដ្ឋបាលខេត្តកំពង់ឆ្នាំង និងរដ្ឋបាលខេត្តតាកែវមិនបានតម្រូវឱ្យអ្នកចូលរួមកិច្ចលទ្ធកម្ម ឬអ្នកទទួលការស្ថាបនា

និងជួសជុលហេដ្ឋារចនាសម្ព័ន្ធភ្ជាប់មកជាមួយអាជ្ញាបណ្ណផ្លូវថ្នល់ដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូនឡើយ។

កត្តានេះ នាំឱ្យអង្គភាពអនុវត្តលទ្ធកម្មទទួលបានក្រុមហ៊ុនមិនមានលក្ខណៈសម្បត្តិផ្លូវច្បាប់គ្រប់គ្រាន់ និងអាចធ្វើឱ្យសំណង់ផ្លូវពុំធានាបាននូវគុណភាពបច្ចេកទេសល្អ និងបាត់ចំណូលពីការចុះបញ្ជីអាជ្ញាបណ្ណផ្លូវថ្នល់ទៀតផង ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរអនុវត្តឱ្យបានសមស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តទាំងអស់បានឯកភាព និងបានសន្យាថាជំរុញការកែលម្អចំណុចខ្វះខាតនេះនាពេលបន្ទាប់។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនៅតែតាមដានការអនុវត្តកិច្ចការនេះបន្តទៀត។

### ៣.២.៧.ការស្នើសុំលិខិតអនុញ្ញាតសាងសង់ និងជួសជុលសំណង់អគាររបស់រដ្ឋ

អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលិខិតអនុញ្ញាតសាងសង់ ត្រង់មាត្រា៥ មាត្រា៦ និងមាត្រា៨ បានបញ្ជាក់ថា "រាល់ការសាងសង់ ឬរុះរើត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីមានសមត្ថកិច្ច។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ជាសេនាធិការមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតបើកការដ្ឋាន និងលិខិតអនុញ្ញាតរុះរើចំពោះសំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ ៣ ០០០ម$^2$ និងមានកម្ពស់ទាបជាង ឬស្មើ១១ជាន់។ ហើយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតបើកការដ្ឋាន និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់លំនៅឋាន ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ ៥០០ម$^2$ និងមានកម្ពស់ទាបជាង ឬស្មើ ៤ជាន់"។

ប្រកាសលេខ ០៧៤ ប្រក/អសណ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ត្រង់ប្រការ៧ បានចែងថា ចំពោះសំណង់អគារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន នានា មុនពេលជួសជុល ម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតជួសជុលពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ លើកលែងតែសំណង់ដែលមានចែងលើកលែងក្នុងប្រការ៣នៃប្រកាសនេះ ឬសំណង់អគារណាដែលមានលិខិតបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

តាមរយៈការចុះធ្វើសវនកម្មនៅខេត្តចំនួន៥ សម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិ សង្កេតឃើញថា ការសាងសង់ និងជួសជុលអគាររដ្ឋរបស់រដ្ឋបាលខេត្តមួយចំនួនពុំឃើញមានភ្ជាប់មកនូវលិខិតអនុញ្ញាតសាងសង់ឡើយដូចមានបង្ហាញខាងក្រោម៖

១-ខេត្តកោះកុង៖ រដ្ឋបាលខេត្តបានសាង់សង់អគាររដ្ឋបាលខេត្តថ្មី

២-ខេត្តកែប៖ រដ្ឋបាលខេត្តកែបបានសាងសង់សាលប្រជុំស្តង់ដារថ្មី

៣-ខេត្តព្រៃវែង៖ រដ្ឋបាលខេត្តបានសាងសង់អគារច្រកចេញចូលតែមួយចំនួន០២ខ្នង ស្ថិតនៅភូមិវាំង ឃុំជីផុស ស្រុកមេសាង និងនៅភូមិបង្អែក ឃុំស្វាយភ្លោះ ស្រុកពាមជរ

៤-ខេត្តកំពង់ឆ្នាំង៖ រដ្ឋបាលខេត្តបានសាងសង់ឃ្លាំងដាក់សម្ភារៈចំនួន ០២

៥-ខេត្តរតនគិរី៖ មន្ទីរសុខាភិបាលខេត្តបានជួសជុលអគារ និងរបងនៅការិយាល័យស្រុកប្រតិបត្តបរកែវ និងបានជួសជុលឃ្លាំងឱសថ របង និងខ្លោងទ្វារនៅមណ្ឌលសុខភាព អណ្ដូងពេជ្រ។

កត្តានេះអាចនាំឱ្យសំណង់ពុំមានគុណភាព និងបច្ចេកទេសសំណង់គ្រប់គ្រាន់ ហើយអាចនឹងជួបប្រទះនូវហានិភ័យណាមួយជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំមន្ទីរ អង្គភាពក្រោមឱវាទអនុវត្តឱ្យបានសមស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តទាំងអស់បានឯកភាព និងបានសន្យាថាជំរុញការអនុវត្តនីតិវិធីនេះឱ្យបានល្អនាពេលខាងមុខ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនៅតែនឹងតាមដានការអនុវត្តការងារនេះបន្តទៀត។

### ៣.២.៨.ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍បូកសរុបចំណូល ចំណាយរដ្ឋបាលថ្នាក់ក្រោមជាតិ

ប្រកាសលេខ ៩៧៣សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ជំពូកទី២ ប្រការ៤ បេសកកម្ម និងរចនាសម្ព័ន្ធ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើបេសកកម្មអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រការ៨ បានបញ្ជាក់ថា នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស បំពេញមុខងារសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស ព្រមទាំងមានភារកិច្ច៖ រៀបចំបូកសរុបរបាយការណ៍នៃការរៀបចំផែនការថវិកា ការអនុវត្តថវិកា និងការសម្រេចទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសារាចរណែនាំលេខ០១២ សហវ.សរ.អហក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៣ ត្រង់ចំណុច១១ បន្ទាត់ទី២ បានបញ្ជាក់ថា របាយការណ៍បិទបញ្ជីថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ) យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សម្រេចទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដាក់បញ្ចូលទៅក្នុងជំពូកមួយនៃសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

តាមការចុះធ្វើសវនកម្មនៅអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការិយបរិច្ឆេទ ២០២៣ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា គិតត្រឹមថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់បានផ្តល់ឯកសាររបាយការណ៍បូកសរុបចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដល់គណៈប្រតិភូសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ដើម្បីមានមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូលចំណាយឆ្នាំ២០២៣ សម្រាប់បញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅឡើយទេ។ កត្តានេះនាំឱ្យការបូកសរុប និងរៀបចំនូវរបាយការណ៍សម្រេចទូទាត់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការយឺតយ៉ាវ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្សព្វផ្សាយសារាចរណែនាំលេខ០១២ សហវ.សរ.អហក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៣ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានធ្វើការបូកសរុប និងរៀបចំរបាយការណ៍អនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានត្រឹមត្រូវ ព្រមទាំងដាក់បញ្ចូលទៅក្នុងជំពូកមួយនៃសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ ជាក់ស្តែងក្នុងការរៀបចំរបាយការណ៍បូកសរុបចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ប្រឈមនឹងបញ្ហាមួយចំនួនដូចជា៖ (១) ការផ្តល់របាយការណ៍បិទបញ្ជីថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់មួយចំនួនផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនបានទាន់ពេលតាមកាលបរិច្ឆេទកំណត់របស់សារាចរណែនាំ និង (២) របាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន ដែលបានផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជារបាយការណ៍បណ្តោះអាសន្នដោយនៅមិនទាន់បានចុះហត្ថលេខាជាផ្លូវការនៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងអង្គភាពពាក់ព័ន្ធ ដើម្បីពង្រឹងការរៀបចំបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកា ស្របតាមខ្លឹមសារនៃសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកាប្រចាំឆ្នាំបន្ថែមទៀត។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំណូមពរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត ដូចជា៖ (១) ត្រៀមរៀបចំបូកសរុបការអនុវត្តចំណូល ចំណាយថវិកាប្រចាំឆ្នាំនៅត្រីមាសទី៤ (២)ពន្លឿនការផ្ទៀងផ្ទាត់ និងការត្រួតពិនិត្យរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ក្រោមជាតិជាមួយនឹងអង្គភាពពាក់ព័ន្ធ និង (៣) រួសរាន់ផ្តល់របាយការណ៍ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាជូនក្រុមប្រឹក្សាដើម្បីពិនិត្យ អនុម័ត និងចុះហត្ថលេខាលើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ និងចៅសង្កាត់ ហើយបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទាន់ពេល។

អាជ្ញាធរសវនកម្មជាតិនឹងតាមដានករណីនេះជាបន្តទៀតនៅឆ្នាំបន្ទាប់។

**៣.២.៩.ការគ្រប់គ្រងអនុវត្តវិធានការតឹងទារបំណុលពន្ធ**

ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រង់មាត្រា៩៥ (ថ្មី) ចំណុច១ បានបញ្ជាក់ថា "លិខិតស្នាម ឬលិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធ មានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ"។

ប្រកាសលេខ ៩៦២ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបំណុលពន្ធដារ ត្រង់ប្រការ៩ វិធានការទារបំណុលពន្ធ ចំណុចទី១ បានបញ្ជាក់ថា "ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងទារបំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្តវិធានការទារបំណុលពន្ធចំពោះបុគ្គលពាក់ពន្ធនឹងបំណុលពន្ធដូចខាងក្រោម៖

- ក.ធ្វើការទំនាក់ទំនង ឬចុះដល់ទីតាំងដើម្បីជំរុញ ឬផ្តល់ដំណឹងបន្ថែមឱ្យមកទូទាត់បំណុលពន្ធ
- ខ.មិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ឬចលនទ្រព្យជាបណ្តោះអាសន្ន
- គ.ដកហូតមកវិញនូវការលើកទឹកចិត្ត ផ្នែកសារពើពន្ធដែលបានផ្តល់ដោយរដ្ឋបាលសារពើពន្ធ
- ឃ.ព្យួរទុក ឬទុកជាមោឃៈនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណផ្សេងៗដែលចេញដោយរដ្ឋបាលសារពើពន្ធ
- ង.មិនអនុញ្ញាតឱ្យចុះបញ្ជីពន្ធដារ
- ច.ធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រអគ្គនាយកដ្ឋានពន្ធដារ នៅលើបណ្តាញសង្គម និងនៅតាមទំព័រសារព័ត៌មាននានា។

ប្រការ១០នៃប្រកាសខាងលើ វិធានការតឹងទារបំណុលពន្ធ បានបញ្ជាក់ថា ដើម្បីបញ្ចៀសនូវចេតនាគេចវេះការទូទាត់បំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះបុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធដូចខាងក្រោម៖

- ក. ស្នើសុំទុកជាមោឃៈនូវលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណផ្សេងៗដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ខ. ស្នើសុំបញ្ឈប់សកម្មភាពអាជីវកម្ម ឬផ្អាកដំណើរការសហគ្រាសជាបណ្តោះអាសន្ន
- គ. ការឃាត់ទុកគណនីធនាគាររបស់សហគ្រាស ឬ/និងបុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធ
- ឃ. ឃាត់ទុកទំនិញ សន្និធិទំនិញ បញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល
- ង. រឹបអូសទ្រព្យសម្បត្តិរបស់សហគ្រាស ឬ/និងបុគ្គលពាក់ព័ន្ធនឹងបំណុលពន្ធ
- ច. ដាក់ពាក្យបណ្តឹងទៅតុលាការ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

ចំណុចនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់ផ្តល់អនុសាសន៍សម្រាប់ការិយបរិច្ឆេទ២០២២។ ប៉ុន្តែ តាមការធ្វើសវនកម្មនៅសាខាពន្ធដារខេត្តចំនួន០៤សម្រាប់ការិយបរិច្ឆេទ២០២៣ ឃើញថា មានបំណុល ពន្ធមួយចំនួនពុំទាន់ត្រូវបានអនុវត្តវិធានការតឹងទារឱ្យបានពេញលេញនៅឡើយ មានដូចខាងក្រោមៈ

១-សាខាពន្ធដារខេត្តកំពតមានចំនួនសរុប ២៩ ៦៧៥លានរៀល។

២-សាខាពន្ធដារខេត្តព្រៃវែងមានចំនួនសរុប ១៩ ៥៣៤លានរៀល។

៣-សាខាពន្ធដារខេត្តតាកែវមានចំនួនសរុប ១៣ ៣២០លានរៀល ក្នុងនោះបំណុល ពន្ធយោងពីរបបពន្ធម៉ៅការ មានចំនួន ៤៨៨លានរៀល។

៤សាខាពន្ធដារខេត្ត-ក្រចេះមានចំនួនសរុប ៨ ៨៧៣ លានរៀល។

កត្តានេះអាចនាំឱ្យបាត់ចំណូលពន្ធជាយថាហេតុ។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរជំរុញសាខាពន្ធដារខេត្តខាងលើឱ្យខិតខំទារបំណុលពន្ធឱ្យ បានគ្រប់ចំនួន និងទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តទាំងអស់បានឯកភាព និងបានសន្យាថាជំរុញការ កែលម្អចំណុចខ្វះខាតនេះនាពេលបន្ទាប់។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តខ្លះបានឯកភាព និងណែនាំសាខាពន្ធដារ ខេត្ត រដ្ឋបាលខេត្តខ្លះទៀតថា ធ្លាប់បានអនុវត្តវិធានការទារមានដូចជាៈ

- បានធ្វើលិខិតជូនដំណឹងទារបំណុលពន្ធ
- បានធ្វើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ
- បានធ្វើលិខិតអញ្ជើញសហគ្រាសមកដោះស្រាយបំណុលពន្ធ
- បានធ្វើលិខិតស្នើសុំកិច្ចអន្តរាគមន៍ និងសហការទៅកាន់រដ្ឋបាលខេត្ត។ល។

ហើយរដ្ឋបាលខេត្តខ្លះផ្សេងទៀតបានលើកឡើងថា បំណុលខាងលើមានយោងមកចាប់តាំងពីរបបពន្ធ ម៉ៅការ ត្រូវបានឈប់អនុវត្ត ដែលម្ចាស់បំណុលបាត់ខ្លួនរកពុំឃើញ និងទារពុំបាន។

អាជ្ញាធរសវនកម្មជាតិនឹងធ្វើការតាមដានលើការអនុវត្តការងារនេះបន្តទៀត។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៣ នាពេលកន្លងមក អាជ្ញាធរ សវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួន ដែលអាជ្ញាធរ សវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គ ភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ ប៉ុន្តែចំណុចមួយចំនួនទៀត នៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

### ៤.១.ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន

ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញ លិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាព

ស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមួយចំនួន ដោយបានផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានពន្ធដារផងដែរ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារ ពុំទាន់បានប្រមូលព័ត៌មានសហគ្រាសនៅតាមបណ្តាក្រសួងស្ថាប័នមួយចំនួនផ្សេងទៀតឱ្យបានពេញលេញ និងទាន់ពេលវេលានៅឡើយដោយសារក្រសួងមួយចំនួនពុំទាន់សហការ។ ចំពោះបញ្ហានេះ អគ្គនាយកដ្ឋានពន្ធដារតែងតែមានយន្តការសម្របសម្រួលជាមួយបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធក្នុងការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកឱ្យស្របតាមគោលការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះ អគ្គនាយកដ្ឋានពន្ធដារក៏បានចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការរៀបចំ Big Data (Data is a gold) របស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយស្ថាប័នពាក់ព័ន្ធឱ្យបានពេញលេញ ។

**៤.២.ការកាន់កិច្ចបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធមួយចំនួន**

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ត្រង់មាត្រា២០១ បានចែងថា "អ្នកជាប់ពន្ធត្រូវកាន់ កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់..." មាត្រា២០១នៃច្បាប់ខាងលើ ត្រង់ចំណុច៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធមិនកាន់ កត់ត្រា ឬកត់ត្រាមិនត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬកំណត់ត្រានានាតាមលក្ខខណ្ឌដែលបានកំណត់ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់នូវប្រាក់ចំណូល និងចំណាយផ្សេងៗ" និងមាត្រា២០៩នៃច្បាប់ខាងលើ ត្រង់ចំណុចទី៣ បានចែងថា "ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមិនបានដាក់លិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យ ឬឯកសារផ្សេងទៀតតាមការតម្រូវ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវក្នុងការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធឯកតោភាគី..."។

តាមការពិនិត្យសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធមួយចំនួនតូច (ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំមួយចំនួន និងសាខាពន្ធដារខេត្ត ខណ្ឌមួយចំនួន) ពុំទាន់បានកាន់ កត់ត្រា និងថែរក្សាទុកកិច្ចបញ្ជិកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធនៅឡើយ។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជានាយកដ្ឋានសវនកម្មសហគ្រាស តែងតែធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំអ្នកជាប់ពន្ធតាមរយៈការធ្វើសិក្ខាសាលា ក៏ដូចជាការផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម Facebook ជាដើម ដើម្បីជំរុញការអប់រំអ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់សារពើពន្ធ និងការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិស្តីពីពន្ធដារ ប៉ុន្តែសហគ្រាសមួយចំនួនតូចនៅតែព្យាយាមគេចវេះ មិនព្រមកាន់កាប់

បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវនៅឡើយ ដែលសហគ្រាសទាំងនេះជាកម្មវត្ថុនៃការធ្វើសវនកម្មពន្ធដារ។

### ៤.៣.ក្រុមហ៊ុន សហគ្រាសមួយចំនួនតូចពុំទាន់បានបំពេញកាតព្វកិច្ចសារពើពន្ធ

ច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ត្រង់មាត្រា២០៦ ចំណុច១ បានចែងថា "អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់"។ មាត្រា២២នៃច្បាប់ខាងលើ អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ កថាខណ្ឌទី៣ "ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ" និងមាត្រា២៣៥នៃច្បាប់ខាងលើ ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារបានចែងថា "ត្រូវផាកពិន័យជាប្រាក់ចំនួន៥ ០០០ ០០០ (ប្រាំលាន)រៀល ដោយរដ្ឋបាលសារពើពន្ធដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតចំពោះបុគ្គលដែលធ្លាប់បានទទួលការព្រមានជាលាយលក្ខណ៍អក្សរពីរដ្ឋបាលសារពើពន្ធលើសពី២ (ពីរ)លើក ហើយនៅតែប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣នៃមាត្រា២២៥"។

តាមការពិនិត្យស្ថិតិសហគ្រាសជាប់ពន្ធមធ្យម និងតូចប្រចាំខែក្នុងឆ្នាំ២០២៣នៅសាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខេត្ត និងខណ្ឌបានរៀបចំសិក្ខាសាលា ដើម្បីបណ្តុះបណ្តាល និងផ្សព្វផ្សាយកាតព្វកិច្ចសារពើពន្ធជូនអ្នកជាប់ពន្ធជារៀងរាល់ឆ្នាំ។ លើសពីនេះទៀត សាខាពន្ធដារខាងលើបានក្រើនរំលឹកដល់អ្នកជាប់ពន្ធដែលខកខានក្នុងការដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែផងដែរ។ ទោះជាយ៉ាងនេះក្តី ការបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែរបស់សហគ្រាសមួយចំនួនតូចពុំទាន់បានខ្ជាប់ខ្ជួននៅឡើយ។ កត្តានេះ អាចនាំឱ្យមានហានិភ័យចំពោះការគេចវេះពន្ធជាយថាហេតុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។

អាជ្ញាធរសវនកម្មជាតិបានឃើញមតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៤.៤.ការប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវអនុវត្តតាមប្រភេទ អត្រា និងលក្ខខណ្ឌ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០២៣ អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រមូលចំណូលពន្ធលើផ្ទាំងផ្សព្វផ្សាយ និងបានបង់ចំណូលចូលថវិកាលើសផែនការ។ តាមការធ្វើតេស្តលើអាជីវកម្មដ្ឋានដែលត្រូវជាប់ពន្ធ និងមានស្លាកយីហោ (ផ្ទាំងផ្សព្វផ្សាយ) មួយចំនួន ដែលមានអាជីវកម្មស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្តចំនួន១៤ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអាជីវកម្មដ្ឋានមួយចំនួនតូច ពុំទាន់បានបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយនៅឡើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយដ្ឋានពន្ធដារមានយន្តការពង្រឹងបន្ថែមទៀតក្នុងការប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយចំពោះ

សហគ្រាសឱ្យបានពេញលេញ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយដ្ឋានពន្ធដារមានយន្តការពង្រឹងបន្ថែមទៀតក្នុងការប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយចំពោះសហគ្រាសឱ្យបានពេញលេញ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាពតាមអនុសាសន៍សវនកម្ម និងពង្រឹងកិច្ចការនេះបន្ថែមទៀតសម្រាប់ឆ្នាំបន្ទាប់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំណូមពរឱ្យអាជ្ញាធរសវនកម្មជាតិជួយផ្តល់អនុសាសន៍ដល់ស្ថាប័នពាក់ព័ន្ធទាក់ទិននឹងកិច្ចការនេះ ចៀសវាងមានការភាន់ច្រឡំជាមួយនឹងការប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ។

**៤.៥.ការកត់ត្រាប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ**

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស០១៧/១២១៨/រកម/ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ត្រង់ចំណូលថវិការាជធានី ខេត្ត " ពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យរូបវន្តបុគ្គល (អនុគណនី ៧០០១៤) និងពន្ធលើឈ្នួលចលនទ្រព្យ និងអចលនទ្រព្យនីតិបុគ្គល (អនុគណនី ៧០០១៥)" ត្រូវបានផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត ។ ប្រកាសលេខ១៤៣១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការប្រគល់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ២ បានចែងថា "អគ្គនាយកដ្ឋានពន្ធដារនិងសាខាពន្ធដារខេត្ត ខណ្ឌត្រូវប្រមូលចំណូលពីពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ និងរៀបចំសលាកបត្របង់ប្រាក់ចំណូលចូលទៅរតនាគាររាជធានី ខេត្ត ដើម្បីកត់ត្រាជាចំណូលថវិការដ្ឋបាលរាជធានី ខេត្តនីមួយៗ។

តាមការពិនិត្យស្ថិតិប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យរបស់រូបវន្តបុគ្គល និងនីតិបុគ្គលប្រចាំខែ និងសំណុំឯកសារផ្សេងៗក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានខិតខំប្រមូលចំណូលពន្ធបានចំនួន៣៦៥ ៥២២ ៩២៣ ២១៩រៀល ស្មើនឹង ១០៤,៣២%នៃផែនការ។ ក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាលមួយចំនួន បានប្រកាស និងបង់ប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យទាំងនេះជូនដល់អង្គភាពពន្ធដែលក្រុមហ៊ុនទាំងនោះបានចុះបញ្ជី ប៉ុន្តែអង្គភាពពន្ធដែលទទួលបានចំណូលប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យទាំងនោះពុំទាន់បានបង្វែរប្រាក់ពន្ធខាងលើទៅអង្គភាពពន្ធដែលស្ថិតនៅតាមទីតាំងជួលជាក់ស្តែងនៅឡើយ។

កត្តានេះ អាចនាំឱ្យការគ្រប់គ្រង និងកត់ត្រាប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យពុំទាន់សមស្របត្រឹមត្រូវ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអគ្គនាយកដ្ឋានពន្ធដារឱ្យបង្វែរប្រាក់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ និងកត់ត្រាប្រាក់ពន្ធឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់អនុគណនី ដើម្បីឱ្យបានជាប្រយោជន៍ដល់រដ្ឋបាលរាជធានី ខេត្ត។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងខិតខំពង្រឹងបន្ថែមលើកិច្ចការនេះសម្រាប់ឆ្នាំបន្ទាប់ ព្រមទាំងរៀបចំអនុវត្តនីតិវិធីការងារដូចករណីបង្វែរប្រាក់ពន្ធលើផ្ទាំងផ្សព្វផ្សាយ ដែលបានអនុវត្តជោគជ័យរួចហើយ។

### ៤.៦.ការចេញវិញ្ញាបនប័ត្របញ្ចប់ការងារជូនអ្នកទទួលការ

ប្រកាសលេខ៣៨១សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ចំណុច៣.១៤.៨.៦ បានបញ្ជាក់ថា នៅពេលបញ្ចប់រយៈពេលនៃការសាងសង់ ហើយអ្នកទទួលការបានកែតម្រូវរាល់ការខូចខាតទាំងអស់ ដូចដែលអ្នកគ្រប់គ្រងគម្រោងបានណែនាំ អ្នកម្ចាស់ការ (តាមរយៈអ្នកគ្រប់គ្រងគម្រោង) ត្រូវចេញនូវវិញ្ញាបនបត្របញ្ចប់ការងារ (ការទទួលយកជាបណ្តោះអាសន្ន) ជូនអ្នកទទួលការ និងប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃសម្រាប់លទ្ធកម្មទំនិញ និងសំណង់បានដាក់ឱ្យប្រើប្រាស់នូវកម្រងឯកសារដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈស្តីពីការងារសាងសង់/ជួសជុល...ត្រង់ចំណុច១៤ នៃលក្ខខណ្ឌកិច្ចសន្យា បានបញ្ជាក់ថា "ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់ទទួលសំណង់។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំ "អ្នកម្ចាស់ការ" នូវលិខិតបញ្ជាក់ពីការបញ្ចប់ ការងារ។ "អ្នកម្ចាស់ការ" នឹងចេញលិខិតបញ្ជាក់ពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន (១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើពី "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់។

តាមការធ្វើសវនកម្មនៅខេត្តចំនួន០៦ សម្រាប់ការិយបរិច្ឆេទ២០២៣ ឃើញថា ១-ខេត្តកោះកុងមានចំនួន១អង្គភាព ២-ខេត្តស្វាយរៀងមានចំនួន១អង្គភាព ៣-ខេត្តកំពង់ស្ពឺមានចំនួន១អង្គភាព ៤-ខេត្តស្ទឹងត្រែងមានចំនួន២អង្គភាព ៥-ខេត្តសៀមរាបមានចំនួន៤អង្គភាព និង៦-ខេត្តក្រចេះមានចំនួន៤អង្គភាព បានអនុវត្តកិច្ចលទ្ធកម្មសំណង់លើការងារជួសជុល និងសាងសង់ ហើយនៅពេលបញ្ចប់ការងារ អ្នកទទួលការពុំបានធ្វើការស្នើសុំលិខិតបញ្ជាក់បញ្ចប់ការងារពីអ្នកម្ចាស់ការទេ។ ជាមួយនេះអ្នកម្ចាស់ការក៏ពុំបានចេញវិញ្ញាបនបត្របញ្ចប់ការងារជូនដែរ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្ត និងមន្ទីរជំនាញបានឯកភាព និងបានសន្យាថា កែលម្អតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិនាការិយបរិច្ឆេទបន្ទាប់។

### ៤.៧.ការប្រមូលចំណូលពីសោហ៊ុយសេវាសំណង់

ប្រកាសអន្តរក្រសួងល ៣៥៦ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៩ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ត្រង់ឧបសម្ព័ន្ធ ខ.I.១.១៤ បានបញ្ជាក់ថា "លិខិតអនុញ្ញាតបើកការដ្ឋានចំពោះផ្ទៃក្រឡាសំណង់ចាប់ពី ៣ ០០០ម$^2$ចុះក្រោម គិតយក១០ភាគរយនៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់"។

ប្រកាសរួមលេខ៩៩៥ សហវ.ប្រក ចុះ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការផ្តល់សេវាសាធារណៈរបស់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់ចំណុច II.1 បានបញ្ជាក់ថា លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចរបស់សាលារាជធានី-ខេត្ត ក្នុងនោះមាន៖

- លិខិតអនុញ្ញាតសាងសង់សំណង់លំនៅឋានដូចជាភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ ចាប់ពី១០០ម² ដល់ ៣ ០០០ម²ទាំងនៅក្រៅក្រុង ក្នុងក្រុង និងរាជធានី ត្រូវបង់តម្លៃសេវា ចាប់ពី៩៨ ០០០៛ ដល់ ៧ ០០០ ០០០៛

- លិខិតអនុញ្ញាតសាងសង់សំណង់អគារផ្សេងៗក្រៅពីលំនៅឋានចាប់ពី១០០ម² ដល់ ២ ០០០ម² ត្រូវបង់ តម្លៃសេវាចាប់ពី ១ ០០០ ០០០៛ ដល់ ១០ ០០០ ០០០៛

- លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្រ បញ្ជាក់ភាពត្រឹមត្រូវ ត្រូវបង់តម្លៃសេវាគិត ១០% នៃតម្លៃសុំលិខិត អនុញ្ញាតសាងសង់។

តាមការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៣នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តចំនួន៤ខេត្ត ឃើញថា មន្ទីរទាំងនេះបានផ្តល់លិខិតអនុញ្ញាតសាងសង់ជូនម្ចាស់សំណង់តាមសំណើ និងបានប្រមូលចំណូលទាំងនេះរួចមកហើយ។ ប៉ុន្តែទន្ទឹមនឹងនេះ មន្ទីរមួយចំនួនបានខកខានក្នុងការប្រមូលចំណូលពីសេវាបើកការដ្ឋាន និងបិទការដ្ឋានឱ្យបានគ្រប់ចំនួន រួមមាន ១.ខេត្តស្វាយរៀងបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន២៦គម្រោង និងបានផ្តល់លិខិតបើកការដ្ឋានចំនួន២៦គម្រោង ប៉ុន្តែពុំបានជំរុញការសុំបិទការដ្ឋានទេ ២.ខេត្តកំពង់ស្ពឺបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន៤៥គម្រោង និងមានលិខិតបើកការដ្ឋានចំនួន០៥គម្រោង ៣.ខេត្តព្រៃវែងបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន១៩គម្រោង និងបើកការដ្ឋានចំនួន១៩គម្រោង ប៉ុន្តែពុំបានជំរុញការសុំបិទការដ្ឋានទេ ៤.ខេត្តស្ទឹងត្រែងបានផ្តល់លិខិតអនុញ្ញាតសាងសង់ចំនួន៤៨គម្រោង និងបើកការដ្ឋានចំនួន០២គម្រោង។ ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះឯកភាពតាមអនុសាសន៍សវនកម្ម និងសន្យាថាជំរុញការងារនេះ។ រដ្ឋបាលខេត្តខ្លះទៀតបានលើកឡើងថា ម្ចាស់សំណង់មួយចំនួនពុំមកសុំបិទការដ្ឋានទេ ទោះមានការចុះណែនាំពួកគាត់រួចហើយក្តី។ ម្យ៉ាងវិញទៀតក៏ពុំមានលិខិតបទដ្ឋានណាត្រូវពិន័យលើម្ចាស់សំណង់ឡើយ។

**៤.៨.ការរក្សាសមតុល្យសាច់ប្រាក់នៅសល់ចុងឆ្នាំ២០២៣**

សារាចរណែនាំលេខ០១០សហវ.សរណ.អថ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ត្រង់ចំណុចI អំពីការបិទបញ្ជីចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ជាកំហិត។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសមតុល្យសាច់ប្រាក់

នៅសល់ចុងឆ្នាំ២០២៣ ចំនួន ៤ ៨០៩លានរៀល (ចំណូលប្រមូលបានក្នុងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យចុងឆ្នាំ) ដែលចំណូលទាំងនេះត្រូវបានធ្វើការបង្វែរចូលថវិកាជាតិនៅដើមឆ្នាំ២០២៤។ កត្តានេះនាំឱ្យការកត់ត្រាចំណូលចំណាយថវិកាពុំបានឆ្លុះបញ្ចាំងតួលេខជាក់ស្តែងតាមឆ្នាំនៃថវិកា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាព និងបានបញ្ជាក់បន្ថែម ដូចខាងក្រោម៖

- ថ្ងៃដំណាច់ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ អគ្គនាយកដ្ឋានរតនាគារជាតិ និងធនាគារជាតិនៃកម្ពុជាឈប់សម្រាក និងបិទប្រតិបត្តិការទទួលប្រាក់ចំណូល ចំណែកធនាគារពាណិជ្ជត្រូវបិទប្រតិបត្តិការផ្ទេរចំណូលទៅគណនីទោលរតនាគារ នៅធនាគារជាតិនៃកម្ពុជា វេលាម៉ោង ១៥:០០នាទីនៃថ្ងៃធ្វើការស្របតាមអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារសម្រាប់ប្រតិបត្តិការចំណូល ជាហេតុនាំឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មិនអាចបង្វែរចំណូលដែលបានបំពេញបែបបទគយរួចនៅថ្ងៃដំណាច់ឆ្នាំទាំងនេះចូលថវិកាជាតិក្នុងឆ្នាំសារពើពន្ធបាន

- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានចេញលិខិតលេខ ៨៤៩៩/២៣ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីប្រតិបត្តិការប្រមូលចំណូល និងការធ្វើសលាកប័ត្របង់ចំណូលថវិកាជាតិនៅចុងឆ្នាំ២០២៣ ជម្រាបជូនគ្រប់ប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ ត្រូវផ្សព្វផ្សាយ និងជំរុញដល់អតិថិជនដែលត្រូវមកបំពេញកាតព្វកិច្ចបង់ពន្ធអាករ និងកម្រៃគ្រប់ប្រភេទនៅចុងឆ្នាំ២០២៣ រូតរះធ្វើការបង់ចំណូលឱ្យបានត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣។ ចំពោះចំណូលនៅសេសសល់ត្រូវកត់ត្រាស្ថានភាពសល់ក្នុងបេឡា និងត្រូវរូតរះធ្វើសលាកបត្របង់ចំណូលថវិកាជាតិដោយឡែកនៅថ្ងៃធ្វើការបន្ទាប់។

### ៤.៩. ការចុះត្រួតពិនិត្យតាមដានអនុលោមភាពលើការប្រើប្រាស់សម្ភារបរិក្ខារវត្ថុធាតុដើមដែលទទួលបានការអនុគ្រោះព្បរ ឬលើកលែងពន្ធអាករនៅមានកម្រិត

ប្រកាសលេខ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨របស់សេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រង់ជំពូកទី៩ នាយកដ្ឋានរបបគយ ប្រការ៤០ បានបញ្ជាក់ថា នាយកដ្ឋានរបបគយបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាលើការងាររបបគយដោយមានតួនាទី និងភារកិច្ចដូចជា៖ ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតគយនាំចេញ នាំចូលទំនិញតាមរបបគយអនុគ្រោះនានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យការប្រើប្រាស់សម្ភារ បរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់។

តាមការធ្វើសវនកម្មនៅនាយកដ្ឋានរបបគយក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថាមានមុខទំនិញនាំចូលដូចជា៖ វត្ថុធាតុដើមគ្រឿងបន្សំ សារធាតុគីមី គ្រឿងម៉ាស៊ីន គ្រឿងបន្លាស់ សម្ភារសំណង់ សម្ភារបរិក្ខារផ្សេងៗ និងទំនិញនាំចូលគ្រប់ប្រភេទដែលមានលក្ខណៈជាវិនិយោគកាត់ដេរ និងវិនិយោគមិនមែនកាត់ដេរ ដែលមានពន្ធអាករជាបន្ទុករដ្ឋសរុបចំនួន **១១ ៣០២ ៤០៦ ២២៤ ៦៤០** រៀល ក្នុងនោះ១. វិនិយោគទុនកាត់ដេរចំនួន ៦ ៤៣០ ៦៥០ ៣៥៨ ៥៦០រៀល និង២. វិនិយោគទុន

ផ្សេងៗចំនួន៤ ៨៧១ ៧៥៥ ៨៦៦ ០៨០រៀល ដោយទទួលបាននូវរបបអនុគ្រោះក្រោមរបបព្យួរពន្ធ ឬលើកពន្ធអាករ។ ទោះបីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាខិតខំចុះត្រួតពិនិត្យតាមដានអនុលោមភាពលើទិសដៅនៃការប្រើប្រាស់សម្ភារ បរិក្ខារ វត្ថុធាតុដើម និងទំនិញគ្រប់ប្រភេទទាំងនោះយ៉ាងណាក៏ដោយ ក៏នៅតែមានសេសសល់ខ្លះនៅឡើយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា ការចុះត្រួតពិនិត្យអនុលោមភាពលើការប្រើប្រាស់សម្ភារ បរិក្ខារ និងវត្ថុធាតុដើម គឺផ្អែកតាមគោលការណ៍ហានិភ័យ។ ជាក់ស្តែងក្នុងឆ្នាំ ២០២៣ នាយកដ្ឋានរបបគយ បានចុះត្រួតពិនិត្យអនុលោមភាពលើការប្រើប្រាស់សម្ភារ បរិក្ខារ និងវត្ថុធាតុដើមដែលទទួលបានការអនុគ្រោះព្យួរ ឬលើកលែងពន្ធនិងអាករ បានសរុបចំនួន ៨៤លើក។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងជំរុញនាយកដ្ឋានរបបគយឱ្យបន្តខិតខំកំណត់មុខសញ្ញាមានហានិភ័យ ដើម្បីចុះត្រួតពិនិត្យតាមដានអនុលោមភាពជាបន្តបន្ទាប់ទៀត។

**៤.១០.ការយឺតយ៉ាវក្នុងការដោះស្រាយកំណត់ហេតុល្មើសច្បាប់គយ**

ប្រកាសលេខ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រង់ជំពូកទី៥ នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ ប្រការ២១ បានបញ្ជាក់ថា នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈមានតួនាទី និងភារកិច្ចដូចជាៈ ពិនិត្យកំណត់ហេតុល្មើសគយ លើកសំណើសម្រុះសម្រួល និងសម្រេចវិនិច្ឆ័យលើបទល្មើសគយ និងវិវាទផ្សេងទៀតជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពិនិត្យ និងសម្រេច។

ប្រកាសលេខ៦១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការសម្រុះសម្រួលបទល្មើសគយ ត្រង់ប្រការ៤ បានបញ្ជាក់ថា ប្រសិនបើក្នុងរយៈពេលកៅសិប(៩០)ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះសម្រួលនូវបទល្មើសគយមិនអាចទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០២៣ នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈបានទទួលកំណត់ហេតុល្មើសច្បាប់គយមួយចំនួនពីបណ្តានាយកដ្ឋានគយ និងរដ្ឋាករ សាខាគយ និងរដ្ឋាករ និងការិយាល័យគយ និងរដ្ឋាករនៅទូទាំងប្រទេស។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ កំណត់ហេតុល្មើសច្បាប់គយមួយចំនួន (បូករួមបញ្ចូលកំណត់ហេតុនៅសល់ឆ្នាំចាស់ៗ) ត្រូវបានធ្វើសេចក្តីសម្រេចវិនិច្ឆ័យរួច ប៉ុន្តែនៅមានកំណត់ហេតុល្មើសច្បាប់គយមួយចំនួនពុំទាន់មានវិធានការ និងដំណោះស្រាយឱ្យបានសមស្របនៅឡើយទេ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ កំណត់ហេតុដែលនៅសល់មួយចំនួន ក្នុងនោះ មានរថយន្តគ្រប់ប្រភេទ គ្រឿងចក្រ ត្រាក់ទ័រ និងសីមី-រ៉ឺម៉ក មួយចំនួន និងទំនិញចម្រុះ ប្រេងម៉ាស៊ីន ស្រាបៀរ ម៉ូតូ បារី ម៉ាស៊ីនភ្លើង សំបកកង់រថយន្ត ថង់ប្លាស្ទីក ម៉ាស៊ីនត្រជាក់ និងទូរស័ព្ទដៃចាស់ៗមួយចំនួន។ ក្រៅពីយន្តការនិងវិធានការដោះស្រាយ

ដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានបន្តចាត់វិធានការចំពោះមុខ ដូចខាងក្រោម៖

- គណៈកម្មការចំពោះកិច្ចដោះស្រាយទំនិញល្មើសនឹងច្បាប់ស្តីពីគយ បានរៀបចំប្រមូលស្ថិតិយានយន្តនិងទំនិញដែលមិនអាចដោះស្រាយបាន ដើម្បីស្នើសុំដាក់លក់ដេញថ្លៃជាទំនិញគ្មានការទាមទារ
- បន្តជំរុញម្ចាស់ឱ្យចូលខ្លួនមកសម្របសម្រួលដោះស្រាយឱ្យអស់លទ្ធភាព។

## ៤.១១.ការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានមិនអស់លទ្ធភាព

អនុក្រឹត្យលេខ ៧២ អនក្រ១១បក ចុះថ្ងៃទី. ខែសីហា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រង់មាត្រា១២ បានកំណត់ថា "ម្ចាស់គម្រោងត្រូវបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថានសម្រាប់កិច្ចការពារបរិស្ថាន" ដូចមានចែងក្នុងមាត្រា១៩ ជំពូក៨ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ"។

ចំណុចនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍សវនកម្មសម្រាប់ការិយបរិច្ឆេទ ២០២២ រួចមកហើយ ប៉ុន្តែតាមរយៈការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមហ៊ុនចំនួន ៩១១មិនទាន់បង់មូលនិធិទាយជ្ជទាន បរិស្ថាន តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន ៧៦៤ ៦៥០ ដុល្លារអាម៉េរិក។ ដូចនេះ ក្រសួងបរិស្ថានគួរអនុវត្តឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ។

ឆ្លើយតបករណីនេះ ក្រសួងសូមបំភ្លឺថា បំណុលមូលនិធិចាប់តាំងពីឆ្នាំ២០១៥-២០២៣ ជាការបំពេញកាតព្វកិច្ចមានចែងក្នុងកិច្ចសន្យាការពារបរិស្ថានរបស់ម្ចាស់គម្រោង ជូនចំពោះក្រសួងបរិស្ថានមិនបានពេញលេញក្នុងបរិយាកាសសេដ្ឋកិច្ចសកលប្រឈមជំងឺរាតត្បាតកូវីដ-១៩ និងសង្គ្រាមតំបន់អឺរ៉ុបខាងកើត និងមជ្ឈឹមបូព៌ា។ ទោះបីជាយ៉ាងនេះក្តី បញ្ហាបំណុលមូលនិធិនេះ តម្រូវឱ្យមានការអនុវត្តវិធានការរដ្ឋបាល និងច្បាប់តឹងទារបំណុលយ៉ាងម៉ឺងម៉ាត់។

## ៤.១២.ការប្រមូលចំណូលអំពីសេវាសាធារណៈផ្នែកអធិការកិច្ចការងារ

ប្រកាសអន្តរក្រសួង លេខ៣៣៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រង់ប្រការ២ បានចែងថា "សេវាសាធារណៈដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានរៀបចំជាកម្រងសេវាសាធារណៈដែលមានរាយលម្អិតអំពីប្រភេទសេវាតម្លៃសេវា រយៈពេលអតិបរិមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃប្រកាសអន្តរក្រសួងនេះ"។ នៅក្នុងឧបសម្ព័ន្ធ១ ត្រង់ចំណុចទី II បានរាយលម្អិតអំពីសេវាសាធារណៈ ផ្នែកអធិការកិច្ចការងារ ក្នុងនោះមានសេវាពីការផ្តល់លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ ការចុះធ្វើអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ (១ដងក្នុង១ឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតផលស្បែកជើង ផលិត

ផលធ្វើដំណើរ និងកាបូប និងផលិតផលប្រហាក់ប្រហែល) និងការចុះធ្វើអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ (១ដងក្នុង១ឆ្នាំ សម្រាប់សហគ្រាស គ្រឹះស្ថានក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតផលស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូប និងផលិតផលប្រហាក់ប្រហែល)។

តាមការពិនិត្យរបាយការណ៍ចំណូលប្រចាំឆ្នាំ២០២៣របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងបានអនុវត្តការប្រមូលចំណូលសេវាសាធារណៈរបស់ខ្លួនបានយ៉ាងប្រសើរ ប្រមាណ២០៧% បើប្រៀបធៀបទៅនឹងច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ ប៉ុន្តែក្រសួងពុំបានប្រមូលចំណូលពីសេវាសាធារណៈ ដែលស្ថិតនៅក្នុងផ្នែកអធិការកិច្ចការងារចំនួន៣ គឺការផ្តល់លិខិតអនុញ្ញាតព្យួរ កិច្ចសន្យាការងារ ការចុះអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ(១ដងក្នុង១ឆ្នាំ សម្រាប់សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរនិងកាបូប និងផលិតផលប្រហាក់ប្រហែល) និងការចុះអធិការកិច្ចការងារសាមញ្ញប្រចាំឆ្នាំ(១ដងក្នុង១ឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថានក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ ផលិត ស្បែកជើង ផលិតផលធ្វើដំណើរនិងកាបូប និងផលិតផលប្រហាក់ប្រហែល)ក្នុងឆ្នាំ២០២៣នៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរអនុវត្តនៃការប្រមូលចំណូលសេវាសាធារណៈឱ្យស្របតាមខ្លឹមសាររបស់ប្រកាសអន្តរក្រសួងខាងលើ។

ឆ្លើយតបចំណុចខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបំភ្លឺថា ក្រោយជំងឺកូវីដ-១៩បានផ្ទុះឡើង រោងចក្រសហគ្រាសក្នុងវិស័យកាត់ដេរ វាយភណ្ឌ និងផលិតផលធ្វើដំណើរ និងកាបូប ទេសចរណ៍ សេវាកម្សាន្តត្រូវរងផលប៉ះពាល់ជាទម្ងន់។ ដូច្នេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលត្រូវជួយដល់វិស័យឯកជនមិនអាចដាក់បន្ទុកដល់រោងចក្រសហគ្រាសបានទេ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធី ឧបត្ថម្ភ ជាសាច់ប្រាក់ដល់កម្មករនិយោជិតសម្រាប់រោងចក្រសហគ្រាសទាំងឡាយណា ដែលបានព្យួរកិច្ចសន្យាការងារថែមទៀតផង។ ទោះយ៉ាងណា ក្រសួងសូមទទួលយកនូវអនុសាសន៍ខាងលើ។ ក្រសួងកំពុងកែសម្រួលសេវាទាំងនេះឱ្យស្របតាមស្ថានភាពបច្ចុប្បន្ន និងតាមសំណូមពររបស់វិស័យឯកជន។

**៤.១៣.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ អំពីការបិទបញ្ជីចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ បានបញ្ជាក់ថា ប្រាក់ចំណូលទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយអាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ ជាកំហិត។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យនៅសល់តួលេខចំណូលមិនមែនសារពើពន្ធ (រដ្ឋបាលកណ្តាលក្រសួង ស្ថាប័ន) ចុងឆ្នាំ២០២៣ ចំនួន ៤ ៤៧៦ លានរៀល ដោយមិនទាន់បាន

បង្វែរចូលថវិកាជាតិបានទាន់ពេលនៅឡើយ។ កត្តានេះ នាំឱ្យការកត់ត្រាចំណូលចំណាយថវិកាមិនឆ្លុះបញ្ចាំងតាមឆ្នាំថវិកា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឯកភាព និងបានបំភ្លឺបន្ថែមថា នៅក្នុងឆ្នាំ២០២៣ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង់ចំណូលខ្វះចំនួន ៤ ៤៧៦ ៤៦០ ០០០ រៀល។ ប៉ុន្តែនៅក្នុងឆ្នាំ២០២៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង់ចំណូលនេះសរុបចំនួន ២ ៤៣៣ លានរៀល ចំពោះទឹកប្រាក់នៅសល់ចំនួន ២ ០៤២ លានរៀល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នឹងបន្តបង់ចូលថវិកាជាតិឱ្យបានគ្រប់ចំនួនមុនដំណាច់ឆ្នាំ២០២៤។ ដោយឡែកសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង់ចំណូលថវិកាជាតិបានត្រឹមត្រូវ និងទាន់ពេលវេលា។

**៤.១៤.ភាពយឺតយ៉ាវក្នុងការចុះបញ្ជីម៉ាក**

ប្រកាសអន្តរក្រសួងលេខ ៣១៥ សហវ ខែឧសភា ១២ទីថ្ងៃប្រក ចុះ.ឆ្នាំ២០២១ រវាងក្រសួងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ក្នុងតារាងឧបសម្ព័ន្ធទី១ ត្រង់លេខរៀងទី៣៧ បានកំណត់រយៈពេលអតិបរមានៃការដាក់ពាក្យស្នើសុំចុះបញ្ជីការត្រួតពិនិត្យលម្អិត ការចុះបញ្ជី និងបោះពុម្ពផ្សាយម៉ាកក្នុង១ជំពូក ពី០៥ ទៅ០៧ខែ។

ចំណុចនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍សវនកម្មសម្រាប់ការិយបរិច្ឆេទកន្លងមក។ ប៉ុន្តែតាមរយៈការត្រួតពិនិត្យលើតារាងនៃការចុះបញ្ជីម៉ាកដែលបានទាញចេញពីប្រព័ន្ធស្វ័យប្រវត្តិកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០២៣ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានចុះបញ្ជីម៉ាកសរុបមួយចំនួនធំ ប៉ុន្តែនាយកដ្ឋាននេះមានភាពយឺតយ៉ាវក្នុងការចុះបញ្ជីម៉ាកមួយចំនួន។ កត្តានេះ អាចនាំឱ្យការផ្តល់សេវាសាធារណៈរបស់នាយកដ្ឋាននៅពុំទាន់ ស្របតាមពេលវេលា ដែលបានកំណត់ដោយប្រកាសអន្តរក្រសួងខាងលើ។

ក្រសួងពាណិជ្ជកម្មបានចុះបញ្ជីម៉ាកសរុបចំនួន ៣ ៩២៣ ក្នុងនោះម៉ាកចំនួន ២ ៦៨១ បានចុះបញ្ជីរួច ប៉ុន្តែមិនអាចអនុលោមតាមរយៈពេលកំណត់ខែ៧ទៅ ៥)) ក្នុងប្រកាសអន្តរក្រសួងលេខ ៣១៥ សហវប្រក។ ការមិនអាចអនុលោមតាមរយៈពេល.កំណត់ គឺអាស្រ័យដោយម៉ាកទាំងនេះ មិនអាចបំពេញតាមលក្ខខណ្ឌដែលកំណត់តាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និង (ច្បាប់ម៉ាក)ត្រូវបានបដិសេធបណ្តោះអាសន្ន ដែលត្រូវបន្តនីតិវិធីក្នុងការតវ៉ានឹងការបដិសេធរបស់នាយកដ្ឋាន តាមរយៈការឆ្លើយតបជាលាយលក្ខណ៍អក្សរ និងផ្តល់ទឡ្ហីករណ៍ និងឯកសារគាំទ្រ ស្របតាមមាត្រា១៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក។ គួរបញ្ជាក់ផងដែរថា ម៉ាកដែលអាចធ្វើការចុះបញ្ជីបានស្របតាមរយៈពេលកំណត់ក្នុងប្រកាសអន្តរក្រសួងពី៥ ទៅ៧ខែបាន លុះត្រាតែម៉ាកនោះបំពេញតាមលក្ខខណ្ឌដែលអាចចុះបញ្ជីបានដែលមានកំណត់ក្នុងច្បាប់ម៉ាក ឬមិនត្រូវបានបដិសេធបណ្តោះអាសន្នណាមួយពីនាយកដ្ឋានជំនាញ។

**៤.១៥.ការទូទាត់និងការកត់ត្រាចំណាយមិនទាន់អនុលោមពេញលេញតាមគោលការណ៍ហិរញ្ញវត្ថុ**

អនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ ត្រង់មាត្រា១១៤ បានចែងថា "សលាកបត្រ

បង្វែរចំណូល និងអាណត្តិបើកប្រាក់ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិកា អាចត្រូវបានបន្តទទួលយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ ដោយត្រូវកត់លេខនាគណនេយ្យនៅត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំអនុវត្ត"។

សារាចរណែនាំលេខ០១០ សហវ.សរណ.អថ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ត្រង់ចំណុចខនៃ I-ខ បានបញ្ជាក់ថា "រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្តត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម (រួមទាំងអាណត្តិទូទាត់ប្រាក់រង្វាន់) និង/ឬប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS ឆ្នាំ២០២៣ ត្រឹមវេលាម៉ោង១៧ និង៣០នាទីនាថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤"។

សារាចរណែនាំបន្ថែមលេខ០០៣ សហវ.សរណ.អរតន ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៣ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣ ត្រង់ចំណុច៣ ផ្នែក "ក" បានបញ្ជាក់ថា "ក្រោយកាលបរិច្ឆេទកំណត់វេលាម៉ោង១៧ និង៣០នាទីនាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ រតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានីខេត្តត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយតកម្មឆ្នាំ២០២៣ ហើយប្រតិបត្តិការចំណាយ (Voucher) ក្នុងប្រព័ន្ធ FMIS ក៏មិនត្រូវបានអនុញ្ញាតឱ្យអនុម័តបញ្ជូនបន្តទៅរតនាគារថ្នាក់កណ្តាលទៀតទេ..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់ (សម្រាប់រដ្ឋបាលកណ្តាល) មួយចំនួនត្រូវបានបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការទូទាត់នៅក្រោយថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ (អំឡុងពេលខែមករា ដល់ខែកុម្ភៈ ឆ្នាំ២០២៤) ហើយបានកត់ត្រាជាចំណាយថវិកាប្រចាំឆ្នាំ២០២៣។

កត្តានេះ អាចធ្វើឱ្យមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តថវិកា និងបង្កការលំបាកដល់កិច្ចជម្រះបញ្ជី ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា នៅរៀងរាល់ដំណាច់ឆ្នាំថវិកានីមួយៗ មានការបញ្ជូនអាណត្តិបើកប្រាក់ក្នុងចំនួនច្រើននាដើមឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានរតនាគារជាតិ ប៉ុន្តែសម្រាប់ឆ្នាំថវិកា២០២៣ មានវឌ្ឍនភាពល្អប្រសើរបានលឿនជាងឆ្នាំកន្លងទៅ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០៣ សហវ.សរណ.អរតន ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីកាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់-អាណត្តិនិយ័តកម្ម និងប្រតិបត្តិការចំណាយថវិកាឆ្នាំ២០២៣ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) សម្រាប់ថវិកាថ្នាក់ជាតិ និងការរៀបចំរបាយការណ៍បូកសរុបការអនុវត្តចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៣។ ដោយឡែក បើពិនិត្យប្រភេទអាណត្តិទាំងនោះ មានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិទូទាត់បុរេប្រទាន នីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងរជ្ជទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវ

ទូទាត់ជម្រះបញ្ជីក្នុងឆ្នាំថវិកា២០២៣ ដើម្បីបិទបញ្ជីចំណាយថវិកា។ ការទូទាត់ចំណាយខាងលើ គឺបានសម្រួលដល់ការទូទាត់ចំណាយចាំបាច់និងបញ្ចៀសការបង្គរបន្ទុកចំណាយទៅឆ្នាំថវិកា២០២៤ និងឆ្នាំបន្តបន្ទាប់។ ម្យ៉ាងទៀត រយៈពេលនេះគឺស្ថិតក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃរតនាគារ។

ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹង (១)បន្តជំរុញក្រសួង ស្ថាប័នឱ្យរួសរាន់រៀបចំលិខិតយុត្តិការចំណាយ និងបោះផ្សាយអាណត្តិបើកប្រាក់ រួចបញ្ជូនទៅអភិបាលថវិកា និងអគ្គនាយកដ្ឋានរតនាគារ ជាតិ ដើម្បីអាចទូទាត់បានទាន់ពេល ជាពិសេសការទូទាត់ជម្រះបញ្ជីបុរេប្រទាន ចំណាយតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន និងចំណាយតាមរជ្ជទេយ្យបុរេប្រទាន ព្រមទាំងចំណាយពាក់ព័ន្ធនឹងនីតិវិធីលទ្ធកម្មសាធារណៈឱ្យទាន់ក្នុងឆ្នាំថវិកា ជៀសវាងការបង្គរបន្ទុកចំណាយថវិកាទៅឆ្នាំថវិកាបន្ទាប់ (២)បន្តពង្រឹងការអនុវត្តការងារពិនិត្យ និងទូទាត់ចំណាយតាមនីតិវិធីថ្មីទាំងស្រុងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីចូលរួមជំរុញការអនុវត្តចំណាយថវិកាឱ្យបានទាន់ពេល (៣) ផ្អែកតាមកម្មវិធីការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលបរិច្ឆេទបញ្ឈប់ការទូទាត់ និងអនុម័ត (Posting) ប្រតិបត្តិការចំណាយថវិកា នឹងរំកិល ១៥ថ្ងៃ ពី១ឆ្នាំ ទៅ១ឆ្នាំ គឺថវិកាឆ្នាំ២០២៣ ត្រឹមថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ថវិកាឆ្នាំ២០២៤ ត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ថវិកាឆ្នាំ២០២៥ ត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៦ និងថវិកាឆ្នាំ២០២៦ ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៧ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣។

### ៤.១៦.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់

សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តិការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈដូចជា កិច្ចសន្យាលទ្ធកម្មដែលមានពន្ធប្រថាប់ត្រា និងបណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ជាដើម។ល។

តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់មួយចំនួនរបស់ក្រសួងមួយចំនួននៅក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើកប្រាក់មួយចំនួនតូច ពុំបានភ្ជាប់នូវឯកសារគាំទ្រឱ្យបានត្រឹមត្រូវដូចជា៖ ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្របតាមកម្មវត្ថុនៃការចំណាយ (ប្រភេទអាជីវកម្មមិនត្រូវតាមការផ្គត់ផ្គង់) និងប្រថាប់ត្រាក្រោយកាលបរិច្ឆេទ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា នៅកៀកដំណាច់ឆ្នាំថវិកា ២០២៣ មានការបញ្ជូនអាណត្តិបើកប្រាក់គំហុកច្រើនមកអគ្គនាយកដ្ឋានរតនាគារជាតិ ហើយក្នុងនោះអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្មមួយចំនួនមានបញ្ហាខ្វះចន្លោះមិនត្រឹមត្រូវតាមនីតិវិធីនៃការទូទាត់ ដោយសារកត្តាពេលវេលា និងការមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ពីដើមទី ហើយបញ្ហាខ្វះចន្លោះមួយចំនួនតម្រូវឱ្យមានកិច្ចសហការចូលរួមពង្រឹងបន្ថែមពីសាមីក្រសួង ស្ថាប័ន និងអង្គភាពពាក់

ព័ន្ធចាប់ពីដើមទី នៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្ម និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយបោះផ្សាយអាណត្តិបើកប្រាក់។ ម្យ៉ាងទៀត ផ្អែកតាមសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់សម្រាប់ការទូទាត់ថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានរតនាគារជាតិ បានបន្តការយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យអាណត្តិបើកប្រាក់ទូទាត់ចំណាយលទ្ធកម្ម ដើម្បីមានមូលដ្ឋានក្នុងការទូទាត់ចំណាយថវិកាដោយផ្អែកលើកំណត់ហេតុប្រគល់ ទទួល ឬកំណត់ហេតុវាយតម្លៃលទ្ធផលការងាររបស់គណៈកម្មការលទ្ធកម្ម ដែលបញ្ជាក់អំពីភាពត្រឹមត្រូវ និងច្បាស់លាស់លើទំនិញ ឬសេវាដែលបានបំពេញរួច។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិបានបន្តណែនាំដល់ក្រសួង ស្ថាប័ន ក៏ដូចជាអ្នកផ្គត់ផ្គង់ឱ្យបំពេញបន្ថែមនូវសក្ខីប័ត្រចំណាយ ដូចជា ការភ្ជាប់ប័ណ្ណប៉ាតង់ឱ្យស្របតាមប្រភេទអាជីវកម្ម និងការបង់ពន្ធប្រថាប់ត្រាលើកិច្ចសន្យាលទ្ធកម្មមួយចំនួន ទើបនាំឱ្យមានករណីហួសកាលបរិច្ឆេទឆ្នាំ២០២៣ ជាដើម។ ករណីនេះ ក៏បានរួមចំណែកក្នុងការប្រមូលពន្ធបង់ចូលថវិការដ្ឋផងដែរ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ណែនាំអគ្គនាយកដ្ឋានរតនាគារជាតិបន្តពង្រឹងការត្រួតពិនិត្យលិខិតយុត្តិការចំណាយ និងទូទាត់ចំណាយថវិកាឱ្យបានត្រឹមត្រូវនិងទាន់ពេល ជាពិសេសបន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងសាមីក្រសួង ស្ថាប័ន ដែលជាអង្គភាពពាក់ព័ន្ធពីដើមទី ឱ្យចូលរួមក្នុងការពង្រឹងនិងដោះស្រាយបញ្ហាប្រឈមទាំងនេះ នៅដំណាក់កាលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងដំណាក់កាលរៀបចំលិខិតយុត្តិការចំណាយមុនពេលបោះផ្សាយអាណត្តិបើកប្រាក់។

**៤.១៧.អង្គភាពថវិកាមួយចំនួនពុំបានផ្ញើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ**

អនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា២៣ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

សារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២៤ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១នៃខែមេសា ខែកក្កដា ខែតុលា និងខែមករា។ ការខកខានដោយមិនបានផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មតាមកាលកំណត់នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពិចារណាផ្អាកការផ្តល់ធានាចំណាយសម្រាប់គម្រោងលទ្ធកម្មបន្តបន្ទាប់។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សម្រាប់ឆ្នាំ២០២៣ ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មមួយចំនួនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលា ប៉ុន្តែមានស្ថាប័នអនុវត្តកិច្ច

លទ្ធកម្មមួយចំនួនទៀតមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលានោះទេ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបញ្ជាក់បន្ថែមថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការណែនាំនិងក្រើនរំលឹក ព្រមទាំងបានរៀបចំផ្ញើលិខិតជូនស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាដែលមិនបានផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០២៣ និងឧបសម្ព័ន្ធរបាយការណ៍របស់អង្គភាពថវិកាតាមរយៈលិខិតលេខ១០២២, ១០២៥, ១០២៦, ១០២៧ សហវ-លស-អលសា ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤។

## ៤.១៨.ការពុំបានគ្រោងក្នុងផែនការលទ្ធកម្ម

ប្រកាសលេខ៨៥១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្ម ត្រង់ប្រការ១៧ បានចែងថា "មូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រូវមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ មានការទទួលខុសត្រូវ និងអាចជឿទុកចិត្តបាន ... តម្រូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្ត ឬអង្គភាពថវិកា" និងប្រការ៣៣ បានចែងថា "រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មទាំងឡាយដែលមិនបានកត់ត្រាក្នុងផែនការលទ្ធកម្ម មិនអនុញ្ញាតឱ្យសុំ ឬផ្តល់ធានាចំណាយឡើយ"។

តាមរយៈការធ្វើសវនកម្មនៅនិយ័តករទូរគមនាគមន៍កម្ពុជាសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា និយ័តករទូរគមនាគមន៍កម្ពុជា បានទូទាត់ចំណាយលើការទិញផ្ទាល់ ឬចុះកិច្ចសន្យាផ្ទាល់ចំពោះសង្ហារឹម សម្ភារការិយាល័យ សម្ភារព័ត៌មានវិទ្យា រថយន្ត ឯកសណ្ឋាន ការជួសជុលអគារ និងប្រាសាទ និងសេវាផ្នែកច្បាប់ ដោយពុំបានគ្រោងក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ២០២៣។

និយ័តករទូរគមនាគមន៍កម្ពុជា បានឯកភាពតាមអនុសាសន៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ដូចនេះអាជ្ញាធរសវនកម្មជាតិនឹងបន្តធ្វើការតាមដានលើការកែលម្អអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

## ៤.១៩.កង្វះខាតក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងការងារជួសជុល និងថែទាំអគារ

ប្រកាសលេខ ១៦១៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រង់ជំពូកទី២ ផ្នែកទី៣ បានចែងថា "អ្នកផ្គត់ផ្គង់ និងអ្នកទទួលការមានភារកិច្ចអនុវត្តកិច្ចសន្យាលទ្ធកម្ម សំខាន់ៗ ជាអាទិ៍៖ រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងាររហូតដល់ការប្រគល់ ទទួលចប់ជាស្ថាពរជូនស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកា"។

តាមការពិនិត្យផែនការលទ្ធកម្មប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈបានអនុវត្ត

កិច្ចលទ្ធកម្មសាធារណៈសរុបចំនួន២៥គម្រោង ក្នុងនោះមានចំនួន២គម្រោង ដែលអ្នកទទួលការពុំបានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួរណែនាំដល់អ្នកទទួលការត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តការងារជួសជុល និងថែទាំអគារឱ្យបានស្របតាមប្រកាសខាងលើ

ឆ្លើយតបនឹងចំណុចខាងលើ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានព្យាយាមអនុវត្ត និងកែតម្រូវតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

**៤.២០.ការអនុវត្តតួនាទីអង្គភាពថវិកាមិនទាន់ពេញលេញ**

អនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់មាត្រា១ បានបញ្ជាក់ថា "អង្គភាពថវិកា គឺជាអង្គភាពដែលត្រូវបានទទួលស្គាល់អាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្ម ភាពការងារ ដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណង គោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័ន" និងប្រកាសអន្តរក្រសួងលេខ១១២ ប្រក.ធទ.ខ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងធនធានទឹក និងឧតុនិយមស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់ប្រការ១ បានបញ្ជាក់ថា "ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន២៧ ដូចខាងក្រោម៖

- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល
- អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស
- មន្ទីរធនធានទឹក និងឧតុនិយមរាជធានី-ខេត្តចំនួន២៥

តាមការចុះធ្វើសវនកម្មលើអាណត្តិទូទាត់របស់ក្រសួងធនធានទឹក និងឧតុនិយមក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេសមិនទាន់មានអាណត្តិកិច្ចច្បាស់លាស់ (អាណាប័កផ្ទេរសិទ្ធិ) ក្នុងការអនុវត្តសកម្មភាពការងាររបស់ខ្លួន ដូចជាការទូទាត់ថវិកាចំណាយរដ្ឋទេយ្យបុរេប្រទាននៅឡើយ។ ដូចនេះ ក្រសួងធនធានទឹក និងឧតុនិយម គួរអនុវត្តឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិ។

ឆ្លើយតបនៅការលើកឡើងខាងលើ ក្រសួងធនធានទឹក និងឧតុនិយមសូមទទួលយកនូវលទ្ធផលដែលបានរកឃើញ និងសូមធ្វើការកែលម្អតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិនៅឆ្នាំបន្ទាប់។

**៤.២១.ការកត់ត្រាចំណាយពុំទាន់បានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ**

ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ បានកំណត់ដូចខាងក្រោម៖

- អនុគណនី២១០៣១ ចំណាយ និងកត់ត្រាចំណាយលើការទិញ និងសាងសង់ អគារសាធារណៈ

- អនុគណនី២១០៣២ ចំណាយ និងកត់ត្រាចំណាយលើការកែលម្អអគារសាធារណៈ
- អនុគណនី៦០០៥១ ចំណាយលើការទិញសម្ភារ និងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា
- អនុគណនី៦០០៥៣ ចំណាយលើការទិញសម្ភារប្រើប្រាស់ ដូចជា៖ សម្ភារកីឡាគ្រប់ប្រភេទ ថ្មពិលគ្រប់ប្រភេទ ហ្វីលថត(អង្គចងចាំ)ការសែតថតសម្លេង ការសែតវីដេអូ ញញួរ សោរចាក់ ម៉ាស៊ីនចោះ ឬខួង ចប តង់ កៅស៊ូ រណា រាំងនន។ល។
- អនុគណនី៦០០៥៥ ចំណាយលើការទិញសម្ភារ និងបរិក្ខាបច្ចេកទេសព័ត៌មានវិទ្យា ដូចជា៖កុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថត ទូរស័ព្ទ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនស្កេន។ល។
- អនុគណនី៦០០៥៨ ចំណាយលើទិញសម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារផ្សេងទៀតក្រៅពីអនុគណនីខាងលើ
- អនុគណនី៦១០៥២ ចំណាយលើការថែទាំ ជួសជុលអគារ របងអគារ ចំណតរថយន្ត បន្ទប់ទឹក ឃ្លាំង ប្រាសាទ អាកាសយាន្តដ្ឋាន កំពង់ផែ ទីផ្សារ សត្វឃាត្តដ្ឋាន (សួនច្បារក្នុងទីធ្លា) ដែលមានសេវាផ្គត់ផ្គង់ពីខាងក្រៅ ព្រមទាំងចំណាយការលាបថ្នាំការរៀបចំបណ្តាញ ឡើងវិញដែលបណ្តាលមកពីការជួសជុលអគារ លើកលែងតែការចំណាយទិញឧបករណ៍ថ្មីបំពាក់បន្ថែមដែលត្រូវកត់ត្រាក្នុងជំពូក (៦០)។ល។
- អនុគណនី៦១០៥៤ ចំណាយលើការងារជួសជុល ថែទាំគ្រប់ប្រព័ន្ធបណ្តាញទាំងអស់ដែលមិនមែនជាផ្លូវចរាចរ ហើយមិនពាក់ព័ន្ធនឹងការជួសជុលអគារ
- អនុគណនី៦១១០៤ ចំណាយរៀបចំពិធីបុណ្យប្រពៃណី បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ បុណ្យរុក្ខទិវា និងពិធីបុណ្យផ្សេងៗទៀត
- អនុគណនី៦១១០៧ សម្រាប់ចំណាយលើការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ
- អនុគណនី៦២០៣៨ ចំណាយទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ផ្សេងទៀតក្រៅពីអនុគណនីខាងលើ
- អនុគណនី៦៥០២២ ចំណាយលើការឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម
- អនុគណនី៧៣០២៨ ចំណូលទទួលបានពីការបញ្ជាក់លើហត្ថលេខា លិខិតចម្លងច្បាប់ដើម វិញ្ញាបនប័ត្រ លិខិតបញ្ជាក់ការសិក្សា ព្រឹត្តិបត្រពិន្ទុ លិខិតផ្សេងៗ...

លិខិតលេខ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីករណីសំណើសុំកែសម្រួលគោលការណ៍ចំណាយមួយចំនួនសម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តចាប់ពីឆ្នាំ២០១៩តទៅ ត្រង់ចំណុច៕ មុខសញ្ញាចំណាយ អនុគណនី៦០០២៨ (កិច្ចដំណើរការរដ្ឋបាល ចំណុចគ (សម្ភារបរិក្ខារ និងសង្ហារឹម) សម្រាប់ចំណាយលើការទិញ កុំព្យូទ័រ ម៉ាស៊ីនអិលស៊ីឌី ម៉ាស៊ីនព្រីនធ័រ កាមេរ៉ាសុវត្ថិភាព អាគុយ កង្ហារ ទូរស័ព្ទលើតុ បំពង់ពន្លត់អគ្គីភ័យ ឧបករណ៍បំពងសម្លេង តុ

ទូ ធ្នើរ កៅអី ក្តារ ខៀន និងអនុគណនី៦០០៥៨(សម្ភាររៀន និងបង្រៀន) ចំណាយសម្រាប់ការទិញសម្ភាររៀន និងបង្រៀន សម្ភារសម្រាប់ពិសោធន៍ និងសម្ភារសម្រាប់បំណិនជីវិត អប់រំកាយ និងកីឡា ការងារយុវជន និងកុមារ...។

តាមការធ្វើសវនកម្មក្នុងឆ្នាំ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុវត្ត និងកត់ត្រាចំណាយមួយចំនួនពុំទាន់បានត្រឹមត្រូវឱ្យស្របទៅតាមខ្លឹមសារនៃប្រកាសខាងលើនៅឡើយ ដូចជា៖

- ក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពថវិកាមួយចំនួនរបស់ក្រសួង បានចំណាយ និងកត់ត្រាចំណាយមួយចំនួនពុំទាន់បានត្រឹមត្រូវស្របតាមប្រកាសខាងលើ ដែលសរុបជាទឹកប្រាក់ មានចំនួន៦ ២៩៤ ២០៥ ០០០រៀ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានអនុវត្តការចំណាយប្រតិបត្តិការសម្រាប់ចំណាយលើការបំពាក់ឧបករណ៍បណ្តុះបណ្តាលជំនាញវិស្វកម្មអគ្គិសនីក្នុងឆ្នាំ២០២៣ ដែលមានទឹកប្រាក់ចំនួន ៣៩៧ ៥៥០ ០០០ រៀល និងបានធ្វើការកត់ត្រាការចំណាយខាងលើពុំទាន់ស្របទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនៅឡើយ។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការកត់ត្រាចំណាយលើមុខសញ្ញាចំណាយផ្គត់ផ្គង់សម្ភារមួយចំនួនក្នុងគម្រោងកិច្ចលទ្ធកម្មមិនទាន់បានត្រឹមត្រូវស្របតាមប្រកាសខាងលើ សរុបជាទឹកប្រាក់ចំនួន ៨៣៥ ៩៥០ ០០០រៀល។

ក្រសួងខាងលើ គួរធ្វើការណែនាំដល់មន្ត្រីហិរញ្ញវត្ថុនៃអង្គភាពថវិការបស់ខ្លួនឱ្យអនុវត្តចំណាយ និងកត់ត្រាចំណាយឱ្យស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងខាងលើ និងអង្គភាពថវិកាក្រោមឱវាទដែលពាក់ព័ន្ធខាងលើ បានឯកភាពទទួលយកចំពោះការរកឃើញខាងលើ និងខិតខំកែលម្អចំណុចខ្វះខាតទាំងនោះនៅឆ្នាំបន្ទាប់ទៀត។

### ៤.២២.បំណុលពីការជួលដីទំនេរ និងដីមានអគារ

អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ផ្នែកទី៣ មាត្រា៤២ ចំណុចត្រេទី៣ បានចែងថា "ផុតរយៈពេល៦ខែ(ប្រាំមួយខែ) គិតពីថ្ងៃផុតកំណត់ឱ្យបង់ប្រាក់ ក្នុងករណីអ្នកជាប់កាតព្វកិច្ចនៅតែមិនទូទាត់បំណុលរបស់ខ្លួនក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលមិនមែនសារពើពន្ធត្រូវបញ្ជូនសំណុំរឿង និងឯកសារភស្តុតាងទាំងអស់ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផ្តល់កិច្ចសហការដើម្បីតឹងទារបំណុលតាមរយៈយន្តការអន្តរក្រសួងដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" និងបទបញ្ជាលេខ ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ បានចែងថា "ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់ចេញវិធានការជាមួយក្រសួង-ស្ថាប័នសាមី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារ

បំណុលដែលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជាៈ បញ្ឈប់ការអនុញ្ញាតនាំចូល-នាំចេញ បង្កក គណនីធនាគារ បញ្ឈប់អាជ្ញាបណ្ណ និងក្នុងករណីការអនុវត្តតឹងទារបំណុលនេះមិនមានប្រសិទ្ធភាព ក្រសួង-ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្ដឹងទៅតុលាការ"។

តាមការពិនិត្យ និងផ្ទៀងផ្ទាត់ចំណូលថ្លៃជួលរោងចក្រ សហគ្រាស និងអចលនវត្ថុឆ្នាំ២០២៣ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងកិច្ចសន្យាជួលទីតាំង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមានបំណុលថ្លៃឈ្នួលជួលចំនួន១ទីតាំង ដែលមានទឹកប្រាក់ចំនួន ១៤៣ ០៨៤.១១ ដុល្លារអាម៉េរិក និងនៅមានបំណុលរ៉ាំរ៉ៃ ចំនួន៣ទីតាំង (១.ទីតាំងអគារត្រួតពិនិត្យកាសែត ២.ទីតាំងរោងភាពយន្តវិមានទិព្វ និង៣.ទីតាំងរោងភាពយន្តភ្នំពេញ ដែលទីតាំងទាំង៣នេះ ស្ថិតនៅក្រោមការកាន់កាប់របស់ឯកជនជាយូរឆ្នាំណាស់មកហើយរហូតមកដល់បច្ចុប្បន្ននេះ) មានចំនួនទឹកប្រាក់សរុប ៦៦ ៥១២ ដុល្លារ អាម៉េរិក។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរបន្តតឹងទារបំណុលខាងលើ តាមការអនុវត្តយន្តការដែលបានកំណត់ដោយអនុក្រឹត្យ និងបទបញ្ជាខាងលើ។

ចំពោះចំណុចនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានបំភ្លឺថា ចំពោះថ្លៃឈ្នួលអតីតមហោស្រពទន្លេបាសាក់ ក្រសួងបានធ្វើលិខិតទារទៅក្រុមហ៊ុន ដូចបានរៀបរាប់ខាងលើ។ ចំណែកបំណុលថ្លៃឈ្នួលជួលទីតាំងចំនួន៣ទៀត ដែលមានបំណុលរ៉ាំរ៉ៃដែលមានលិខិតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្ដីការគណៈរដ្ឋមន្ត្រីស្ដីពីការលក់ផ្ដាច់ ទិញផ្ដាច់ និងដោះដូរទីតាំងក្រសួងកំពុងរៀបចំធ្វើលិខិតសុំគោលការណ៍ពីរដ្ឋាភិបាលសុំលុបបំណុលរ៉ាំរ៉ៃនេះ។

### ៤.២៣.ភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

សារាចរណែនាំលេខ០០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវ គ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗក្នុងចន្លោះរយៈពេល០៥ (ប្រាំ) ឆ្នាំនៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំដែលរៀបចំរួច ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន០២ (ពីរ) ច្បាប់យ៉ាងយូរនៅដំណាច់ត្រីមាសទី១នៃឆ្នាំបន្ទាប់ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី។

តាមការធ្វើសវនកម្មនៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា គិតត្រឹមថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ ក្រសួង ស្ថាប័ន (ថ្នាក់កណ្ដាល) សហគ្រាសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងមន្ទីជំនាញថ្នាក់មូលដ្ឋានមួយចំនួន បានរៀបចំ និងផ្ញើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនទៀតមិនបានផ្ញើតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២៣ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឡើយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាព និងសូមបំភ្លឺបន្ថែមថា ជារៀងរាល់ឆ្នាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែងតែជូនដំណឹងទៅអាជ្ញាធរកាន់កាប់ទាំងអស់ដែលជាក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ព្រមទាំងបានចុះពិនិត្យផ្ទៀងផ្ទាត់ និងជំរុញបន្ថែមទៀតផងដែរ។ ចំពោះការិយបរិច្ឆេទឆ្នាំ២០២៣នេះ ក៏បានរៀបចំដូចឆ្នាំកន្លងមក។ បច្ចុប្បន្នមាន វឌ្ឍនភាពជាបន្តបន្ទាប់ពី មួយឆ្នាំទៅមួយឆ្នាំទាំងការធ្វើទំនើបកម្ម លិខិតបទដ្ឋានគតិយុត្ត និងការប្រមូល បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ រដ្ឋ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមសំណូមពរអាជ្ញាធរសវនកម្មជាតិជួយជំរុញបន្ថែមទៅអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលមានភាពយឺតយ៉ាវក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំផងដែរ។

**៤.២៤.ភាពយឺតយ៉ាវ និងកង្វះខាតក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ**

សារាចរណែនាំលេខ០០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជាស្ដីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ចំណុចទី៥ បានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ដែលស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រសួង ស្ថាប័នថ្នាក់កណ្ដាលចំនួន៣៧ និងមន្ទីរ អង្គភាពថ្នាក់មូលដ្ឋាននៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភាពយឺតយ៉ាវក្នុងការធ្វើប័ណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋរបស់ខ្លួន។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែងតែជំរុញទៅអាជ្ញាធរកាន់កាប់ដាក់ពាក្យស្នើសុំរៀបចំធ្វើប័ណ្ណកម្មសិទ្ធិបានកាន់តែច្រើនហើយចំនួនដីដែល ពុំទាន់មានប័ណ្ណកម្មសិទ្ធិកាន់តែនៅ សល់ចំនួនតិចទៅៗ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីជំរុញការរៀបចំនិងធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋនៅ

ក្របខ័ណ្ឌទូទាំងប្រទេស។ កន្លងមកគណៈកម្មការអន្តរក្រសួងនេះ បានបើកយុទ្ធនាការចុះផ្សព្វផ្សាយ និងជំរុញការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋនៅទូទាំង២៥ រាជធានី ខេត្ត ដែលមានរយៈពេល ៤ខែ ចាំពីខែតុលា ឆ្នាំ២០២២ ដល់ខែមករា ឆ្នាំ២០២៣។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសំណូមពរអាជ្ញាធរសវនកម្មជាតិ ជួយជំរុញបន្ថែមទៅអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលពុំទាន់បានធ្វើប័ណ្ណកម្មសិទ្ធិលើដីរដ្ឋ រួសរាន់រៀបចំដាក់ពាក្យស្នើសុំធ្វើឱ្យបានឆាប់។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ បានបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលបានគិតគូរយ៉ាងហ្មត់ចត់ និងរៀបចំឡើង ដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ និងប្រាក់ចំណូលរបស់ប្រជាជន ព្រមទាំងទ្រទ្រង់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច ពិសេសការបន្តអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ និងធានាដល់ជោគជ័យនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ និងការធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេមឆ្នាំ២០២៣ ក៏ដូចជាការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការសម្រេចឱ្យបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលត្រូវបានកំណត់នៅក្នុង**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤** និង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣**។ ការអនុវត្តបញ្ចប់សកម្មភាពអាទិភាពនៅសេសសល់របស់ក្រសួង ស្ថាប័ន ក៏ដូចជារបស់រាជរដ្ឋាភិបាលនៅក្នុងឆ្នាំចុងក្រោយនៃអាណត្តិរាជរដ្ឋាភិបាល នីតិកាលទី៦ ជាពិសេសកិច្ចការកែទម្រង់លើគ្រប់វិស័យ សំដៅកសាងមូលដ្ឋានគ្រឹះបន្ថែមក្នុងដំណើរការឈានឆ្ពោះទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជាដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានមោទនភាពជាតិ មានអនាគតដ៏រុងរឿង ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងជារដ្ឋអធិបតេយ្យមួយដ៏រឹងមាំដែលគោរពបានយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ និងមានសន្តិភាពពេញលេញ ព្រមទាំងមានកិត្យានុភាពខ្ពស់ត្រដែតលើឆាកអន្តរជាតិ និងបន្តរក្សាការពារសមិទ្ធផលសង្គមជាតិទាំងឡាយដែលសម្រេចបានកន្លងមកប្រកបដោយភាពជាម្ចាស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែង ដើម្បីជម្នះ និងទប់ទល់ផលប៉ះពាល់អវិជ្ជមាននានាដែលអាចកើតមានឡើងនាពេលអនាគត ក្នុងស្មារតីធានាឱ្យកម្ពុជាអាចឈរដ៏រឹងមាំ និងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួនក្នុងគ្រប់កាលៈទេសៈ។ ទោះបីជារាជរដ្ឋាភិបាលបានជួបនូវការលំបាកខាងលើដែលពុំធ្លាប់ជួបប្រទះពីមុនៗមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅតែអាចគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អ ទាំងការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយថវិកា ការគ្រប់គ្រងបំណុល និងការធ្វើកិច្ចបញ្ជិកាគណនេយ្យយ៉ាងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតជាងពេលណាៗទាំងអស់ក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ក្នុងការបន្តរក្សាសុខសន្តិភាព ស្ថិរភាព ឯករាជ្យជាតិ

និងអធិបតេយ្យភាព ដែលជាបំណងប្រាថ្នារួមរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឱ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឱ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព៕